ក្រសួងអប់រំ យុវជន និង កីឡា

# កម្មវិធីសាលាកុមារមេត្រី

## សមាសភាគទី ២ : ប្រសិទ្ធភាពនៃការបង្រៀន និង រៀន

# ការអប់រំបំណិនជីវិតតាមមូលដ្ឋាន



# ឯកសារណែនាំគ្រូ

២០០៩

# ការអប់រំបំណិនជីវិតតាមមូលដ្ឋាន

## I. សេចក្តីផ្តើម

ការអប់រំជាកក្តាគន្លឹះក្នុងការអភិវឌ្ឍសង្គមជាតិ ពីព្រោះការអភិវឌ្ឍសង្គមជាតិគេត្រូវការធនធានមនុស្សដែលមានគុណភាព ចំណេះដឹង បំណិន និង ឥរិយាបថល្អ ចេះអភិវឌ្ឍខ្លួនឯងផង និង សង្គមជាតិផង ។ ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា (២០០៣-២០១៥) ក្នុងចំនុចទី ៦ បានចែងថា "...កែលំអគ្រប់ទិដ្ឋភាពនៃគុណភាពអប់រំ និង ធានាបាននូវគុណភាពប្រសើរបំផុតគ្រប់ផ្នែក ដើម្បីឱ្យមនុស្សគ្រប់រូបដណ្តើមបានលទ្ធផលរៀនសូត្រ មានកំរិតវាស់បាន មានការទទួលស្គាល់ ជាពិសេសផ្នែកភាសាខ្មែរ លេខនព្វន្ត និង ជំនាញចាំបាច់សំរាប់ចិញ្ចឹមជីវិត (បំណិនជីវិត)" ។

ទន្ទឹមគ្នានេះដែរ ការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ តម្រូវឱ្យមានការកែលំអកម្មវិធី សិក្សាយ៉ាងហោចណាស់ ១០ ឆ្នាំម្តង ។ ជាក់ស្តែងនៅប្រទេសកម្ពុជា មានការកែលំអកម្មវិធីសិក្សាជាបន្តបន្ទាប់ ដូចជាកម្មវិធីសិក្សាក្រោយឆ្នាំ១៩៧៩ ការបង្រៀនផ្តោតទៅលើគោលវិធី "គ្រូមជ្ឈមណ្ឌល" ហើយនៅឆ្នាំ១៩៩៦ ការកែលំអកម្មវិធីសិក្សាបានផ្តោតទៅលើគោលវិធី "សិស្សមជ្ឈមណ្ឌល" ដែលធ្វើឱ្យតួនាទីរបស់គ្រូបង្រៀន ផ្លាស់ប្តូរ ។ នៅឆ្នាំ ២០០៤ ក្រសួងអប់រំ យុវជន និង កីឡា បានបង្កើតគោលនយោបាយសំរាប់អភិវឌ្ឍកម្មវិធីសិក្សា ចំណេះទូទៅ ២០០៥-២០០៩ ដែលអនុញ្ញាតិឱ្យមានកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ២-៥ ម៉ោងក្នុងមួយសប្តាហ៍ បន្ថែមលើកម្មវិធីសិក្សាជាតិ (២៥ ម៉ោងសម្រាប់បឋមសិក្សា ៣០ ម៉ោងសម្រាប់មធ្យមសិក្សាបឋមភូមិ និង ៣២ ម៉ោងសម្រាប់មធ្យមសិក្សាទុតិយភូមិ) និង មានរយៈពេល ៣៨ សប្តាហ៍ ក្នុងមួយឆ្នាំសិក្សា ។ ចំណុចសំខាន់នៅក្នុងគោលនយោបាយសំរាប់អភិវឌ្ឍន៏កម្មវិធីសិក្សាថ្មីនេះគឺ តម្រូវឱ្យបញ្ចូលខ្លឹមសារបំណិនជីវិតទៅក្នុងសៀវភៅសិក្សាមុខវិជ្ជានីមួយៗ និង កម្មវិធីបំណិនជីវិតតាមមូលដ្ឋានត្រូវផ្តល់ឱ្យសិស្សនូវបំណិនទាំងឡាយដែលមាននៅក្នុងមូលដ្ឋានរបស់ពួកគេ ។

ឯកសារណែនាំការអនុវត្តកម្មវិធីបំណីនជីវិតតាមមូលដ្ឋាន ដែលបានបង្កើតឡើងនៅពេលនេះគឺជាឯកសារជំនួយមួយសំរាប់ក្រុមការងារថ្នាក់ស្រុក នាយកសាលា គ្រូបង្រៀន និង សហគមន៏ អភិវឌ្ឍ និង អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅថ្នាក់កម្រងសាលា ទៅតាមតម្រូវការសិក្សារបស់សិស្សនៅក្នុងមូលដ្ឋានរបស់ខ្លួន ដែលរួមចំណែកដល់ការ អនុវត្តកម្មវិធីសាលាកុមារមេត្រី និង ការប្រើប្រាស់ស្តង់ដាកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព ។

## II. គោលបំណងរួម

- លើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និង រៀន ដោយផ្សារភ្ជាប់ការរៀនសូត្រនៅក្នុងថ្នាក់ទៅនឹងការរស់នៅជាក់ស្តែង ដើម្បីជួយពួកគេអភិវឌ្ឍបំណិនផ្នែកសង្គម ការគិតដោយវិភាគ ការដោះស្រាយបញ្ហាងាយៗ ដែលកើតមាន នៅក្នុងសហគមន៍របស់គេ តាមរូបភាព និងសកម្មភាពនៃការរៀនសូត្រខុសៗគ្នា ដោយមានការចូលរួមពីសហគមន៍
- លើកទឹកចិត្តការិយាល័យអប់រំស្រុក ដើម្បីដឹកនាំការអភិវឌ្ឍ និង អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅតាមកម្រងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស និង បញ្ហាជាក់ស្តែងដែលគេជួបប្រទះរាល់ថ្ងៃ
- ជួយបំពេញបន្ថែមកម្មវិធីសិក្សាថ្នាក់ជាតិ ដែលផ្តោតលើការអភិវឌ្ឍចំណេះដឹង ដោយផ្តល់ឱកាសឱ្យសិស្សអភិវឌ្ឍបំណិនជាច្រើនតាមរយៈធ្វើសកម្មភាពផ្ទាល់ដើម្បីឆ្លើយតបទៅនឹងចតុស្តម្ភអប់រំ ដែលតម្រូវឱ្យសិស្សមានចំណេះដឹង ចំណេះធ្វើ ឥរិយាបថល្អ និង ចេះរស់នៅជាមួយគ្នាដោយសុខុដមរម្យនា
- ជួយពង្រឹងបន្ថែមការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៅក្នុងមុខវិជ្ជាផ្សេងៗទៀតនៃកម្មវិធីសិក្សាជាតិ ។

## III. ខ្លឹមសារ

ជំពូកទី ១ : ទិដ្ឋភាពទូទៅនៃកម្មវិធីបំណិនជីវិត

ជំពូកទី ២ : ការអភិវឌ្ឍ និង អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅថ្នាក់កម្រង

ជំពូកទី ៣ : របៀបរៀនរបស់កុមារ និង វិធីដឹកនាំសកម្មភាពរៀន

ជំពូកទី ៤ : ការវាយតម្លៃការបង្រៀន និង រៀន កម្មវិធីបំណិនជីវិត

# ជំពូកទី ១ : ទិដ្ឋភាពទូទៅនៃកម្មវិធីបំណិនជីវិត

## ១. គោលនយោបាយកម្មវិធីបំណិនជីវិត

ផ្អែកលើគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ បានកំណត់ថា "..សាលារៀនត្រូវបង្កើនភាពជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍ រដ្ឋអំណាចមូលដ្ឋាន និង អង្គការ មិនមែនរដ្ឋាភិបាល ហើយត្រូវអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលមានពី ២ ទៅ ៥ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ដែលជាផ្នែក មួយនៃកម្មវិធីសិក្សាជាតិ..."។ ឆ្លើយតបទៅនឹងគោលនយោបាយថ្មីនេះ ក្រសួងអប់រំ យុវជន និង កីឡា បានអភិវឌ្ឍ គោលនយោបាយបំណិនជីវិត (ឆ្នាំ២០០៦) ដែលបានចែងថា ការអនុវត្តកម្មវិធីបំណិនជីវិតមាន២រូបភាព:

- ***ទី ១ ការបញ្ជ្រាបចូលទៅក្នុងកម្មវិធីសិក្សាជាតិ*** តាមរយៈមុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និង សិក្សាសង្គម ដើម្បីឱ្យការសិក្សារបស់សិស្សមានភាពសកម្ម និង ការចូលរួម ។ ការសិក្សាដែលមាន ភាពសកម្ម និង ការចូលរួម បង្កឱកាសឱ្យសិស្សអភិវឌ្ឍបំណិនមូលដ្ឋានជាច្រើន ដូចជាការប្រាស្រ័យ ការវិភាគ ការ សម្រេចចិត្ត ការដោះស្រាយបញ្ហា ទំនុកចិត្តលើខ្លួនឯង ការទទួលខុសត្រូវ ឥរិយាបថវិជ្ជមាន ។ល។ សកម្មភាព បង្រៀន និង រៀនទាំងនេះ នឹង រួមចំណែកដល់ការសម្រេចគោលនយោបាយកម្មវិធីសាលាកុមារមេត្រីរបស់ក្រសួង អប់រំ យុវជន និង កីឡា (២០០៧) ក្នុងសមាសភាគទី ២ ស្តីពីការលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និង រៀន ។

- ***ទី ២ ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន*** ដែលឆ្លើយតបទៅនឹងតម្រូវការរៀនសូត្ររបស់សិស្ស ដោយ មានការចូលរួមពីសហគមន៍ និង រួមចំណែកដោះស្រាយបញ្ហាងាយៗដែលមាននៅក្នុងសហគមន៍ ។ ប្រការនេះបាន ជួយបំពេញឱ្យកម្មវិធីសិក្សាជាតិ ដែលអាចជួយសិស្សឱ្យបន្តសិក្សាទៅថ្នាក់លើទៀត ហើយអ្វីដែលជាតម្រូវការតាមសហគមន៍នីមួយៗគេអាចសិក្សានៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ។ ដោយសារកម្មវិធីបំណិនជីវិតតាមមូលដ្ឋានជាកម្មវិធីថ្មីសម្រាប់យើងទាំងអស់គ្នា ដូចនេះនៅខេត្តព្រៃវែង បានសាកល្បងអភិវឌ្ឍ និង អនុវត្តកម្មវិធីសិក្សានេះនៅ ថ្នាក់កម្រងសាលា ដើម្បីងាយស្រួលក្នុងការងារពិនិត្យតាមដាន និង គ្រប់គ្រងរបស់ការិយាល័យអប់រំស្រុក ។

ដោយសារកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (បំណិនមូលដ្ឋាន និង បំណិនអាជីព) ប្រកបដោយគំនិតច្នៃប្រឌិត ហើយខុសគ្នាពីសហគមន៍មួយទៅសហគមន៍មួយ វាជាការសំខាន់ណាស់ដែលគ្រូបង្រៀន និង មន្ត្រីអប់រំត្រូវប្រើស្តង់ដាកម្មវិធីសិក្សាដើម្បីវាយតម្លៃការសិក្សារបស់សិស្ស ដោយផ្តោតទៅលើបំណិនមូលដ្ឋាន ឬ បំណិនអាជីព ដែលកម្មវិធីនីមួយៗព្យាយាមសម្រេចឱ្យបាន(សូមមើលការវាយតម្លៃនៅទំព័រទី៥៦ និង ស្តង់ដាកម្មវិធីសិក្សាឆ្នាំ២០០៦) ។ ម្យ៉ាងវិញទៀត យុទ្ធវិធីក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (៦ ដំណាក់កាល) រួមចំណែកដល់ការអនុវត្តកម្មវិធីសាលាកុមារមេត្រីផងដែរ ជាពិសេសសមាសភាគទី ២ និង ៥ ។ ទន្ទឹមគ្នានេះដែរ ដោយសារវាជាកម្ម

វិធីដែលឆ្លើយតបទៅនឹងតម្រូវការតាមមូលដ្ឋាន ដូចនេះវាក៏អាចឆ្លើយតបទៅនឹងសមាសភាគផ្សេងៗទៀតដែរ ។ ឧទាហរណ៍ : បើវាជាបញ្ហាសិស្សបោះបង់ការសិក្សា វានឹងឆ្លើយតបទៅនឹងសមាសភាគទី ១ ប៉ុន្តែបើវាជាបញ្ហាដែលទាក់ទងទៅនឹង សុខភាព សុវត្ថិភាព ឬ យេនឌ័រ វានឹងឆ្លើយតបទៅនឹងសមាសភាគទី ៣ និង ៤ ។ ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស និង ប្រជុំបច្ចេកទេសប្រចាំខែរបស់ក្រុមការងារថ្នាក់ស្រុក ជាផ្នែកមួយនៃការគាំទ្ររបស់ប្រព័ន្ធអប់រំដែលឆ្លើយតបទៅនឹង សមាសភាគទី ៦ នៃកម្មវិធីសាលាកុមារមេត្រី ។

## កំណត់ចំណាំ

* នៅពេលជ្រើសរើស កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ត្រូវកំណត់គោលបំណងឱ្យបានច្បាស់ ហើយ សមស្របទៅនឹងក្រុមអាយុអ្នកដែលរៀននៅក្នុងកម្មវិធីនោះ (បំណិនមូលដ្ឋាន ឬ បំណិនអាជីព) ។
* ការអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននេះ មានគោលបំណងជួយធ្វើឱ្យការអនុវត្តកម្មវិធីបំណិនជីវិតឱ្យមានភាពជាក់លាក់ងាយស្រួលយកទៅអនុវត្ត ។
* ការអភិវឌ្ឍម្មវិធីបំណិនជីវិតតាមមូលដ្ឋាននេះ មានខ្លឹមសារឆ្លើយតបទៅនឹងស្តង់ដាកម្មវិធីសិក្សាកម្រិតអប់រំមូលដ្ឋានដូចជាការផ្តល់ឱ្យសិស្សនូវសមត្ថភាពវិភាគវែកញែកភាពខុសគ្នារវាងការពិត និង គំនិតនៅពេលស្តាប់ព័ត៌មាន ការសម្តែងតួការសម្ភាស ការឆ្លើយតប ការបង្ហាញគំនិតផ្ទាល់ខ្លួនដោយមានហេតុផលច្បាស់លាស់ការធ្វើការជាក្រុមជាដើម ។ ម្យ៉ាងទៀតកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននេះ ជួយបំពេញបន្ថែមទៅលើកម្មវិធីសាលាកុមារមេត្រី ក្នុងការលើកកម្ពស់គុណភាពអប់រំជាពិសេសសមាសភាគទី២ស្តីពីគឺប្រសិទ្ធភាពនៃការបង្រៀន-រៀន និង សមាសភាគទី ៥ ស្តីពីការចូលរួមរបស់កុមារ គ្រួសារ និង សហគមន៍ ។



## ២. អត្ថន័យបំណិនជីវិត

បំណិនជីវិតមានន័យទូលំទូលាយ ហើយត្រូវបានគេឱ្យនិយមន័យខុសៗគ្នាទៅតាមបរិបទរបស់វា ។ កម្មវិធីបំណិន ជីវិតមានគោលបំណងជួយ : ១).អភិវឌ្ឍស្វ័យភាពសិក្សាដល់សិស្ស ២).បង្កើនសមត្ថភាពដើម្បីដោះស្រាយបញ្ហា និង ៣).អភិវឌ្ឍទស្សនៈសិក្សាដើម្បីលើកកម្ពស់ជីវភាពរស់នៅ ។ កម្មវិធីបំណិនជីវិតក្នុងកម្រិតអប់រំមូលដ្ឋានផ្តោតទៅលើ ការអភិវឌ្ឍបំណិនមូលដ្ឋាន រួមមានចំណេះដឹង ការប្រតិបត្តិងាយៗ និង បុរេវិជ្ជាជីវៈ ព្រមទាំងបំណិនទូទៅ និង គុណភាពផ្ទាល់ខ្លួន ។ ដោយឡែកកម្មវិធីបំណិនជីវិតសម្រាប់មធ្យមសិក្សា និង ក្រៅប្រព័ន្ធផ្តោតលើការអភិវឌ្ឍបំណិនអាជីព រួមមានបំណិនបច្ចេកទេស ការគ្រប់គ្រងអាជីវកម្ម និង បំណិនមូលដ្ឋាន ដែលចាំបាច់សម្រាប់មនុស្សគ្រប់រូប ។

### ២.១. ដ្យាក្រាមបកស្រាយពីអត្ថន័យបំណិនជីវិត



## ២.២. និយមន័យបំណិនជីវិត

**បំណិនជីវិត :** ជាសមត្ថភាព និង ទេពកោសល្យចាំបាច់ដែលធ្វើឱ្យជីវិតប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗទទួលបានជោគជ័យ និង មានផលិតភាពខ្ពស់ ។ សមត្ថភាព និង ទេពកោសល្យទាំងនោះរួមមាន :

**១. បំណិនមូលដ្ឋាន :** សំដៅលើកកម្ពស់បំណិនទូទៅផ្នែកសង្គម និង បំណិនចាំបាច់សម្រាប់រស់នៅប្រចាំថ្ងៃ ។

**ចំណេះដឹង :** ភាសា នព្វន្ត វិទ្យាសាស្រ្ត និង ព័ត៌មានទូទៅពាក់ព័ន្ធនឹងជីវិត ។

**បំណិនទូទៅ និង គុណភាពផ្ទាល់ខ្លួន :** ការប្រាស្រ័យទាក់ទង ការគិតដោយវិភាគ ការដោះស្រាយបញ្ហា ការធ្វើការសម្រេចចិត្ត អន្តរបុគ្គល ការឱ្យតម្លៃលើខ្លួនឯង ទំនុកចិត្តលើខ្លួនឯង ឥរិយាបថវិជ្ជមាន ជាដើម ។

**ការប្រតិបត្តិ និង បុរេវិជ្ជាជីវៈ** ការអនុវត្តជាក់ស្តែងចំពោះការងារប្រចាំថ្ងៃ និង សញ្ញាណវិជ្ជាជីវៈងាយៗ ។

**២. បំណិនអាជីព :** សម្តៅរកប្រាក់ចំណូល និង តម្រូវឱ្យមានការបណ្តុះបណ្តាលរយៈពេលវែង ។

**បំណិនគ្រប់គ្រងអាជីវកម្ម :** ការគ្រប់គ្រងមុខរបរ និង ការងារប្រកបដោយជោគជ័យ ។

**បំណិនបច្ចេកទេស :** ការអភិវឌ្ឍជំនាញជាក់លាក់ក្នុងការប្រកបមុខរបរ ឬ ការងារអ្វីមួយ ។

## ២.៣. ការកំណត់បំណិនមូលដ្ឋាន និង បំណិនអាជីព

| **បំណិនមូលដ្ឋាន** | | **បំណិនអាជីព** | |
|---|---|---|---|
| ចំណេះដឹង | • ភាសា<br>• គណិតវិទ្យា វិទ្យាសាស្រ្តអនុវត្ត...<br>• មេរោគអេដស៍ ផ្តាសាយបក្សី សុខភាព បន្តពូជ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរផ្លូវភេទ គ្រឿងញៀន...<br>• វប្បធម៌ ប្រវត្តិសាស្ត្រ...<br>• ចំណេះដឹងទាំងឡាយដែលទទួលបានតាមរយៈការសិក្សាស្រាវជ្រាវ ។ | **បំណិន គ្រប់គ្រង អាជីវកម្ម** | ជំនាញធ្វើផែនការ ការសម្រេចចិត្ត គំនិត ច្នៃប្រឌិត ការជឿជាក់ ការទទួលខុសត្រូវ គំនិតផ្តួចផ្តើម ការគ្រប់គ្រងពេលវេលា ការស្វែងរកទីផ្សារ ការកំណត់តម្លៃ សមត្ថភាពគ្រប់គ្រងប្រាក់ និង ធនធាន ជំនាញរដ្ឋបាល ទំនាក់ទំនង ការដកបទពិសោធន៍... ។ល ។ |
| **បំណិនទូទៅ និង គុណភាព ផ្ទាល់ខ្លួន** | • អន្តរបុគ្គល ទំនាក់ទំនង ការគិតល្អិតល្អន់ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ការធ្វើផែនការ និង កំណត់គោលដៅ | **បំណិន បច្ចេកទេស** | • **កសិកម្ម :** ការចិញ្ចឹមសត្វ ការដាំបន្លែ ការបណ្តុះពូជ ផលិតផលម្ហូបអាហារ ជាដើម ។ |

| | | | |
|---|---|---|---|
| | ការគ្រប់គ្រងពេលវេលា...<br>• អធ្យាស្រ័យល្អ ភាពអំណត់ ភាពស្មោះត្រង់ ឱ្យតម្លៃអ្នកដទៃ ការឱ្យតម្លៃខ្លួនឯង ទំនុកចិត្តលើខ្លួនឯង ឥរិយាបថវិជ្ជមានក្នុងការរស់នៅ ការទទួលខុសត្រូវ...។ | | • **សេវាកម្ម :** កាត់សក់ សម្អាងការ ភោជនីយដ្ឋាន សណ្ឋាគារ ទេសចរណ៍ ជាដើម ។<br>• **ឧស្សាហកម្ម :** តម្លើងយានយន្ត ឧស្សាហកម្មកាត់ដេរ រោងចក្រភេសជ្ជៈ កសិដ្ឋានកសិ-ឧស្សាហកម្ម ។ល។<br>• **កំណត់សំគាល់ :** បំណិនបច្ចេកទេសទាំងនេះអាចប្រើដើម្បីបង្កើតមុខរបរផ្ទាល់ខ្លួន ឬ មុខរបរទទួលកម្រៃ ។ |
| **ការប្រតិបត្តិ និង បុរេវិជ្ជាជីវៈ** | • ដេររប៉ាក់ ការងារក្នុងសួនច្បារ ដាំស្ល កាត់សក់ ការសម្អាតភូមិដ្ឋាន-ទីធ្លាសាធារណៈ ចិញ្ចឹមសត្វ... | | |
| **កំណត់សំគាល់ :** អាជីពខាងលើនេះអាចបង្រៀនដើម្បីអភិវឌ្ឍបំណិនមូលដ្ឋានដល់សិស្សបឋមសិក្សាផងដែរ ។ បញ្ហាសំខាន់គឺអាស្រ័យទៅលើការកំណត់គោលបំណង និង ការរៀបចំចាត់ចែងកម្មវិធីបំណិនជីវិតសម្រាប់ក្រុមមុខសញ្ញានីមួយៗប៉ុណ្ណោះ ។ | | | |

# ជំពូកទី ២ : ការអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

## ១. គោលការណ៍អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

- កម្មវិធីបំណិនជីវិតតាមមូលដ្ឋានត្រូវអភិវឌ្ឍឡើងដោយនាយកសាលា គ្រូបង្រៀន សិស្ស និង មាតាបិតានៅតាមសាលា ឬ កម្រងសាលា ។
- ការអនុវត្តកម្មវិធីបំណិនជីវិតនេះត្រូវឆ្លើយតបទៅនឹងតម្រូវការ និង ចំណង់ចំណូលចិត្តរៀនសូត្ររបស់សិស្ស និង មានខ្លឹមសារបំពេញបន្ថែមទៅនឹងកម្មវិធីសិក្សាជាតិ ជាពិសេសគឺជួយអ្នករៀនឱ្យទទួលបានចំណេះដឹង ចំណេះធ្វើ ឥរិយាបថល្អ និង រស់នៅជាមួយគ្នាដោយសុខដុមរមនា ។
- ផ្តល់ឱ្យសិស្សនូវបំណិន និង សមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាងាយៗ ដែលគេជួប ប្រទះ និងកើតមាននៅតាមមូលដ្ឋានក្នុងសហគមន៍របស់ពួកគេ ។
- ប្រើប្រាស់ធនធានដែលមាននៅតាមមូលដ្ឋាន ដូចជាមន្ត្រីជំនាញ អ្នកមានបទពិសោធន៍ អ្នកដែលទទួលជោគជ័យ ឬ បរាជ័យចំពោះបញ្ហាដែលសិស្សកំពុងសិក្សាកម្មវិធីបំណិនជីវិតនោះ ។

## ២. ការអភិវឌ្ឍកម្មវិធីសិក្សា

គោលបំណងរបស់កម្មវិធីគឺអភិវឌ្ឍ និង អនុវត្តបំណិនជីវិតតាមមូលដ្ឋានដែលចាំបាច់ ដើម្បីជួយឱ្យការរស់នៅប្រកបដោយផ្លែផ្កា និង សម្បូរសប្បាយតាមរយៈការអភិវឌ្ឍ និង ការអនុវត្តយុទ្ធសាស្ត្រដោះស្រាយបញ្ហានៅតាមមូលដ្ឋានរបស់ពួកគេ ។ កម្មវិធីបំណិនជីវិតត្រូវបានអភិវឌ្ឍតាមបែបការពិគ្រោះយោបល់ ដោយសិស្សចូលរួមក្នុងដំណើរការកំណត់បញ្ហា ដែលមាននៅក្នុងមូលដ្ឋានរបស់ពួកគេ បន្ទាប់មកធ្វើការជ្រើសរើសបញ្ហាអាទិភាពដែលគេជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ហើយចូលរួមក្នុងដំណើរការនៃការរៀន និង ដោះស្រាយបញ្ហាទាំងនេះ ។ កម្មវិធីនេះ រៀបចំឡើងដើម្បីឱ្យសិស្ស មានភាពម្ចាស់ការលើខ្លួនឯង ។ ការអនុវត្តដំណើរការនៃការរៀនដែលមាន ៦ ដំណាក់កាលសំដៅលើកកម្ពស់វិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌលដោយប្រើសកម្មភាពតាមបែបចូលរួមប្រកបដោយភាពសប្បាយរីករាយហើយមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងតម្រូវការរបស់សិស្ស និង បរិស្ថានជុំវិញរបស់ពួកគេ ។

| ការអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅកម្រងសាលារៀន | |
|---|---|
| **ការអភិវឌ្ឍប្រធានបទ** | **លំនាំនៃការបង្រៀន និង រៀន** |
| គ្រូ សិស្ស និង សហគមន៍ជាអ្នកកំណត់ខ្លឹមសារ ឬ ប្រធានបទដោយប្រើលំនាំដូចខាងក្រោម :<br>១. ការកំណត់បញ្ហាដែលសិស្សជួបប្រទះប្រចាំថ្ងៃ<br>២. ការកំណត់បញ្ហាអាទិភាពទាំងនោះ<br>នៅចុងបញ្ចប់គេបានកំណត់ប្រធានបទ សម្រាប់កម្មវិធី បំណិនជីវិតតាមមូលដ្ឋានដែលឆ្លើយតបទៅនឹងតម្រូវ ការ និង ចំណង់ចំណូលចិត្តរបស់សិស្សតាមកម្រិតថ្នាក់ នីមួយៗ( **ការកំណត់អាទិភាពបញ្ហាគួរចែកជាបីផ្នែកៈ ផ្នែកសង្គម ផ្នែកវប្បធម៌ប្រពៃណី និង ផ្នែក ការប្រតិបត្តិ-បុរេវិជ្ជាជីវៈ**) ។ | លំនាំនៃការសិក្សាទាំង ៦ ដំណាក់កាល ត្រូវអនុវត្តក្នុង ការបង្រៀនប្រធានបទទាំងអស់ ដែលបានកំណត់នៅក្នុង កម្មវិធីសិក្សារបស់កម្រងនីមួយៗ:<br>១. ការស្វែងយល់ពីប្រធានបទ<br>២. ការស្រង់ព័ត៌មានពីសហគមន៍<br>៣. ការវិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា<br>៤. ការអភិវឌ្ឍផែនការសកម្មភាពផ្សព្វផ្សាយ<br>៥. ការអនុវត្តផែនការផ្សព្វផ្សាយនៅតាមសហគមន៍<br>៦. ការឆ្លុះបញ្ចាំង និង វាយតម្លៃលើការផ្សព្វផ្សាយ |

**តារាងខាងលើនេះបញ្ជាក់បានថា នៅតាមកម្រងនីមួយៗ គេដឹងពីអ្វីដែលគេត្រូវបង្រៀន និង រៀន (សូមមើលលំអិតដំណាក់កាលទាំង ៦) ។ ការរៀនបែបនេះតម្រូវឱ្យសិស្សអនុវត្តជាក់ស្តែង និង ជួយឱ្យសិស្សអភិវឌ្ឍបំណិនទូទៅជាច្រើន។**

## ៣. ការគាំទ្រពីប្រព័ន្ធអប់រំ និង ការចូលរួម

នៅក្នុងរបត់ថ្មីនៃការកែទម្រង់រដ្ឋបាលសាធារណៈឆ្ពោះទៅរកការគ្រប់គ្រងបែបវិមជ្ឈការ តួនាទីរបស់មន្ត្រីពាក់ព័ន្ធនឹងមានការកែសម្រួលដើម្បីឆ្លើយតបទៅនឹងការវិវត្តនេះ ។ ការកំណត់តួនាទីខាងក្រោមនេះ នឹងផ្តល់ឱកាសដល់មូលដ្ឋានជាបណ្តើរៗក្នុងការទទួលខុសត្រូវលើការងារអប់រំ :

- ផ្អែកលើស្តង់ដាកម្មវិធីសិក្សា ដែលបានកំណត់ដោយក្រសួងអប់រំយុវជន និង កីឡា មូលដ្ឋានត្រូវរកគ្រប់មធ្យោបាយ ដើម្បីធ្វើឱ្យសិស្សម្នាក់ៗសម្រេចបានលទ្ធផលការសិក្សារបស់គេតាមកម្រិតថ្នាក់នីមួយៗ និង ធានាឱ្យពួកគេអាចបន្តការ សិក្សាទៅថ្នាក់លើទៀត ។

- ផ្អែកលើគោលនយោបាយកម្មវិធីបំណិនជីវិត ជាពិសេសការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន អាជ្ញាធរអប់រំអាចកៀងគរធនធាន ដែលមាននៅក្នុងមូលដ្ឋាន រៀបចំកម្មវិធីបំណិនជីវិតមួយដែលឆ្លើយតបទៅនឹងតម្រូវការ

រស់នៅប្រចាំថ្ងៃរបស់សិស្សតាមក្រុមអាយុរបស់គេ ។ (សូមមើលបន្ថែមគោលនយោបាយបំណិនជីវិត ២០០៦ ត្រង់ចំណុច *លេខ ៧.៣ ស្តីពីការទទួលខុសត្រូវ ការចូលរួម និង កិច្ចសហការ*) ។ តារាងខាងក្រោមបង្ហាញពីតួនាទីរបស់អ្នកពាក់ព័ន្ធក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាន។

| តួនាទីរបស់ក្រសួង/មន្ទីរ | តួនាទីរបស់មូលដ្ឋាន(អប់រំស្រុក នាយកសាលា គ្រូបង្រៀន សិស្ស) | ការគាំទ្រពីសហគមន៍ |
|---|---|---|
| o រៀបចំគោលនយោបាយ និងការណែនាំអនុវត្តច្បាស់លាស់<br>o ពិនិត្យតាមដានការអនុវត្ត និង កែលំអគោលនយោបាយ<br>o ទទួលសាទរនឹងគំនិតផ្តួចផ្តើមថ្មី នៅតាមមូលដ្ឋាន<br>o ប្រមូល និង ចែករំលែកបទពិសោធន៍ល្អៗពីមូលដ្ឋាន ។ | o ស្វែងយល់ពីតម្រូវការរៀនសូត្ររបស់សិស្ស<br>o ផ្តួចផ្តើមគំនិតថ្មី ដោយផ្អែកលើគោលនយោបាយរបស់ក្រសួង ជាពិសេស ស្តង់ដាកម្មវិធី និង បំណិនជីវិត<br>o បង្កលក្ខណៈឱ្យមានការរៀនសូត្រពិតប្រាកដ (ធ្វើសកម្មភាព និង គិតកម្រិតខ្ពស់)<br>o ស្រាវជ្រាវចងក្រងបទពិសោធន៍ល្អៗ<br>o ផ្តល់ព័ត៌មានត្រឡប់ជូនក្រសួង ។ | o ស្វែងរកការគាំទ្រពីគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ/សង្កាត់សម្រាប់សកម្មភាពសហគមន៍<br>o ចលនាការចូលរួមរបស់សហគមន៍ក្នុងការអប់រំ និង ការរៀបចំសាលាកុមារមេត្រី<br>o ផ្សារភ្ជាប់ទៅនឹងបណ្តាញផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពអប់រំ ។ |

# ជំពូកទី ៣ : របៀបរៀនរបស់កុមារ និង វិធីដឹកនាំសកម្មភាពរៀន

## ១. លំនាំផ្សេងៗនៃការរៀន

ជាទូទៅគេតែងតែគិតថាការរៀនកើតឡើងនៅតែក្នុងថ្នាក់រៀនតែប៉ុណ្ណោះ ដែលមានគ្រូជាអ្នកបង្រៀន និងសិស្សជាអ្នករៀន ។ តាមពិតការរៀនអាចមាននៅគ្រប់ទីកន្លែង ហើយបុគ្គលម្នាក់ៗមានរបៀបរៀនខុសៗគ្នា។ ខ្លះចូលចិត្តរៀនម្នាក់ឯងដោយស្ងៀមស្ងាត់ ឬ កំដរដោយចម្រៀង ខ្លះចូលចិត្តរៀនជាក្រុមដោយមានការពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ខ្លះចូលចិត្តរៀនតាមរយៈការសង្កេត និង វិភាគលើអ្វីដែលគេបានឃើញ ខ្លះចូលចិត្តរៀនដោយអនុវត្តជាក់ស្តែងតែម្តង ។ ល។ ប្រការទាំងនេះហើយ ដែលតម្រូវឱ្យគ្រូអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ដោយផ្លាស់ប្តូរបច្ចេកទេសបង្រៀនខុសៗគ្នា ពីមួយពេលទៅមួយពេល ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការ និង របៀបរៀនសូត្ររបស់សិស្សម្នាក់ៗ ។ លើសពីនេះទៀត ការបង្រៀនសិស្សឱ្យចេះរៀនដោយខ្លួនឯង នឹងធ្វើឱ្យការសិក្សាពោរពេញទៅដោយការចង់ចេះ ចង់ដឹងតាមរយៈការសួរសំណួរ ដែលមានការវិភាគ សន្និដ្ឋាន វាយតម្លៃ និង លើកកម្ពស់ការចែករំលែកបទពិសោធពីគ្នាទៅវិញទៅមក ។ យុទ្ធវិធីក្នុងការសិក្សាបែបនេះ ពេលខ្លះតម្រូវឱ្យគ្រូបង្រៀនរៀនពីសិស្ស និង បង្កើតទម្លាប់ឱ្យមានការស្រាវជ្រាវស្វែងយល់ និង រកដំណោះស្រាយចំពោះបញ្ហាដែលគេជួបប្រទះប្រចាំថ្ងៃ ។ ខាងក្រោមនេះជាដ្យាក្រាមបង្ហាញពីការរៀនដោយខ្លួនឯងរបស់សិស្សក្នុងការកសាងចំណេះដឹងថ្មី និង ចែករំលែកជាមួយអ្នកដទៃ។

**ការកសាង និង ប្រើប្រាស់ចំណេះដឹងថ្មីប្រកបដោយប្រសិទ្ធភាព**





កុមារីនេះរៀនជាបុគ្គល ដើម្បីស្វែងយល់ពីអត្ថបទអំណាន ធ្វើការគិត វិភាគ ប្រៀបធៀបទៅនឹងអ្វីដែលគេចេះ ព្រមទាំងធ្វើការសង្ខេបមុននឹងចែករំលែកឱ្យអ្នកដទៃ ។



កុមារនេះចែករំលែកអ្វី ដែលគេបានរៀនឱ្យទៅមិត្តភក្តិ តាមរយៈការពន្យល់ដោយមានអំណះអំណាង ព្រមទាំងរៀនស្តាប់ពីគ្នាទៅវិញទៅមក ។



កុមារទាំងនេះរៀនជាក្រុម ពិភាក្សាលើប្រធានបទអ្វីមួយ ដោយមានការចូលរួមពីសមាជិកទាំងអស់ ប្រកបដោយការទទួលខុសត្រូវ ។ ប្រការនេះធ្វើឱ្យសិស្សអភិវឌ្ឍបំណិនបានច្រើន ។



កុមារទាំងនេះកំពុងសម្តែងតួ។ ការអនុវត្តបែបនេះជាទម្រង់មួយដែលបង្ហាញពីការយល់ដឹង និង សមត្ថភាពរបស់សិស្សចំពោះការសិក្សា។ តាមរយៈការសម្តែងនេះ កុមារអភិវឌ្ឍនូវ ទំនុកចិត្ត និង ការឱ្យតម្លៃលើខ្លួនឯង និង បំណិនសង្គមដទៃទៀតដែរ។



កុមារទាំងនេះរៀន តាមរយៈការណែនាំពីគ្រូមុនចាប់ផ្តើមធ្វើកិច្ចការ ។ ការស្វែងយល់ការណែនាំពីគ្រូឱ្យបានច្បាស់លាស់ អាចជួយឱ្យពួកគេធ្វើការប្រកបដោយប្រសិទ្ធភាព ។



កុមារទាំងនេះរៀនដោយអនុវត្តផ្ទាល់ ។ ការអនុវត្តផ្ទាល់ជួយឱ្យពួកគេទទួលបាននូវបទពិសោធន៍ ជាក់ស្តែង ព្រមទាំងធ្វើឱ្យចំណេះដឹងរបស់ពួកគេកាន់តែរឹងមាំ និង ចងចាំបានយូរ ។



កុមារទាំងនេះរៀនតាមរយៈការបង្ហាញលទ្ធផល ដែលគេបានពិភាក្សា ឬ ស្រាវជ្រាវពីអ្វីមួយនៅក្នុង ថ្នាក់ ។ ប្រការនេះជួយឱ្យកុមារមិនត្រឹមតែទទួលបានចំណេះដឹងប៉ុណ្ណោះទេ គេថែមទាំងអាចបង្ហាញពីអ្វីដែលគេបានរៀនឱ្យដល់មិត្តភក្តិរបស់គេទៀតផង ។



កុមារទាំងនេះរៀនតាមរយៈការបង្ហាញលទ្ធផលដែលគេសម្រេចបានដល់សហគមន៍ ។ ប្រការនេះធ្វើឱ្យការសិក្សារបស់គេផ្សារភ្ជាប់ទៅនឹងសហគមន៍ និង ធ្វើឱ្យសហគមន៍ចាប់អារម្មណ៍ និង គាំទ្រដល់ការអប់រំ ។

## ២. ល្បិចក្នុងការរៀបចំសកម្មភាពបង្រៀន និង រៀន[១]

### ២.១. ការរៀនបែបសកម្ម

ការរៀនគឺជាការស្វែងយល់ឱ្យបានស៊ីជម្រៅលើបញ្ញត្តិ បំណិន និង ឥរិយាបថ ដើម្បីបង្កើនការយល់ពីខ្លួនឯង អ្នកដទៃ និង បរិស្ថានជុំវិញ ។ ចំពោះកុមារ ការស្វែងយល់ស៊ីជម្រៅនេះ ជាលំនាំសកម្មមួយ រួមមាន ***បទពិសោធន៍ អន្តរកម្ម ការឆ្លុះបញ្ចាំង និង ទំនាក់ទំនង*** ។ តាមរយៈបទពិសោធន៍ជាក់ស្តែងវិធីរៀនបែបនេះអាចធ្វើឱ្យកុមារដែលមិនទាន់ចេះ គិតពីអរូបីអាចចាប់ផ្តើមរៀនបានល្អប្រសើរ ។ កុមារទទួលបានការយល់ដឹងពីពិភពខាងក្រៅនៅពេលដែលពួកគេមានទំនាក់ទំនងជាមួយបរិស្ថាន ធម្មជាតិ និង បរិស្ថានសង្គម ។ ***ការរៀនរបស់កុមារនឹងមានប្រសិទ្ធភាព នៅពេលដែលការរៀននោះផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង ប៉ុន្តែបើមានតែការអនុវត្តវាក៏មិនគ្រប់គ្រាន់ក្នុងការអភិវឌ្ឍសមត្ថភាព និង បំណិនរបស់កុមារដែរ ។ ដូចនេះដើម្បីឱ្យកុមារទទួលបាននូវសមត្ថភាព និង ចំណេះដឹងពិតប្រាកដលើអ្វីដែលគេបានរៀន លុះត្រាតែកុមារអាចរៀបរាប់ បកស្រាយ និង បង្ហាញបាននូវការយល់ឃើញដោយ ខ្លួនឯង*** ។ លើសពីនេះទៀត ដើម្បីធ្វើឱ្យចំណេះដឹងរបស់ពួកគេកាន់តែរីកចំរើន ពួកគេចាំបាច់ត្រូវតែចែករំលែក ហើយ ទទួលយកការពិភាក្សាដេញដោលពីអ្នកដទៃ ។ **បទពិសោធន៍ អន្តរកម្ម ការឆ្លុះបញ្ចាំង និង ការទំនាក់ទំនង** ទាំងអស់ នេះគឺជាសមាសភាពនៃ **ការរៀនបែបសកម្ម** ។

ម៉្យាងទៀតកុមារត្រូវការដកស្រង់បទពិសោធន៍ផ្ទាល់ ជាមួយនឹងឱកាសនៃការរៀនសូត្រទាំងឡាយ ដើម្បីឱ្យពួកគេទទួលបាននូវចំណេះដឹង និង បទពិសោធន៍ពិតប្រាកដ ព្រមទាំងពិចារណាបានល្អិតល្អន់ និង បង្កើតទំនាក់ទំនងទៅនឹងបទពិសោធន៍ទាំងនោះ ។ លំនាំនេះធ្វើឱ្យពួកគេទទួលបានការយល់ដឹងច្រើនពីបទពិសោធន៍នៃការរៀនសូត្ររបស់ពួកគេ ។ ដូចនេះការបង្កើត និង ការរៀបចំបរិស្ថានថ្នាក់រៀនមួយឱ្យមានលក្ខណៈជាការរៀនសកម្ម វាជាតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនដែលត្រូវផ្តោតការយកចិត្តទុកដាក់ជាចម្បង ។

#### ***ទិដ្ឋភាពនៃការរៀនបែបសកម្ម***



1. អនុញ្ញាតឱ្យកុមារប្រើចំណេះដឹងដែលមានស្រាប់ ។
2. ត្រូវរៀបចំឱ្យមានសណ្តាប់ធ្នាប់ និង រចនាសម្ព័ន្ធការងារឱ្យបានល្អ ដើម្បីឱ្យកុមារអាច សង្កេត និង ប្រមូលយកព័ត៌មានបានត្រឹមត្រូវ ។
3. ផ្តល់ឱកាសសម្រាប់ធ្វើការឆ្លុះបញ្ចាំងឡើងវិញ និង ធ្វើទំនាក់ទំនង ។
4. ទទួលយកការឆ្លើយតបរបស់សិស្ស ដែលមានកម្រិតខុសៗគ្នា ។
5. តម្រូវឱ្យកុមារធ្វើការសម្រេចចិត្ត និង ពិនិត្យកំហុសសម្រាប់ធ្វើការកែលំអនាពេលអនាគត ។
6. អនុញ្ញាតឱ្យកុមារប្រមូលព័ត៌មានត្រឡប់ និង វាយតម្លៃការសិក្សា ។

[១] *ដកស្រង់ចេញពីសៀវភៅសាលាកុមារមេត្រីរបស់អង្គការ IBO*

## ២.២. ការរៀនបែបអន្តរកម្ម

ការរៀនបែបអន្តរកម្មគឺការរៀនដែលមានទំនាក់ទំនងទៅវិញទៅមកជាមួយមនុស្ស និង វត្ថុដែលនៅជុំវិញ ។ ជាទូទៅកុមារតែងចង់ដឹង ចង់ឃើញ ឆ្ងល់ហើយសួរ ។ ពួកគេប្រើវិញ្ញាណទាំងអស់របស់ពួកគេ ដើម្បីកាន់មើល និង ពិនិត្យវត្ថុទាំងនេះ ។ ការបង្រៀនវិទ្យាសាស្ត្រគ្រូត្រូវឱ្យសិស្សទាំងអស់មានអន្តរកម្ម ប្រើប្រាស់ កាន់វត្ថុទាំងនោះ ដើម្បីសង្កេត និង សិក្សា។ នៅពេលធ្វើពិសោធ ពិនិត្យ ស្រាវជ្រាវ ជាមួយវត្ថុផ្សេងៗ សិស្សនឹងទទួលបាន ចំណេះដឹងដ៏ទូលំទូលាយ ។ លោក Piaget បាន បញ្ជាក់ថា ប្រភេទនៃការរៀននេះជា ***ចំណេះដឹងលើរូបធាតុ*** ។ នៅក្នុងន័យគណិតវិទ្យា យើងឱ្យសិស្សដាក់វត្ថុទាំងអស់បញ្ចូលគ្នាទៅតាមរបៀបផ្សេងៗ ដើម្បីរកឱ្យឃើញនូវទំនាក់ទំនងរបស់វា។ **ឧទាហរណ៍** : ពេលសិស្សចែកជាក្រុម និង ធ្វើចំណាត់ថ្នាក់ ពេលនោះគឺពួកគេបានរៀនពីទំនាក់ទំនងរួចទៅហើយ ។



ការស្វែងយល់វត្ថុដោយផ្ទាល់មានសារៈសំខាន់ណាស់សម្រាប់កុមារតូចៗ ពីព្រោះលោក Piaget បានសរសេរ ថា ***កុមារតូចៗគិតបានល្អពេលដែលពួកគេចាប់កាន់ និង ធ្វើអំពើទៅលើវត្ថុដោយផ្ទាល់*** ។ ការផ្តល់ឱកាសដល់អ្នករៀនជាប្រការចាំបាច់បំផុត ដើម្បីឱ្យពួកគេមានអន្តរកម្មជាមួយសម្ភារ និងវត្ថុផ្សេងៗមុននឹងក្លាយទៅជាអ្នកដោះស្រាយបញ្ហា ។ ***ការលើក ទឹកចិត្តកុមារដើម្បីឱ្យក្លាយជាអ្នកដោះស្រាយបញ្ហាដោយខ្លួនឯង គឺវាមានប្រសិទ្ធភាពជាងការដែលយើងប្រាប់ពួកគេនូវរបៀបដោះស្រាយ បញ្ហា*** ។ ពេលដែលយើងប៉ាន់ស្មាន និង វាយតម្លៃទៅលើអ្នករៀន យើងចាំបាច់ត្រូវឱ្យតម្លៃទៅលើរបៀបដែលអ្នករៀនមានអន្តរកម្មជាមួយវត្ថុនៅជុំវិញខ្លួនពួកគេ ។ អន្តរកម្មជាមួយមនុស្ស វាជាផ្នែកមួយនៃការរៀនបែបសកម្ម និង បែបអន្តរកម្ម ។ យើងជាគ្រូបង្រៀនគួរតែលើកទឹកចិត្តដល់ អ្នករៀនឱ្យចេះធ្វើពិសោធ និង យល់ដឹងពីបំណិននៃការសហការគ្នា ។ ប្រការនេះជម្រុញឱ្យមានការអភិវឌ្ឍបំណិន ខាងសង្គម ។ ដូចនេះ ***ដើម្បីលើកទឹកចិត្តអ្នករៀនចេះគិត និង ចេះស្វែងយល់ ឱ្យបានស៊ីជម្រៅយើងត្រូវផ្តល់ឱកាស ឱ្យអ្នករៀន ដោយបង្កើតស្ថានភាពមួយដែលមានន័យសម្រាប់គេ ។ អ្នករៀនធ្វើការសម្រេចចិត្តហើយ ផ្លាស់ប្តូរទស្សនៈ ជាមួយអ្នកដទៃ*** ។



## ២.៣. ការរៀនបែបសហការ

**តើការរៀនបែបសហការជាអ្វី ?**

- ការរៀនតាមបែបសហការគឺជាសកម្មភាពរៀនមួយ ដែលប្រើដើម្បីរៀបរាប់ពីវិធីមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់ឱ្យសិស្សធ្វើការជាមួយគ្នាដើម្បីរៀន ។
- គ្រូបង្រៀនផ្តល់ឱកាសដើម្បីឱ្យសិស្សធ្វើការងារជាក្រុមរួមគ្នា ។ តាមការស្រាវជ្រាវបានបង្ហាញថា នៅពេលសិស្សធ្វើការងារជាក្រុម ដោយមានការសហការគ្នានោះអាចធ្វើឱ្យសិស្សសំរេចបានវត្ថុបំណងសំខាន់ៗមួយចំនួននៃការរៀន។
- សិស្សយល់ពីតម្លៃខ្លួនឯង មានអាកប្បកិរិយាល្អចំពោះអ្នកដទៃ ហើយលទ្ធផលនៃការសិក្សារបស់សិស្សម្នាក់ៗកាន់តែខ្ពស់។
- សិស្សមានឥរិយាបថវិជ្ជមានទៅកាន់អ្នកដទៃ ទោះបីអ្នកដទៃមានឥរិយាបថផ្សេងខុសពីខ្លួនគេក៏ដោយ ។
- សិស្សទទួលបានលទ្ធផលសិក្សាខ្ពស់ ។ លទ្ធផលស្រាវជ្រាវបានបញ្ជាក់ប្រាប់ ថា លំនាំនៃការពិភាក្សានៅក្នុងក្រុមអាចលើកកម្ពស់ទំនាក់ទំនងក្នុងការរៀនរបស់សិស្ស ព្រោះក្នុងពេលក្នុងពេលពិភាក្សាតែងមានខ្វែងគំនិត យោបល់ សន្និដ្ឋាន ទ្រឹស្តី និង ព័ត៌មានគ្នា។ ដូចនេះតាមរយៈការពិភាក្សាសិស្សអាចវិះរកគំនិតរួម បញ្ជាក់ពីគំនិតទាំងនោះ ហើយអាចបញ្ច្រាបចំណេះដឹងទៅតាមរបៀបផ្ទាល់ខ្លួនរបស់គេម្នាក់ៗ ហើយសិស្សអាចបង្កើតគំនិតដែលចេញពីការគិត ដោយខ្លួន គេផ្ទាល់ ។

**ហេតុអ្វីបានជាការរៀនតាមបែបសហការវាមានសារៈសំខាន់?**

ការមានសមត្ថភាពចូលរួមរៀនជាមួយអ្នកដទៃគឺជាគន្លឹះមួយដើម្បីអភិវឌ្ឍក្នុងការ រក្សាមិត្តភាព ទទួលបានភាពស្និទ្ធស្នាលនៅក្នុងគ្រួសារ មានទំនាក់ទំនងដែលទទួលបានជោគជ័យ មានភាពត្រូវរ៉ូវគ្នាជាមួយមិត្តរួមការងារសហសេវិក និង អភិវឌ្ឍសហគមន៍មួយ ដែលចេះយកអាសារគ្នា ។ ជាក់ស្តែងដើម្បីបង្កើនន្ទូវសមត្ថភាពរបស់កុមារឱ្យមានការសហការគ្នាគឺយើងត្រូវផ្តល់ពេលវេលាសម្រាប់កុមារ ដោយឱ្យពួកគេធ្វើការរួមគ្នាជាក្រុម ហើយបង្រៀនពួកគេពីបំណិនដែលពួកគេត្រូវការដើម្បីធ្វើការជាក្រុមតូចប្រកបដោយប្រសិទ្ធភាព ។ ការរៀនបែបសហការជាក្រុមបានផ្តល់ជាមធ្យោបាយល្អសម្រាប់កុមារដើម្បីឱ្យពួកគេ ធ្វើការដោះស្រាយបញ្ហាជាមួយគ្នា និង ជួយកុមារដែលមានការ ខ្វះខាតផ្នែកទំនាក់ទំនងនៅក្នុងសង្គមឱ្យមានការរីកចំរើនឡើង ។

## ២.៤. ការរៀនជាក្រុម

**ហេតុអ្វីបានជាការរៀនជាក្រុម  គឺជាការអនុវត្តដ៏ល្អមួយ?**

ការធ្វើការជាក្រុមអនុញ្ញាតឱ្យកុមារជាច្រើនមានអន្តរកម្ម និង ចូលរួមក្នុងលំនាំនៃការរៀន បើធៀបទៅនឹងការរៀនក្រោមការដឹកនាំដោយផ្ទាល់របស់គ្រូបង្រៀន ។ ការចែកជាក្រុមបួននាក់ សិស្សមួយភាគបួននៅក្នុងថ្នាក់រៀននឹងនិយាយ ហើយបីភាគបួននឹងស្តាប់ បើចែកសិស្សជាក្រុមពីរនាក់ សិស្សពាក់កណ្តាលថ្នាក់នឹងនិយាយនៅពេលតែមួយ ។ ការរៀនបែបគ្រូមជ្ឈមណ្ឌល សិស្សចាំតែឆ្លើយនឹងសំណួររបស់គ្រូប៉ុណ្ណោះ ។

**ប្រភេទនៃក្រុម** : កុមារអាចបង្កើតជាក្រុមតាមសមត្ថភាពចំណាប់អារម្មណ៍ ស្ថានភាពសង្គម យេនឌ័រ រាប់លេខ ។ល ។ ចំពោះការរៀនបែបសហការ ការរៀបចំក្រុមឱ្យមានសមត្ថភាពចម្រុះនោះមានលក្ខណៈប្រសើរបំផុត ។ សិស្សពូកែ ចេះជួយសិស្សខ្សោយ ។ ពួកគេបញ្ជាក់នូវការយល់ដឹងរបស់ខ្លួន និង ការយល់ដឹងដែលទទួលបានពីអ្នកដទៃមុននឹងបញ្ជូនបន្តទៅឱ្យអ្នកដទៃ ។

**ការធ្វើការងារជាក្រុមផ្តល់ឱកាសដើម្បីឱ្យកុមារ :**



- មានការរំភើបចំពោះទស្សនៈ អារម្មណ៍ និង សុវត្ថិភាពអ្នកដទៃ ។
- មានការរីកចម្រើនបំណិនផ្នែកទំនាក់ទំនង ។
- ទទួលបានបទពិសោធក្នុងការធ្វើផែនការ ការរៀបចំ ការធ្វើសេចក្តីសម្រេចចិត្ត និង ការដោះស្រាយបញ្ហា ។
- ឆ្លងបទពិសោធនគ្នាទៅវិញទៅមក ។
- ចែករំលែកគំនិត ព័ត៌មាន អារម្មណ៍ និង សមិទ្ធផលជាមួយគ្នា ។
- បញ្ជាក់ កែសម្រួលឡើងវិញ និង ពង្រឹងការរៀនតាមរយៈការពិភាក្សា ។
- អភិវឌ្ឍទំនាក់ទំនងល្អជាមួយមិត្តភក្តិ ។

គ្រូអាចបង្កើតក្រុមសិស្សសម្រាប់ធ្វើកិច្ចការទៅតាមស្ថានភាពដោយប្រើលក្ខណៈវិនិច្ឆ័យផ្សេងពីនេះ ប៉ុន្តែវាតម្រូវឱ្យមានការផ្លាស់ប្តូរសមាជិកក្រុមជាញឹកញាប់ ដើម្បីឱ្យសិស្សមានឱកាសធ្វើការជាមួយមិត្តរួមថ្នាក់បានច្រើន ។







**របៀបធ្វើឱ្យការងារក្រុមទទួលបានជោគជ័យ ៖**

វាមានសារៈសំខាន់ណាស់ ក្នុងការរៀបចំការណែនាំសម្រាប់ការងារក្រុមដល់សិស្ស ។ ការណែនាំនេះ គួរតែបិទនៅក្នុងថ្នាក់រៀន ដែលជាគោលការណ៍មួយដើម្បីធ្វើឱ្យការងារក្រុមទទួលបានជោគជ័យ ។

- ប្តូរវេនគ្នាក្នុងការបញ្ចេញមតិ យោបល់ ឬ តួនាទីក្នុងក្រុម
- ផ្តល់ការលើកទឹកចិត្តដល់គ្នាទៅវិញទៅមក
- សួរយោបល់ក្រុមដោយ មិនមានការអត្តនោម័ត
- សុំឱ្យក្រុមរបស់ពួកគេបញ្ជាក់ឡើងវិញ ពេលដែលពួកគេមិនយល់
- ជួយគ្នាទៅវិញទៅមក
- ស្តាប់អ្នកដទៃ ពេលដែគេកំពុងនិយាយ
- អញ្ជើញអ្នកដទៃ ឱ្យមកផ្តល់យោបល់
- ចែករំលែកសម្ភារៈគ្នាប្រើ
- មិនយល់ស្របជាមួយគំនិតគេ ប៉ុន្តែមិនមាក់ងាយគេឡើយ
- ធ្វើឱ្យក្រុមមានដំណើរការល្អ
- ប្រើភាសា កាយវិការប្រកបដោយភាពវិជ្ជមាន
- ធានាថាសមាជិកគ្រប់រូបមានឱកាសបានផ្តល់គំនិត និង យោបល់ ។ល។

## ២.៥. ការអភិវឌ្ឍបំណិននៃការគិត

**ការបង្រៀនកុមារឱ្យចេះគិត ៖** ដើម្បីឱ្យកុមាររៀនគិត ពួកគេចាំ បាច់ត្រូវចេះពី ៖

- របៀបវាយតម្លៃស្ថានភាព
- របៀបផ្តុះបញ្ចាំងទៅលើទិដ្ឋភាពសំខាន់ៗ
- របៀបសម្រេចចិត្តធ្វើអ្វីមួយ
- របៀបចាប់ផ្តើមធ្វើអ្វីមួយ ។

ប្រការសំខាន់បំផុតនោះគឺពួកគេចាំបាច់ត្រូវមានការពិសោធជាក់ស្តែង ដែលនឹងផ្តល់ឱកាសក្នុងការគិត ។ គ្រូអាចផ្តល់ឱ្យសិស្សទទួលបានបទពិសោធន៍ជាក់ស្តែងតាមរយការៈ

- សំណួរបើក "**ហេតុអ្វី ? អ្វីខ្លះ ? ដូចម្តេច?**" ចំពោះកិច្ចការ សកម្មភាព និង រឿងរ៉ាវដែលគេបានជួបប្រទះ ។
- ឱ្យកុមារផ្ទួរផ្តងព័តិមាន ប្រៀបធៀបទិន្នន័យជាមួយអ្វីដែលពួកគេបានចេះរួចមកហើយ ។ ការធ្វើបែបនេះអាចជួយពួកគេឱ្យរកឃើញនូវទំនាក់ទំនងរវាងពាក្យ និង បញ្ញត្តិ ដោយប្រើសំណួរដូចជា៖
    - o **តើវាមានលក្ខណៈរួមអ្វីខ្លះ ?**
    - o **តើវាមានភាពខុសគ្នាយ៉ាងដូចម្តេច?**

- ធ្វើចំណាត់ថ្នាក់វត្ថុ គំនិត និង ព័ត៌មាន ។ការធ្វើចំណាត់ថ្នាក់នេះជួយពួកគេឱ្យចាំនូវហេតុការណ៍បានល្អ ។
- បង្ហាញពី**ការគិតដោយវិភាគ** (លទ្ធភាពដើម្បីវាយតម្លៃព័ត៌មាន) ។
- ការរៀនដោយប្រើប្រាស់រូបបារម្មណ៍ និង ការរៀនដោយប្រេវិញ្ញាណទាំងប្រាំ ។ លំនាំនេះត្រូវត្រូវមានវត្ថុទីកន្លែង និង ពេលវេលាពិតសម្រាប់ឱ្យសិស្សសិក្សា ។ ឧទាហរណ៍ៈ ឃើញ ប៉ះ ភ្លក់របស់ដែលត្រជាក់ដើម្បីផ្តល់ឱកាសដល់កុមារបានអនុវត្តដោយផ្ទាល់ ។ រូបបារម្មណ៍ដែលបង្កើតដោយវិញ្ញាណអាចជួយដល់កុមារក្នុងការរក្សាទុកនូវព័ត៌មាន និង មានការរចងចាំបានយូរ ។
- ផ្តល់ឧបករណ៍ងាយៗដល់កុមារ ហើយបង្រៀនពីវិធីអនុវត្តដល់ពួកគេ ។ ឧទាហរណ៍ ៖ របៀបមើលផែនទី របៀប ដោះស្រាយលំហាត់គណិតវិទ្យា របៀបសរសេរសំបុត្រ ។ល ។
- លើកទឹកចិត្តជាប្រចាំចំពោះសំណេរផ្ទាល់ខ្លួនដូចជាៈ កាសែត ទស្សនាវដ្តី កំណាព្យ រឿង បំណកស្រាយសេចក្តីអធិប្បាយនៃការពិសោធ ការសរសេរសំបុត្រ ព្រោះដំណើរ ការបញ្ចេញ គំនិតនៅលើក្រដាសបង្ខំឱ្យអ្នក សរសេររៀបចំគំនិតរបស់ពួកគេបានត្រឹមត្រូវ ។
- បង្រៀនកុមារឱ្យលើសពីអ្វីដែលពួកគេបានរៀន ដោយដាក់ពួកគេនៅក្នុងស្ថានភាពមនុស្ស ដែលពួកគេកំពុងរៀន តាមរយៈសួរសំណួរថាៈ

*ក.* *តើពួកគេមានអារម្មណ៍យ៉ាងណា*

*ខ.* *តើពួកគេកំពុងធ្វើអ្វី? ស្លៀកពាក់អ្វី? ញ៉ាំអ្វី ?*

*គ.* *ប្រសិនបើ........... តើ........... ?*

*ឃ.* *សរសេរសំបុត្រមួយច្បាប់ទៅកាន់មិត្តម្នាក់ ឬគ្រួសាររបស់អ្នក អំពីអ្វីដែលនឹងកើតឡើងចំពោះរូបអ្នក ។*



**បង្រៀនកុមារឱ្យចេះសួរនូវសំណួរបួនខាងក្រោមអំពីអ្វីដែលពួកគេបានឮ ឬ អ្វីដែលពួកគេបានអាន ៖**

ក. តើវាខុសប្លែកពីធម្មតាដូចម្តេចខ្លះ ?

ខ. តើអ្វីខ្លះជាចំណេះដឹងសកលឬ ? ( ឧទាហរណ៍ៈ មេឃតែងតែពណ៌ខៀវ ) ។

គ. ប្រសិនបើមិនសកល តើមានភស្តុតាងអ្វីដើម្បីគាំទ្រនូវពាក្យពោលទាំងនេះ ?

ឃ. ប្រសិនបើមានភស្តុតាង តើវាអាចយកជាការបានឬទេ ?

ប្រសិនបើភស្តុតាងមិនអាចយកជាការបាន ពួកគេគួរតែរៀនបដិសេធមិនយល់ស្របនឹងពាក្យពោលទាំងនោះ ។

**បង្រៀនបំណិនដោះស្រាយបញ្ហា :** នេះគឺជាវិធីមួយ :

ក. តើពួកគេបានដឹងអ្វីខ្លះពីបញ្ហានោះ ? តើវាជាបញ្ហារបស់នរណា ?

ខ. តើពួកគេមិនបានដឹងពីអ្វីខ្លះ?

គ. តើត្រូវធ្វើអ្វីខ្លះ ? តើលទ្ធផលអ្វីដែលពួកគេចង់បាន ?

ឃ. បំផុសរាល់ដំណោះស្រាយដែលអាចធ្វើទៅបានតាមវិធីផ្សេងៗ ។

ង. វាយតម្លៃពីផលល្អ និងផលអាក្រក់ដើម្បីរៀបចំដោះស្រាយបញ្ហា ។

ច. អនុវត្តនូវផែនការ

ជ. វាយតម្លៃលទ្ធផល ។ តើផែនការដំណើរការឬទេ? ប្រសិនបើមិនដំណើរការ ចូរពិចារណារកដំណោះស្រាយមួយផ្សេងទៀត ។

ឈ. ប្រសិនបើផែនការដំណើរការនោះ បញ្ហាអាចដោះស្រាយបានដោយជោគជ័យ ។

**ខាងក្រោមនេះជាគោលវិធីក្នុងការដោះស្រាយបញ្ហាងាយមួយ :**

<u>ជំហានដោះស្រាយបញ្ហា</u>

ជំហានទី 1 : តើអ្នកគិតថាអ្វីជាបញ្ហា ? ហេតុអ្វី ?

ជំហានទី 2 : តើអ្នកគិតថាអ្នកគួរតែធ្វើអ្វី ? បង្កើតគំនិតចំនួនបី ។

ជំហានទី 3 : ជ្រើសរើសគំនិតមួយ ។ រួចប្រាប់ថាហេតុអ្វីបានជាអ្នកជ្រើសរើសវា? ពន្យល់ពីលក្ខណៈវិនិច្ឆ័យរបស់អ្នក ។



## ៣. លំនាំនៃការបង្រៀន និង រៀន

| គម្រោងអភិវឌ្ឍមេរៀនបំណិនជីវិតតាមលំនាំដំណាក់កាលទាំង ៦ | | | | |
|---|---|---|---|---|
| ឈ្មោះដំណាក់កាល | ប្រភេទសកម្មភាព | ចំណេះដឹង និង បំណិន ដែលបានអភិវឌ្ឍ | ធនធាន/ សម្ភារ ចាំបាច់ | រយៈពេល |
| **១.ការស្វែងយល់ពីប្រធានបទ**<br>**គោលបំណង :** កំណត់បាននូវអ្វីដែលសិស្សចេះស្រាប់ និង មធ្យោបាយនានាដើម្បីបង្កើនចំណេះដឹងរបស់សិស្សចំពោះប្រធានបទដែលបានជ្រើសរើស ។ | • បំផុសសំនួរលើចំណេះដឹងមានស្រាប់<br>• អញ្ជើញអ្នកជំនាញមកធ្វើបទឧទ្ទេស( អ្នកមានចំណេះដឹង បទពិសោធន៍ស្របតាមប្រធានបទ)<br>• ការអានឯកសារ ( នៅបណ្ណាល័យ/សហគមន៍)<br>• ការប្រើករណីសិក្សា | • ជំនាញស្រាវជ្រាវ<br>• ជំនាញទំនាក់ទំនង<br>• ជំនាញរៀបចំចាត់ចែង<br>• ជំនាញនៃការបង្ហាញ<br>• ចំណេះដឹងលើប្រធានបទ<br>• ម្ចាស់ការលើខ្លួនឯង<br>• សមត្ថភាពស្តាប់អាន<br>• វិភាគ | • ធនធានមនុស្ស<br>• ឯកសារពាក់ព័ន្ធប្រធានបទ | ២ម៉ោង |
| **២. ការស្រង់ព័ត៌មានពីសហគមន៍**<br>**គោលបំណង:** បង្កើតឧបករណ៍ និង ចុះប្រមូលព័ត៌មានពីសហគមន៍ដែលអាចឱ្យសិស្សវាយតម្លៃការយល់ដឹង និង ឥរិយាបថរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស ។ | o បង្កើតកម្រងសំណួរ<br>o ការត្រៀមសម្ភាស<br>o ការសម្ភាសន៍ជាក់ស្តែង<br>o ការធ្វើរបាយការណ៍ | o ជំនាញស្រាវជ្រាវ<br>o ជំនាញទំនាក់ទំនង<br>o ជំនាញអន្តរបុគ្គល<br>o ចំណេះដឹងលើប្រធានបទ<br>o ម្ចាស់ការលើខ្លួនឯង<br>o ទំនុកចិត្តលើខ្លួនឯង<br>o សមត្ថភាពសរសេរ | o សៀវភៅ<br>o សិស្ស ប៊ិច ខ្មៅដៃ | ៨ ម៉ោង |
| **៣. ការវិភាគព័ត៌មាន ដោយប្រើដើមឈើបញ្ហា**<br>**គោលបំណង:** ប្រើប្រាស់ព័ត៌មានដែលប្រមូល បានដើម្បីវិភាគបញ្ហាសំខាន់ៗ ដូចជាមូលហេតុ ផលវិបាក និងដំណោះស្រាយចំពោះបញ្ហានោះដោយប្រើដំណើរការវិភាគដើមឈើបញ្ហា ។ | o បង្ហាញពីលទ្ធផលស្រាវជ្រាវ<br>o វិភាគដើមឈើបញ្ហា<br>o កំណត់យកដំណោះស្រាយ និង សង្ខេបខ្លឹមសារចងក្រងជាមេរៀនជីវិត | o សមត្ថភាពនិយាយ<br>o ជំនាញក្នុងការវិភាគ<br>o ជំនាញការគិតដោយវិភាគ<br>o ជំនាញដោះស្រាយបញ្ហា<br>o ជំនាញក្នុងការបង្ហាញ<br>o ទំនុកចិត្តលើខ្លួនឯង<br>o ការអប់រំខ្លួនឯង<br>o ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា | o ក្រដាសផ្ទាំងធំ<br>o ប៊ិចហ្វឺត<br>o ប័ណ្ណតូចៗ<br>o កន្ត្រៃ<br>o ស្កុត | ២ម៉ោង |
| **៤.ការអភិវឌ្ឍផែនការសកម្មភាពផ្សព្វផ្សាយ**<br>**គោលបំណង :** កំណត់ដំណោះ | o ការជ្រើសរើសយកដំណោះស្រាយ<br>o រៀបចំផែនការសកម្មភាព | o ជំនាញធ្វើការសម្រេចចិត្ត<br>o ជំនាញក្នុងការធ្វើចំណាត់ថ្នាក់<br>o ជំនាញក្នុងការធ្វើផែនការ | • ក្រដាសផ្ទាំងធំ<br>• ប៊ិចហ្វឺត<br>• ប័ណ្ណតូចៗ | ២ ម៉ោង |

| | | | | |
|---|---|---|---|---|
| ស្រាយដែលអាចអនុវត្តជាក់ស្តែង (មួយ ឬ ច្រើន) ដើម្បីដោះស្រាយបញ្ហា និង កសាងផែនការសម្រាប់អនុវត្ត ។ | ផ្សព្វផ្សាយដល់សហគមន៍ (រួមមាន ល្បែង សរសេររឿង សម្តែងតួ ។ល។)<br>o បង្ហាញផែនការ និង ហ្វឹកហាត់<br>o ការរៀបចំសម្ភារ | o ជំនាញធ្វើការងារជាក្រុម<br>o ចំណេះដឹងបានមកពីការចូលរួមធ្វើផែនការ<br>o ទំនុកចិត្តលើខ្លួនឯង<br>o ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា | • កន្ត្រៃ<br>• ស្កុត | |
| **៥. ការអនុវត្តផែនការនៅតាមសហគមន៍**<br>**គោលបំណង :** សិស្សមានសមត្ថភាពអនុវត្តតាមដំណោះស្រាយដែលគេជ្រើសរើសជាទម្រង់សកម្មភាពផ្សព្វផ្សាយ និង ចូលរួមដើម្បីដោះស្រាយបញ្ហា ដែលមាននៅតាមមូលដ្ឋាន ។ | • ការផ្តល់ការណែនាំ<br>• ការអនុវត្តជាក់ស្តែងតាមសកម្មភាពមូលដ្ឋាន<br>• ការផ្តល់ព័ត៌មានត្រឡប់ និង ការថ្លែងអំណរគុណ | • ជំនាញទំនាក់ទំនង<br>• ជំនាញអន្តរបុគ្គល<br>• ជំនាញរៀបចំចាត់ចែង<br>• ចំណេះដឹងតាមរយៈការចូលរួមអនុវត្តផែនការ<br>• ចំណេះដឹងពីឥរិយាបថរបស់សហគមន៍<br>• ទំនុកចិត្តលើខ្លួនឯង<br>• ឥរិយាបថវិជ្ជមានឆ្ពោះទៅរកការដោះស្រាយបញ្ហាក្នុងសហគមន៍ | • ផ្អែកលើសកម្មភាពតាមមូលដ្ឋាន | ២ ម៉ោង |
| **៦. ការឆ្លុះបញ្ចាំងនិងវាយតម្លៃ**<br>**គោលបំណង :** លើកទឹកចិត្តសិស្សដើម្បីឆ្លុះបញ្ចាំង និង រៀនពីបទពិសោធន៍ក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយនៅតាមមូលដ្ឋាន ។ | • ឆ្លុះបញ្ចាំងលើសកម្មភាពតាមមូលដ្ឋាន<br>• ការសរសេររបាយការណ៍ | • ជំនាញក្នុងការវិភាគ<br>• ជំនាញគិតដោយវិភាគ<br>• ទំនុកចិត្តខ្លួនឯង<br>• ម្ចាស់ការខ្លួនឯង<br>• ការយល់ដឹងខ្លួនឯង<br>• ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាក្នុងសហគមន៍ | • សៀវភៅសិស្ស និង ប៊ិច ខ្មៅដៃ | ២ ម៉ោង |

# ដំណាក់កាលទី ១: ការស្វែងយល់ប្រធានបទ

## I. សេចក្តីផ្តើម :

ដោយសារកម្មវិធីបំណិនជីវិតតាមមូលដ្ឋានផ្តោតទៅលើតម្រូវការ និង ចំណង់ចំណូលចិត្តរបស់សិស្សនៅតាមសហគមន៍របស់គេ គ្រូត្រូវដឹងថាសិស្សមានចំណេះដឹងច្រើនពាក់ព័ន្ធទៅនឹងប្រធានបទដែលត្រូវរៀន ។ លើសពីនេះទៀតមន្ត្រីសង្គមកិច្ច សុខាភិបាល អាជីវករ... នៅក្នុងសហគមន៍ជាធនធានដែលគ្រូអាចប្រើប្រាស់ក្នុងការកសាងចំណេះដឹង និង ស្វែងយល់ ពីប្រធានបទ ។

**II. គោលបំណង :** សិស្សកំណត់បាននូវអ្វីដែលគេចេះស្រាប់ និង មធ្យោបាយផ្សេងក្នុងការបង្កើនចំណេះដឹងរបស់ខ្លួនចំពោះប្រធានបទដែលបានជ្រើសរើស ។

**III. បំណិនសំខាន់ៗដែលត្រូវអភិវឌ្ឍ :** បំណិនស្រាវជ្រាវ បំណិនទំនាក់ទំនង បំណិនអន្តរបុគ្គល ការរៀបចំចាត់ ចែងលើប្រធានបទឱ្យកាន់តែស៊ីជម្រៅ ការឱ្យតម្លៃខ្លួនឯង និង សហគមន៍ និង ការទទួលខុសត្រូវ ។

## IV. ល្បិចបង្រៀន :



គ្រូមិនគ្រាន់តែយកដំណាក់កាលទាំង ៦ ទៅបង្រៀននោះទេ។ គ្រូត្រូវដឹងច្បាស់ថា តើត្រូវរៀបចំសកម្មភាពណាខ្លះ ដើម្បីឱ្យសិស្សយល់ច្បាស់ពី ប្រធានបទ ។

### សកម្មភាពទី ១ : ការបំផុសគំនិត

#### សេចក្តីផ្តើម:

ការបំផុសគំនិតគឺជាវិធីសាស្ត្រដើម្បីប្រមូលគំនិតឱ្យបានច្រើនដែលពាក់ព័ន្ធទៅនឹងប្រធានបទជាក់ស្តែង ។ លោកគ្រូ អ្នកគ្រូឱ្យសិស្សបញ្ចេញគំនិតរបស់គេ មិនថាគំនិតនោះចម្លែកចាកឆ្ងាយពីប្រធានបទ ឬ យល់ឃើញថា គំនិតនោះមិនអាចទទួលយកបានក៏ដោយ ។ ល្បិចបង្រៀននេះគឺដើម្បីប្រមូលគំនិតឱ្យបានច្រើនក្នុងរយៈពេលដ៏ ខ្លីមួយ និង ផ្តល់ឱ្យគ្រូនូវចំណាប់អារម្មណ៍ភ្លាមៗ ថាតើកុមារយល់ដឹងបានប៉ុន្មានពាក់ព័ន្ធទៅនឹងប្រធានបទ ។ វិធីនេះគេប្រើដើម្បីបំផុសគំនិតនូវអ្វី ដែលសិស្សពុំទាន់ដឹង និង អ្វីដែលសិស្សបានដឹងអំពីប្រធានបទ ។ ម្យ៉ាងវិញទៀតយើង អាចនិយាយថា វាគឺជាការសំយោគគំនិតអំពីអ្វីដែលកុមារចង់ដឹង ។

### វិធានក្នុងការបំផុសគំនិត

- ការបំផុសគំនិតលើប្រធានបទត្រូវឱ្យកុមារទាំងអស់បានចូលរួម ដោយផ្តោតការយកចិត្តទុកដាក់ពិសេសចំពោះកុមារនៅខាងក្រោយ ឬ កុមារដែលស្ងៀមស្ងាត់ ។
- លើកទឹកចិត្តសិស្សឱ្យនិយាយនូវអ្វីដែលគេគិត ដើម្បីចែករំលែកគំនិតទាំងនោះជាមួយសិស្សដទៃទៀតក្នុងថ្នាក់ ។
- មិនត្រូវរិះគន់ សើចចម្អកដល់គំនិត ឬ បញ្ឈប់គំនិតរបស់កុមារឡើយ ។
- កត់ត្រារាល់គំនិតទាំងអស់ដែលបានលើកឡើង និង មិនត្រូវពិភាក្សា ឬ វាយតម្លៃគំនិត ដែលបានបង្កើតឡើងឡើយ ហើយត្រូវស្តាប់គ្នាទៅវិញទៅមក ។
- បន្ទាប់ពីបានប្រមូលគំនិតចប់ អ្នកអាចពិភាក្សា ដាក់គំនិតជាក្រុម ឬ លុបគំនិតមួយចំនួនចោល ទៅតាមតម្រូវការនៃសកម្មភាព ។

**វិធីប្រតិបត្តិដើម្បីអនុវត្តការបំផុសគំនិត :** មានវិធីច្រើនដូចខាងក្រោមដែលអ្នកអាចយកទៅធ្វើការបំផុសគំនិតៈ

- សរសេរសំណួរ "តើយើងដឹងអ្វីខ្លះអំពី (ឈ្មោះប្រធានបទ) ជាអក្សរធំលើក្តារខៀន។ គូសរង្វង់មូលលើវា ហើយគូសសញ្ញាព្រួញខ្លះៗចេញពីរង្វង់នោះ ។ សួរសិស្សថាគេដឹងអ្វីខ្លះអំពីប្រធានបទ ។ នៅពេលដែលគេផ្តល់គំនិតអ្វីមួយ សរសេរវាជុំវិញប្រធានបទ (រង្វង់) នោះ ហើយបន្ទាប់មកបានមែកធាងជាច្រើន។
- ឬ សរសេរ "តើយើងដឹងអ្វីខ្លះអំពី (ឈ្មោះប្រធានបទ) ជាអក្សរធំលើក្តារខៀន ។ ឱ្យពេលសិស្ស ២-៣ នាទី ដើម្បីកត់ត្រាគំនិតដោយខ្លួនឯង ។ ក្រោយមកប្រមូលគំនិតរបស់គេដាក់លើក្តារខៀន ។
- ឬ ធ្វើដូចខាងលើ ប៉ុន្តែ កុមារត្រូវធ្វើការងារជាក្រុមតូចៗ ។
- សកម្មភាពបំផុសគំនិតនេះអាចធ្វើវានៅលើក្រដាស់ផ្ទាំងធំ ដែលអាចប្រើប្រាស់នៅមេរៀនបន្ទាប់ទៀត ដោយប្រើជាឯកសារយោង ឬ បំពេញបន្ថែមនូវគំនិតថ្មីនៅលើក្រដាសផ្ទាំងធំនោះ ។

## សកម្មភាពទី ២: ការអញ្ជើញអ្នកមានបទពិសោធន៍មកផ្តល់បទឧទ្ទេស

### សេចក្តីផ្តើម

ការអញ្ជើញអ្នកមានបទពិសោធន៍មកឧទ្ទេស និងនិយាយទៅកាន់សិស្សពីប្រធានបទជាក់លាក់មួយវាអាចធ្វើឱ្យសិស្សទទួលបានព័ត៌មានបន្ថែមមួយដែលគួរឱ្យចាប់អារម្មណ៍ និង មានអន្តរកម្មល្អប្រសើរ ។ ការអញ្ជើញអ្នកមានបទពិសោធន៍មកនិយាយធ្វើឱ្យសិស្សអភិវឌ្ឍបំណិនក្នុងការសួរ ការស្តាប់ និង ឆ្លើយតបចំពោះ ព័ត៌ មានតាមលក្ខណៈជាក់ស្តែង។ វាគ្មិនក៏អាចដើរតួជាគំរូមួយបានដែរ ជាពិសេសនៅពេលដែលវាគ្មិនជាមិត្តភក្តិរបស់គេត្រូវបានអញ្ជើញឱ្យបង្ហាញនូវយោបល់ និង បទពិសោធន៍របស់គេទៅលើប្រធានបទជាក់លាក់មួយ ។

## វិធានក្នុងការអញ្ជើញ

- ត្រូវមានទំនាក់ទំនងភ្ញៀវជាមុន កំណត់កាលវិភាគជាមួយភ្ញៀវឱ្យបានច្បាស់លាស់ និង គំនិតសំខាន់ៗដែលគួរនិយាយជាដើម ។
- ត្រូវអញ្ជើញភ្ញៀវជាមុនដើម្បីដឹងថាតើគាត់ អាចចូលរួមបានឬទេ ។
- មិនត្រូវបង្ខំភ្ញៀវឱ្យចូលរួមនិយាយលើប្រធានបទ ដែលគេយល់ថាគេមិនមានទំនុកចិត្ត ក្នុងការនិយាយ ឬ មិនត្រូវបង្ខំគេឱ្យនិយាយនូវរឿងរ៉ាវដែលពាក់ព័ន្ធផ្លូវចិត្ត ដូចជាអំពើហិង្សា ក្នុងគ្រួសារជាដើម។ ត្រូវព្យាយាមអញ្ជើញភ្ញៀវណាដែលអ្នកគិតថាគាត់អាចធ្វើឱ្យកុមារចាប់អារម្មណ៍ និង អាចលើកទឹកចិត្តកុមារបាន ។ ប្រសិនបើភ្ញៀវនិយាយតែម្នាក់ឯងទៅកាន់សិស្សនោះវានឹងធ្វើឱ្យសិស្សធុញ ឬ មិនចាប់អារម្មណ៍ចំពោះប្រធានបទ ហើយអាចធ្វើឱ្យវត្ថុបំណងនោះមិនអាចសម្រេចបាន ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់មេរៀនទាំងមូលទៀតផង ។
- សួរសិស្សថាតើអ្នកស្គាល់ភ្ញៀវ ឬ វាគ្មិនណាម្នាក់ដែលអ្នកចង់អញ្ជើញឱ្យមកនិយាយអំពីប្រធានបទនេះទេ គ្រូក៏អាចផ្តល់ជម្រើសឱ្យពួកគេក្នុងជ្រើសរើសភ្ញៀវ ឬ វាគ្មិននេះ ។
- ត្រូវប្រាកដថាបានផ្តល់ព័តិមានដល់នាយកសាលា និងទទួលការអនុញ្ញាតរួចហើយ ។
- ស្នើសុំឱ្យសមាជិកគណៈកម្មការឃុំអប់រំសម្រាប់ទាំងអស់គ្នាឱ្យជួយអញ្ជើញភ្ញៀវ ។
- ត្រូវប្រាកដថាផ្តល់ព័តិមានអំពីប្រធានបទដល់ភ្ញៀវ និង ប្រាប់ពីកាលបរិច្ឆេទ ព្រមទាំងអ្នកស្តាប់ និង វត្ថុបំណងនៃសកម្មភាព ដើម្បីឱ្យគាត់អាចត្រៀមលក្ខណៈបានល្អ ។
- រំលឹកភ្ញៀវពីកាលបរិច្ឆេទដែលជិតមកដល់ ដើម្បីកុំឱ្យកុមារអន់ចិត្ត ក្នុងករណីភ្ញៀវដែលមិនបានមក ឬ បើសិនជាគេភ្លេច ។
- ដឹងឱ្យច្បាស់នូវតម្រូវការ ដែលពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ ។ ភ្ញៀវខ្លះគេប្រហែលជាទាមទារសោហ៊ុយក្នុងការធ្វើដំណើរ បើសិនជាគាត់នៅតំបន់ឆ្ងាយ ហើយប្រហែលជាពុំសូវមានពេលវេលាច្រើនទៀតផង ។
- ត្រូវឱ្យកុមារអរគុណចំពោះភ្ញៀវ ហើយចាត់ចែងឱ្យកុមារសរសេរជាលិខិតថ្លែងអំណរគុណ និង ចែករំលែកនូវអ្វីដែលគេបានរៀនជាមួយភ្ញៀវ ។ ភ្ញៀវដែលបានមកធ្វើបទឧទ្ទេសលើកនេះអាចនឹងអញ្ជើញត្រឡប់មកជាថ្មីម្តងទៀតនៅជំហានទី ៥ (ការអនុវត្តផែនការនៅតាមសហគមន៍) ។

**វិធីប្រតិបត្តិដើម្បីអនុវត្តការផ្តល់បទឧទ្ទេស :** មានវិធីច្រើន ដែលគេអាចយកទៅអនុវត្តក្នុងពេលឧទ្ទេសៈ

- ប្រាប់កុមារអំពីភ្ញៀវដែលនឹងមកជួបពួកគេពី (ឈ្មោះ អាយុ ភេទប្រវត្តិរូប បទពិសោធន៍ និង មូលហេតុដែលអ្នកជ្រើសរើសគាត់មកធ្វើបទឧទ្ទេស) ។ ឱ្យកុមារគិតរកសំនួរមុនពេលចាប់ផ្តើមមេរៀន ដែលគេចង់សួរទៅកាន់ភ្ញៀវដែលនិយាយអំពីប្រធានបទ ។

- ឱ្យកុមារអានអត្ថបទអំពីប្រធានបទដើម្បីបង្កើតសំនួរ ដែលគេចង់សួរភ្ញៀវ ។
- បន្ទាប់ពីភ្ញៀវចាកចេញទៅគ្រូអាចឱ្យសិស្សពិភាក្សាសំណួររចម្លើយ និង ពិភាក្សាពីអ្វីដែលគេបានរៀនសូត្រពីភ្ញៀវទាំងខ្លឹមសារ និង ជំនាញលើការបង្ហាញ ។

## តើនរណាអាចធ្វើជាវាគ្មិនសម្រាប់កុមារ?

- អ្នកមានជំនាញលើប្រធានបទអាចជាមន្ត្រីរដ្ឋាភិបាលឬក្រុមការងារឃុំដែលធ្វើការលើបញ្ហាសុខភាពបញ្ហាសង្គម នាយក គ្រូបង្រៀន ព្រះសង្ឃ ។ល។
- បុគ្គលិកអង្គការ ដែលយល់អំពីការងារអប់រំ និងប្រធានបទដែលពាក់ព័ន្ធ។
- សមាជិកសហគមន៍ដែលមានបទពិសោធន៍ និង បញ្ហាផ្ទាល់ខ្លួន ដែលពាក់ព័ន្ធទៅនឹងប្រធានបទ (បញ្ហាពាក់ព័ន្ធទៅនឹងអនាម័យ និង សុខភាព ការបោះឆ្នោតឃុំ ។ល។)
- កុមារក្នុងសហគមន៍ ដែលមានបទពិសោធន៍ទាក់ទងទៅនឹងប្រធានបទ (ចំណាកស្រុកទៅធ្វើការនៅភ្នំពេញក្នុងរោងចក្រកាត់ដេរ កុមារ/យុវជនដែលបោះបង់ចោលសាលា យុវជនដែលកំពុងធ្វើការងារជាដើម ។)

# សកម្មភាពទី ៣ : គម្រោងស្រាវជ្រាវខ្លាយៗ

## សេចក្តីផ្តើម

ការស្រាវជ្រាវងាយៗ គឺជាសកម្មភាពទាំងឡាយណា ដែលមានគោលបំណងប្រមូលព័ត៌មានសំខាន់ៗអំពីប្រធានបទដែលគេអាចប្រើប្រាស់នៅពេលក្រោយបាន ។ ការស្រាវជ្រាវងាយៗគឺជាសកម្មភាពខ្លីៗ ហើយសាមញ្ញដែលមិនចាំបាច់ចំណាយពេលច្រើនធ្វើផែនការ ធ្វើការវិភាគវែងឆ្ងាយ និង មិនមានភាពសាំញ៉ាំ ។ ការអនុវត្តសកម្មភាពស្រាវជ្រាវងាយៗទាំងនេះ ផ្តល់ឱកាសដល់កុមារក្នុងការទទួលយកបទពិសោធន៍ក្នុងការស្រាវជ្រាវប្រមូលព័ត៌មានដែលមានស្រាប់ និង អភិវឌ្ឍការយល់ដឹងពីប្រភពធនធានផ្សេងៗនៃព័ត៌មានក្នុងសហគមន៍។

## វិធាននៃសកម្មភាពស្រាវជ្រាវងាយៗ

- ត្រូវត្រៀមប្រភពព័ត៌មានជាស្រេច ហើយឱ្យកុមារទាំងអស់បានដឹងប្រភពព័ត៌មានទាំងនោះ ។
- ត្រូវប្រាកដថា កុមារមានជំនឿចិត្តក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវងាយៗនេះ ។
- មិនត្រូវធ្វើឱ្យកុមារមានសម្ពាធក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវឡើយ ឬមិនត្រូវបង្ខំ ឬ ធ្វើឱ្យគេខឹងឡើយ បើសិនជាកុមារមិនអាចប្រមូលទិន្នន័យដែលអាចជឿជាក់បាន ។
- មិនត្រូវឱ្យកុមាររៀបចំសំនួរច្រើនពេកទេ (អតិបរិមា ចំនួន ៦សំនួរ គឺគ្រាប់គ្រាន់ ) ។
- ផ្តល់ឱកាសឱ្យសិស្សហ្វឹកហាត់ធ្វើការអនុវត្តសកម្មភាពស្រាវជ្រាវ ជាមួយមិត្តភក្តិក្នុងថ្នាក់រៀនរបស់គេ ។
- រៀបចំកុមារឱ្យមានសុជីវធម៌ក្នុងការនិយាយទៅកាន់អ្នកផ្តល់ព័ត៌មាន និង ត្រូវពន្យល់ពីគោលបំណងនៃការធ្វើសំណួរ និង ការស្រាវជ្រាវរបស់គេ ។

- ជូនពរឱ្យកុមារមានសំណាងល្អ មុនពេលចុះស្រាវជ្រាវ និង ទទួលបាននូវបទពិសោធន៍ល្អព្រមទាំងទទួលបាននូវភាពសប្បាយរីករាយក្នុងការងារនេះ ។
- លើកទឹកចិត្តសិស្សឱ្យព្យាយាមធ្វើឡើងវិញប្រសិនបើការធ្វើលើកទី ១ មិនបានទទួលជោគជ័យ ដោយពន្យល់ថាការងារនេះនឹងបានប្រសើរនៅពេលក្រោយ ។
- មិនត្រូវឱ្យសិស្សអានលទ្ធផលដែលទទួលបានពីការស្រាវជ្រាវម្តងម្នាក់ៗនៅក្នុងថ្នាក់រៀនឡើយ ព្រោះវានាំឱ្យខាតពេលវេលា សិស្សធុញទ្រាន់ និង ធ្វើឱ្យបាត់បង់ឱកាសរបស់គេក្នុងការប្រើប្រាស់ព័ត៌មាន ដែលគេបានប្រមូល ។

**វិធីប្រតិបត្តិដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវងាយៗ :** ការរៀបចំសកម្មភាពស្រាវជ្រាវងាយៗដូចជា :

- បំផុសគំនិតរកប្រភពអ្នកផ្តល់ព័ត៌មានលើប្រធានបទជាក់លាក់មួយ (អ្នក ភូមិ កុមារ មន្ត្រីរដ្ឋាភិបាល ឯកសារក្នុងបណ្ណាល័យ វិទ្យុ ទូរទស្សន៍ ។ល។)
- សួរសិស្សថាតើពួកគេចង់រកប្រភេទព័ត៌មានបែបណា ។
- ឱ្យសិស្សកំណត់នូវប្រភពព័ត៌មានដែលល្អបំផុតសម្រាប់ប្រធានបទដែលបានជ្រើសរើស ហើយជាវិធីមួយងាយបំផុតក្នុងការអនុវត្តដើម្បីស្វែងរកព័ត៌មានដែលគេត្រូវការ ។
- នៅពេលសិស្សសម្រេចយកប្រភេទព័ត៌មានដែលគេចង់បាន និងប្រភពដែលល្អបំផុត សិស្សអាចចាប់ផ្តើមធ្វើផែនការសកម្មភាពស្រាវជ្រាវ ។
- ជាដំបូងឱ្យសិស្សអភិវឌ្ឍកម្រងសំនួរដោយផ្អែកលើអ្វីដែលគេបានរកឃើញ ។
- ត្រូវចងចាំថាគួរតែមានសំណួរយ៉ាងច្រើនបំផុតចំនួន ៦ សំនួរសម្រាប់សិស្សម្នាក់ៗ ។ សិស្សម្នាក់ៗអាចប្រមូលព័ត៌មានខុសៗគ្នា ដែលបញ្ជាក់ថាមានព័ត៌មានច្រើនណាស់ដែលប្រមូលបានផ្តោតលើប្រធានបទជាក់លាក់មួយ ។
- បន្ទាប់មកទៀតឱ្យសិស្សធ្វើតារាងរាយឈ្មោះពីប្រភពព័ត៌មានដែលរកបានសម្រាប់សំណួរនីមួយៗ ។ ពេល ខ្លះ វាពិតជាសំខាន់ណាស់ ក្នុងការដែលមានប្រភពព័ត៌មានមួយចំនួនដាក់ក្នុងតារាង ដើម្បីឱ្យសិស្សអាច មានជម្រើសខ្លះ នៅពេលប្រមូលទិន្នន័យ (សូមមើលគំរូតារាងឈ្មោះប្រភពប្រមូលទិន្នន័យ) ។
- ត្រូវប្រាកដថាសិស្សទាំងអស់យល់ថា វាមិនមែនជាការសំខាន់ក្នុងការប្រមូលព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបានលើប្រធានបទនោះទេ។ ប៉ុន្តែវាជាការប្រសើរណាស់បើយើងមានព័ត៌មានតិចតែមានគុណភាពគ្រប់គ្រាន់ល្អ ។
- ឱ្យសិស្សហ្វឹកហាត់សួរសំណួរនៅក្នុងថ្នាក់រៀនមុនពេលគេចេញទៅសហគមន៍ ហើយវាកាន់តែប្រសើរទៅទៀត ប្រសិនបើមានគំរូសំខាន់ឱ្យសិស្សធ្វើដោយជ្រើសរើសនរណាម្នាក់នៅក្នុងសាលា ឬ នៅក្នុង សហគមន៍ ។

## ការប្រើប្រាស់ព័ត៌មាន

នៅពេលដែលសិស្សប្រមូលព័ត៌មានបានហើយ មានវិធីជាច្រើនដើម្បីជួយឱ្យពួកគេចេះប្រើប្រាស់ ហើយអាចបង្ហាញព័ត៌មាននោះត្រឡប់វិញបាន ។ វិធីទាំងនេះមានដូចជា ៖



- ឱ្យគេធ្វើការងារជាក្រុម ហើយឱ្យគេផ្លាស់ប្តូរព័ត៌មាន ដែលប្រមូលបាន ។
- បន្ទាប់មកទៀត សមាជិកតាមក្រុមនីងអាចសរសេរប្រភេទព័ត៌មានខុសៗគ្នាដែលគេប្រមូលបាន ហើយ បង្ហាញវាទៅកាន់សិស្សដទៃទៀត ។
- វិធីបង្ហាញព័ត៌មានដែលប្រមូលបានមួយទៀត គឺឱ្យសិស្សជ្រើសរើសផ្នែកមួយនៃព័ត៌មាននៃការស្រាវជ្រាវរបស់គេ ។ សកម្មភាពនេះអាចជ្រើសរើសបានតាមវិធីជាច្រើន ។ ឧទាហរណ៍ ផ្នែកខ្លះនៃព័ត៌មានដែលគេគិតថាមានសារៈសំខាន់បំផុតសម្រាប់ពួកគេ និង ផ្នែកខ្លះនៃព័ត៌មានដែលគេគិតថាពុំសូវមានប្រយោជន៍សម្រាប់គេ និង ផ្នែកដែលគេមិនដែលធ្លាប់បានដឹងសោះពីមុន ។ល។
- នៅពេលដែលគេបានជ្រើសរើសផ្នែកព័ត៌មានរួចហើយ គេអាចសរសេរវានៅលើប័ណ្ណដាក់នៅលើជញ្ជាំង ក្រោយមកទៀតគេទៅមើលជម្រើសព័ត៌មានរបស់សិស្សផ្សេងៗទៀត ។
- បន្ទាប់មកសិស្សអាចប្រើប្រាស់ព័ត៌មាននេះក្នុងដំណាក់កាលផ្សេងទៀតនៃកម្មវិធី ។

### គំរូតារាងឈ្មោះប្រភពប្រមូលទិន្នន័យ សម្រាប់សកម្មភាពស្រាវជ្រាវងាយៗ

<table>
<tr><th colspan="2" rowspan="2">សំណួរ</th><th colspan="2">ប្រភពព័ត៌មាន</th><th rowspan="2">ការឆ្លើយតប/សម្គាល់</th></tr>
<tr><th>មនុស្ស</th><th>ឯកសារ/ទីកន្លែង</th></tr>
<tr><td>១</td><td></td><td></td><td></td><td></td></tr>
<tr><td>២</td><td></td><td></td><td></td><td></td></tr>
<tr><td>៣</td><td></td><td></td><td></td><td></td></tr>
<tr><td>៤</td><td></td><td></td><td></td><td></td></tr>
<tr><td>៥</td><td></td><td></td><td></td><td></td></tr>
<tr><td>៦</td><td></td><td></td><td></td><td></td></tr>
</table>

## សកម្មភាពទី ៤ : ការប្រើប្រាស់ករណីសិក្សា

ករណីសិក្សាគឺជាខ្សែរឿងទាំងឡាយណាដែលមានព័ត៌មានលើប្រធានបទ ជាស្ថានភាពឬជាព្រឹត្តិការណ៍ ហើយជាទូទៅវាផ្សារភ្ជាប់ទៅនឹងការនិទានរឿងរបស់នរណាម្នាក់ ។ វាអាចឆ្លើយផ្ទាល់ទៅនឹងសំណួរ ឬបង្ហាញដោយផ្ទាល់នូវអ្វីដែលអ្នកអានចង់ដឹង ។ វាក៏ផ្តល់ព័ត៌មានដល់អ្នកអានដើម្បីកំណត់លក្ខណៈ និង ដំណោះស្រាយផ្សេងៗចំពោះស្ថានភាព និង បញ្ហាដែលគេជួបប្រទះនៅក្នុងសហគមន៍របស់គេផ្ទាល់ ។ ករណីសិក្សាគឺជាឧបករណ៍ដ៏មានប្រយោជន៍ពីព្រោះវាផ្តល់នូវបរិបទពិតរបស់ជីវិតដែលគេអាចវិភាគ ស្វែងយល់ព័ត៌មានបានច្រើនលើប្រធានបទ ស្ថានភាព ឬព្រឹត្តិការណ៍មួយ ដែលកើតមានក្នុងជីវិតរបស់មនុស្សម្នាក់ៗ ។

### ល័ក្ខខ័ណ្ឌនៃការបង្កើតករណីសិក្សា

- ត្រូវប្រាកដថា ករណីសិក្សាមិនវែងហួសហេតុពេក ។
- ត្រូវប្រាកដថាករណីសិក្សាសរសេរមានរបៀបរៀបរយតាមភាសាដែលសមរម្យសម្រាប់សិស្សរបស់អ្នក ។
- ត្រូវប្រាកដថា អ្នកជ្រើសរើសករណីសិក្សាដែលពាក់ព័ន្ធ និង ប្រធានបទ ។
- ត្រូវប្រាកដថាសំណួរដែលប្រើប្រាស់ក្នុងករណីសិក្សាអាចឱ្យសិស្សអភិវឌ្ឍចំណេះដឹង និង សមត្ថភាពរបស់គេ ក្នុងការធ្វើអនុមានពែ្វកដោយផ្អែកលើព័ត៌មាននៅក្នុងអត្ថបទ ។
- ផ្លាស់ប្តូរវិធីសាស្ត្រដែលអ្នកប្រើប្រាស់ករណីសិក្សា ជាមួយសិស្សរបស់អ្នកជាពិសេសប្តូរព័ត៌មានសម្រាប់ក្រុមហើយត្រូវមានគំនិតច្នៃប្រឌិត ។

**វិធីប្រតិបត្តិក្នុងការប្រើប្រាស់ករណីសិក្សា:** វិធីផ្សេងៗដែលអ្នកអាចយកទៅប្រើប្រាស់សម្រាប់ធ្វើករណីសិក្សា

- នៅពេលដែលអ្នកបានជ្រើសរើសករណីសិក្សា ដែលពាក់ព័ន្ធទៅនឹងអ្វីដែលអ្នកចង់ឱ្យសិស្សរៀន ចូរចាប់ផ្តើមគិតពីសំណួរ ដែលអ្នកចង់ឱ្យគេឆ្លើយដោយប្រើប្រាស់ករណីសិក្សា ។ (សូមមើលទំព័របន្ទាប់) ។
- អ្នកអាចឱ្យសិស្សធ្វើការងារជាដៃគូ ជាក្រុម ឬជាបុគ្គល អានករណីសិក្សា ហើយឆ្លើយសំណួរ ។
- អ្នកអាចឱ្យករណីសិក្សាផ្សេងៗគ្នាទៅក្រុមឬបុគ្គលខុសៗគ្នា បន្ទាប់មកឱ្យគេផ្តុំគ្នាជាក្រុមធំ ដើម្បីចែករំលែកបទពិសោធន៍ដែលគេបានទទួលពីករណីសិក្សា ។

### ឧទាហរណ៍នៃការបង្កើតក្រុម

១. អ្នកអាចចែកទៅឱ្យក្រុមសិស្ស៤នាក់នូវករណីសិក្សាខុសគ្នាចំនួន ២ ។ សិស្ស ២ នាក់ធ្វើការងាររួមគ្នា ដើម្បីឆ្លើយកម្រងសំណួរ ហើយក្រុមផ្សេងទៀតធ្វើការងារទៅលើកម្រងសំណួរដដែល ប៉ុន្តែជាមួយករណីសិក្សាខុសគ្នា ។ នៅពេលបញ្ចប់សកម្មភាព ពួកគេអាចចែករំលែកចម្លើយគ្នា ។

២. អ្នកអាចឱ្យករណីសិក្សាដូចគ្នាទៅដល់សិស្សក្នុងក្រុម ប៉ុន្តែមានសំណួរខុសគ្នា ។ នៅចុងបញ្ចប់សមាជិកក្នុងក្រុមចែករំលែកព័ត៌មានទាំងនេះជាមួយគ្នា ។

៣. អ្នកអាចណែនាំករណីសិក្សាដល់សិស្ស (តើករណីសិក្សានេះនិយាយពីនរណា ទីតាំងនិងលក្ខណៈទូទៅនៃករណីសិក្សា) បន្ទាប់មកទៀត អ្នកអាចសួរសិស្សថាតើអ្វីដែលគេចង់ដឹងពីករណីសិក្សា ចំពោះតួអង្គដែលបានបង្ហាញ ហើយដែលពាក់ព័ន្ធទៅនឹងប្រធានបទដែលអ្នកកំពុងសិក្សា ។ ឱ្យសិស្សអានករណីសិក្សា ហើយសួរសំណួរ ពិនិត្យមើលថាតើគេទទួលបានចម្លើយប៉ុន្មាន ។

**ការអភិវឌ្ឍ និង ការសួរសំណួរ :** វាជាការសំខាន់ណាស់បើគ្រូសួរសំណួរដើម្បី :

- ត្រួតពិនិត្យការយល់ដឹង ។
- ជម្រុញការចូលរួមជាមួយសិស្ស ។
- ឱ្យសិស្សប្រតិបត្តិ ។

**ប្រភេទសំនួរ**

- **សំណួរបិទ/សំណួរបើក** : ឧទាហរណ៍-តើប្អូនបារម្ភអំពីការទៅរកការងារធ្វើនៅភ្នំពេញឬ?
- **សំណួរប្រៀបធៀប** : ឧទាហរណ៍-តើកុមារីនៅក្នុងរឿងសម្រេចចិត្តទៅធ្វើការងារនៅភ្នំពេញ ដោយខ្លួនឯង ឬ ដោយចិត្តរបស់ឪពុកម្តាយរបស់គេ?
- **សំណួរទស្សទាយ** : ឧទាហរណ៍-ប្រសិនបើ..................តើអ្វីនឹងកើតឡើង..............? ប្រសិនបើនាងបន្តរៀនឱ្យបានចប់ចុងចប់ដើម តើនាងនឹងក្លាយជាមនុស្សប្រសើរបែបណានាពេលអនាគត?
- **សំណួរដែលចាប់ផ្តើមឡើងដោយពាក្យ:** អ្វី? ហេតុអ្វី? ឯណា? នរណា? ពេលណា? របស់នរណា? របៀបណា?

  ឧទាហរណ៍ : ហេតុអ្វីបានជាអ្នកគិតថាកុមារីនៅក្នុងរឿងសម្រេចចិត្តទៅភ្នំពេញ?

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនីមួយៗដែលបានបញ្ចប់ដោយធ្វើការកត់សម្គាល់លើបទពិសោធន៍របស់គេ និង អារម្មណ៍របស់គេលើការចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ ។ គ្រូអាចសួរនូវសំណួរងាយៗ ដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំងលើបំណិនដែល បានអភិវឌ្ឍ:

1. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ ?
2. ក្រៅពីខ្លឹមសារមេរៀន តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី ?
3. តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនបានអភិវឌ្ឍបំណិននោះ?
4. តើបំណិនអ្វីខ្លះដែលប្អូនមិនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនមិនបានអភិវឌ្ឍបំណិននោះ?
5. តើពេលក្រោយប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនមិនទាន់អភិវឌ្ឍ ?

# ជំណាក់កាលទី ២ : ការស្រង់ព័ត៌មានពីសហគមន៍

## I. សេចក្តីផ្តើម :

ស្វែងយល់អំពីអ្វីដែលសហគមន៍យល់ដឹងលើប្រធានបទគឺជាលំហាត់មួយដ៏មានប្រយោជន៍សម្រាប់សិស្សដែលគេអាចផ្សារភ្ជាប់នូវអ្វីដែលគេបានពិភាក្សាអំពីប្រធានបទក្នុងថ្នាក់រៀនលើស្ថានភាពពិតនៃជីវិតរបស់គេ ។ វាក៏ជាការផ្តល់ឱកាសដល់សិស្ស ដើម្បីប្រមូលព័តិមានសំខាន់ៗពីសហគមន៍ និង ឱ្យគេមានទម្លាប់ធ្វើការងារជាមួយសហគមន៍ ដើម្បីជួយដោះស្រាយបញ្ហាងាយៗក្នុងមូលដ្ឋាន ។

**II. គោលបំណង :** បង្កើតឧបករណ៍និងចុះប្រមូលព័តិមានពីសហគមន៍ហ្វឹកហាត់ក្នុងការសួរសំណួរ ដែលអាចឱ្យសិស្សវាយតម្លៃ ការយល់ដឹង និង ឥរិយាបថរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស ។

**III. បំណិនជីវិតសំខាន់ៗដែលនឹងអភិវឌ្ឍ :** បំណិនស្រាវជ្រាវ បំណិនទំនាក់ទំនង បំណិនអន្តរបុគ្គល ចំណេះដឹងលើប្រធានបទឱ្យកាន់តែស៊ីជម្រៅពីសហគមន៍ និង ឥរិយាបថរបស់សហគមន៍លើប្រធានបទការពឹងពាក់លើខ្លួនឯង និង ការជឿជាក់លើខ្លួនឯង ។

## IV. ល្បិចបង្រៀន

### សកម្មភាពទី១ : ការបង្កើតកម្រងសំណួរ

#### សេចក្តីណែនាំ

វាជាការចាំបាច់ណាស់ក្នុងការរៀបចំសិស្សមុនពេលគេទៅសហគមន៍ ដើម្បីប្រមូលព័តិមានស្តីពីការយល់ដឹងរបស់គេលើប្រធានបទ ។ ការកសាងកម្រងសំណួរនឹងជួយសិស្ស ឱ្យយល់កាន់តែច្បាស់អំពីអ្វីដែលត្រូវសួរក្នុងសហគមន៍ ។

**ល្បិចបង្រៀន :**



- រំលឹកឡើងវិញនូវអ្វីដែលបានពិភាក្សាក្នុងជំហានទី ១ ដោយដាក់ពណ៌ចំណាំលើព័តិមាននិងគំនិតសំខាន់ៗ ។
- អភិវឌ្ឍផែនទីគំនិតលើប្រធានបទ និង សំយោគសំណួរឱ្យបានច្រើនតាមចំនួនដែលអាចធ្វើបាន ដែលឆ្លុះបញ្ចាំងលើផែនទីគំនិត ដោយរាប់បញ្ចូលទាំងរឿងរ៉ាវសំខាន់ៗជុំវិញប្រធានបទ ដែលអ្នកបានសង្កេតឃើញក្នុងសហគមន៍ និង អ្វីដែលអ្នកចង់ដឹងបន្ថែមពីសហគមន៍ ។
- ធ្វើយ៉ាងណាឱ្យសិស្សយល់ច្បាស់ពីគោលបំណងនៃការបង្កើតកម្រងសំណួរដោយផ្តោតលើ (មូលហេតុផលប៉ះពាល់ ដំណោះស្រាយ ផែនការសម្រាប់ជីវិត.........) ។

- ដាក់សំណួរដែលទើបតែបង្កើតទៅតាមក្រុមគំនិត និង ជ្រើសរើសសំណួរសំខាន់ៗយ៉ាងច្រើនចំនួន ១០ ដើម្បីប្រើប្រាស់ពេលធ្វើសម្ភាស ។ សិស្សមិនចាំបាច់ទន្ទេញសំណួរឱ្យចាំឡើយ គឺគេគ្រាន់តែចាំពីគំនិតសំខាន់ៗ ដែលត្រូវសួរ និង សួរសំណួរបន្តបន្ទាប់នៅពេលដែលគេចង់ដឹងបន្ថែម ។
- គ្រូធ្វើយ៉ាងណាឱ្យសិស្សចេះបត់បែនតាមសិរិយាបថជាក់ស្តែងនៅពេលចុះសម្ភាសន៍។

## គំរូកម្រងសំណួរ

១. តើលោកពូ-អ្នកមីងដឹងពីរឿងរ៉ាវដែលទាក់ទងទៅនឹង................................?

២. តើធ្លាប់មានរឿងនេះកើតនៅក្នុងសហគមន៍លោកពូ-អ្នកមីងដែរឬទេ?

៣. តើលោកពូ-អ្នកមីងដឹងទេថាតើមូលហេតុអ្វីនាំឱ្យមានរឿងរ៉ាវនោះ?

៤. តើលោកពូ-អ្នកមីងដឹងទេថារឿងនោះវានឹងមានផលវិបាកអ្វីខ្លះ?

៥. តើលោកពូ-អ្នកមីងគិតថារឿងនោះមានអ្វីខ្លះប៉ះពាល់ដល់ជីវិត និងគ្រួសាររបស់ពួកគាត់?

៦. តើពួកគាត់/លោកពូ-អ្នកមីងធ្វើដូចម្តេចដើម្បីដោះស្រាយរឿងរ៉ាវនេះកន្លងមក?

៧. តើពេលកើតមានរឿងរ៉ាវនោះ មាននរណាម្នាក់ជួយធ្វើអន្តរាគមន៍ដែរឬទេ?

៨. តើលោកពូ-អ្នកមីងចង់ឃើញបញ្ហាបែបនេះកើតមាននៅក្នុងសហគមន៍របស់លោកពូ-អ្នកមីងដែរទេ?

៩. តើលោកពូ-អ្នកមីងគិតថាយើងអាចរួមគ្នាដោះស្រាយបញ្ហាទាំងនោះបានដែរឬទេ? ហេតុអ្វី?

១០. តើលោកពូ-អ្នកមីងគិតថាគួរមានដំណោះស្រាយដូចម្តេចខ្លះ?

- សកម្មភាពនេះអាចធ្វើបានដោយថ្នាក់ទាំងមូល ឬ ដោយក្រុមតូចៗ ។ បើធ្វើដោយក្រុមតូចក្រុមនីមួយៗត្រូវបង្ហាញកម្រងសំណួររបស់គេទៅដល់ថ្នាក់ទាំងមូល ហើយដឹកនាំការពិភាក្សាដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថាពួកគេក្តោបយកព័តិមានចាំបាច់សម្រាប់ដំណាក់កាលបន្ទាប់ ។
- សិស្សម្នាក់ៗមានកម្រងសំណួរដែលសរសេរលើសៀវភៅរបស់គេ ។
- គ្រូត្រូវរៀបចំផែនការលំអិតជូននាយកសាលា ឬ ក្រុមការងារ ដើម្បីពួកគាត់ផ្តល់ព័តិមានដល់សហគមន៍ នៅពេលបញ្ចប់សកម្មភាពទី ២ ស្តីពីការត្រៀមសម្ភាសន៍។

## សកម្មភាពទី ២: ការត្រៀមសម្ភាសន៍

ការត្រៀមសម្ភាសន៍អាចជួយសិស្សធ្វើផែនការរៀបចំសម្ភារនិងការចាត់ចែងទាំងឡាយ ដែលចាំបាច់មុនពេលសម្ភាសន៍ ។ វានឹងជួយឱ្យសិស្សយល់កាន់តែច្បាស់នូវអ្វីដែលគេនឹងត្រូវធ្វើនៅក្នុងសហគមន៍ដូចជា ***ហេតុអ្វី? ធ្វើអ្វី? នរណាធ្វើ? នៅពេលណា? ធ្វើដោយរបៀបណា?*** ។ល។

**ល្បិចបង្រៀន**

- កំណត់គោលបំណងនៃការសម្ភាសន៍ដើម្បីឱ្យសិស្សអាចពន្យល់សហគមន៍ពីគោលបំណង ដែលគេត្រូវជួប ។
- អភិវឌ្ឍន៍តារាងតាមដានទូវអ្វីដែលសិស្សត្រូវធ្វើ ដោយរាប់ទាំងកម្រងសំណួរ ការផ្តល់ព័តិមានដល់អ្នកដែលត្រូវសម្ភាសន៍ ការហ្វឹកហាត់ដោយប្រើកម្រងសំណួរ កំណត់ចំនួន និង មុខសញ្ញាដែលយើង ចង់សម្ភាសន៍ កំណត់កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវសម្ភាសន៍ ។
- បង្ហាញផែនការសម្ភារដល់នាយកសាលា ឬ ក្រុមការងារ ដើម្បីឱ្យពួកគេជួយគាំទ្រ ។
- ចែករំលែកការទទួលខុសត្រូវសមាជិកក្នុងក្រុម តើនរណាជាអ្នកណែនាំក្រុមទៅកាន់អ្នកដែលត្រូវសម្ភាសន៍ នរណាជាអ្នកសួរសំណួរ? នរណាជាអ្នកកត់ត្រា ។ល។ រួចទុកពេលវេលាឱ្យសិស្សហ្វឹកហាត់សម្ភាសន៍ ។

## សកម្មភាពទី ៣ : ការសម្ភាសន៍ជាក់ស្តែង

សកម្មភាពនេះអនុវត្តឡើងនៅក្នុងសហគមន៍ ដោយជួយជំរុញការធ្វើអន្តរកម្មរវាងសាលា និង សហគមន៍ ព្រមទាំងធ្វើឱ្យសហគមន៍យល់ច្បាស់អំពីរឿងរ៉ាវ ដែលនឹងអាចមានឥទ្ធិពលទៅលើជីវិតរបស់ពួកគាត់ ។ វាក៏ផ្តល់ឱកាសឱ្យសិស្សអភិវឌ្ឍបំណិនទំនាក់ទំនង អន្តរបុគ្គល និង ទទួលបានកាន់តែច្រើននូវទំនុកចិត្តលើខ្លួនឯង ការគោរពខ្លួនឯង និង ចំណេះដឹងអំពី សហគមន៍ ។

**ល្បិចបង្រៀន**

- ស្វាគមន៍ចំពោះអ្នកដែលត្រូវសម្ភាសន៍ ហើយពន្យល់ពីគោលបំណងនៃការសម្ភាសន៍ ។
- ណែនាំសមាជិកក្រុមដល់អ្នកដែលត្រូវសម្ភាសន៍ ហើយអរគុណដល់គាត់ដែលបានចំណាយពេលវេលាសម្រាប់ការសម្ភាសន៍នេះ ។
- ចាប់ផ្តើមសម្ភាសន៍សមាជិកក្រុមនីមួយៗត្រូវប្រកាន់តួនាទី និង ការទទួលខុសត្រូវរបស់ខ្លួនតាមការ ដែលបានរៀបចំ ទុកកាលពីសកម្មភាពលើកមុន ។
- នៅចុងបញ្ចប់អរគុណដល់អ្នក ដែលត្រូវសម្ភាសន៍សារជាថ្មី ហើយជម្រាបពួកគាត់ថាយើងខ្ញុំសង្ឃឹមថានឹងបានសហការជាមួយលោកពូ-អ្នកមីងដើម្បីដោះស្រាយបញ្ហានេះនៅពេលអនាគត ។

## សកម្មភាពទី ៤ ៖ ការធ្វើរបាយការណ៍

បន្ទាប់ពីធ្វើសម្ភាសន៍រួចហើយក្រុមនីមួយៗត្រូវរៀបចំនូវអ្វីដែលគេបានរកឃើញ ហើយបង្ហាញដល់ថ្នាក់ទាំងមូល ដោយកត់សម្គាល់នូវចំណុចសំខាន់ៗដែលរកឃើញ ។ក្រុមនីមួយៗក៏ត្រូវរៀបចំរបាយការណ៍ផងដែរអំពីភាពលំបាក និង ការប្រឈមទាំងឡាយដែលគេជួបប្រទះនៅពេលចុះសម្ភាសន៍ ហើយកំណត់នូវអ្វីដែលគេត្រូវការជំនួយបន្ថែមនៅពេលដែលគេចុះសម្ភាសន៍ ។

### ល្បិចបង្រៀន

- សកម្មភាពនេះអាចធ្វើដាច់ដោយឡែកពីគ្នានៅក្រៅថ្នាក់រៀនដោយក្រុមផ្ទាល់ខ្លួនរបស់គេឬធ្វើក្នុងថ្នាក់រៀនដោយមានជំនួយពីគ្រូប្រចាំថ្នាក់ ។
- ក្រុមនីមួយៗដឹកនាំការពិភាក្សាលើលទ្ធផលសម្ភាសន៍ ហើយសរសេរនៅលើក្រដាស់ព្រាង ។
- រៀបចំលទ្ធផលសម្ភាសន៍នោះធ្វើយ៉ាងណាអាចបង្ហាញបានស្រួលនៅក្នុងថ្នាក់រៀនទៅតាមគំរូដូចខាងក្រោម ។
- សរសេរលទ្ធផលនេះលើក្រដាស់ផ្ទាំងធំសម្រាប់ការបង្ហាញ ។

### គំរូនៃការបង្ហាញលទ្ធផល

**គោលបំណង ៖** ..........................................................................................

**ក្រុមគោលដៅ ៖** ..........................................................................................

**វិធីសាស្ត្រ ៖** ..........................................................................................

**លទ្ធផល ៖**

១. ចំណេះដឹង៖ គិតទាំងព័ត៌មានទូទៅ មូលហេតុ, ផលវិបាក ។ល។

២. ការអនុវត្ត៖ គិតទាំងឥទ្ធិពលលើសហគមន៍, វិធីសាស្ត្រក្នុងការបញ្ចៀសបញ្ហា, សកម្មភាពអនុវត្តន៍...

៣. ឥរិយាបថ៖ គិតទាំងការផ្តោតលើបញ្ហា, ឆន្ទៈដោះស្រាយបញ្ហា ។ល។

**បទពិសោធន៍ដែលបានរៀន**

១. ការលំបាក និង ការប្រឈម ។

២. ការកែលំអសម្រាប់អនាគត ។

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្សដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនីមួយៗ ដែលបានបញ្ចប់ដោយកំណត់សម្គាល់លើបទពិសោធន៍របស់គេ និង អារម្មណ៍របស់គេលើការចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ហើយជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោម:

1. តើដំណើរការសិក្សានៅក្នុងដំណាក់កាលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ ?
2. ក្រៅពីខ្លឹមសារមេរៀន តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី ?
3. តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនបានអភិវឌ្ឍបំណិននោះ?
4. តើបំណិនអ្វីខ្លះដែលប្អូនមិនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនមិនបានអភិវឌ្ឍបំណិននោះ?
5. តើពេលក្រោយប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនមិនទាន់អភិវឌ្ឍ ?

## ដំណាក់កាលទី ៣ : ការវិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា

### I. សេចក្តីផ្តើម

វិភាគលទ្ធផលព័តិមានគឺជាជំហានបន្តពីការប្រមូលព័តិមានក្នុងសហគមន៍នៃដំណាក់កាលទី ២ ។ ដំណាក់កាលនេះពាក់ព័ន្ធក្នុងការវិភាគព័តិមាន និង ការកំណត់ដំណោះស្រាយលើដើមឈើបញ្ហា ។ វាជំរុញសិស្សឱ្យចេះគិតដោយវិភាគ និង ការរែកញែក បំណិនដោះស្រាយបញ្ហា ព្រមទាំងមានឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាក្នុងសហគមន៍របស់ពួកគេ ។

**II. គោលបំណង :** សិស្សអាចប្រើប្រាស់ព័តិមានដែលប្រមូលបាន ដើម្បីវិភាគបញ្ហាសំខាន់ៗ ដូចជាមូលហេតុ ផលវិបាក និង ដំណោះស្រាយចំពោះបញ្ហានោះដោយប្រើការវិភាគដើមឈើបញ្ហា ។

**III. បំណិនសំខាន់ៗដែលនឹងអភិវឌ្ឍ :** បំណិនវិភាគ បំណិនគិតដោយល្អិតល្អន់ បំណិនដោះស្រាយបញ្ហា បំណិនក្នុងការបង្ហាញ ទំនុកចិត្តលើខ្លួនឯង ការឱ្យតម្លៃខ្លួនឯង ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាសហគមន៍...។

### IV. ល្បិចបង្រៀន :

#### សកម្មភាពទី ១ : ការបង្ហាញលទ្ធផលព័ត៌មានដែលប្រមូលបាន

ការបង្ហាញលទ្ធផលព័តិមានដែលបានប្រមូលផ្តល់នូវវេទិកាមួយដល់សិស្សក្នុងការចែករំលែកព័តិមាន ដែលទទួលបានទៅកាន់ថ្នាក់ទាំងមូល ។វាជួយឱ្យសិស្សបំពេញព័តិមានបានពេញលេញអំពីរឿងរ៉ាវដែលគេអាចវិភាគដោយល្អិតល្អន់ និង អាចរកឃើញនូវ ដំណោះស្រាយជាក់ស្តែងចំពោះបញ្ហា ។

**ល្បិចបង្រៀន :**

- ឱ្យក្រុមនីមួយៗបិទរបាយការណ៍ក្រដាស់ផ្ទាំងធំរបស់គេ ដែលបានរៀបចំនៅក្នុងដំណាក់កាលទី ២ ហើយត្រូវប្រាកដថាក្រុមនីមួយៗបានត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ការបង្ហាញ ។
- អញ្ជើញក្រុមនីមួយៗឡើងបង្ហាញលទ្ធផលព័តិមានប្រមូលបានពីសហគមន៍ ( មិនមែនជាគំនិតរបស់ក្រុមទេ) ហើយសមាជិកក្រុម ដទៃទៀតសួរសំណួរ ឬធ្វើការបកស្រាយឱ្យច្បាស់បើសិនជាចាំបាច់ ។
- ចាត់តាំងសមាជិកម្នាក់នៅឈរចាំក្បែរប៉ុស្ទ័ររបស់ខ្លួន ដើម្បីបកស្រាយរាល់ចម្ងល់ផ្សេងៗបើចាំបាច់ ហើយសមាជិកផ្សេងទៀត ដើរមើលរបាយការណ៍របស់ក្រុមដទៃទៀត ។
- បូកសរុបដោយកំណត់នូវលទ្ធផលសំខាន់ៗ និង សរសេរវានៅលើក្រដាស់ផ្ទាំងធំឱ្យបានរួចជាស្រេចសម្រាប់ការវិភាគដើមឈើបញ្ហា ។

## សកម្មភាពទី ២ ៖ ការវិភាគដើមឈើបញ្ហា

ការវិភាគដើមឈើបញ្ហាជួយសិស្សឱ្យចេះប្រើប្រាស់ព័ត៌មានដែលប្រមូលបានពីសហគមន៍ ។ នេះគឺជាវិធីមួយនៃការរៀបបញ្ចូលព័ត៌មានទៅតាមក្រុមដូចជាហេតុ និង ផលនៃបញ្ហាហើយធ្វើការវិភាគដើម្បីទាញបាននូវដំណោះស្រាយប្រក្រតីមួយចំនួនសម្រាប់សកម្មភាពបន្តនៅដំណាក់កាលក្រោយទៀត ។

### ល្បិចបង្រៀន

- ដាក់ក្រដាស់ផ្ទាំងធំនៃព័ត៌មានសំខាន់ៗ ដែលបានរៀបចំក្នុងសកម្មភាពមុន ។
- អាចធ្វើទៅបានដោយក្រុមតូចៗ ឬ ថ្នាក់ទាំងមូលដោយបញ្ចូននូវអ្វីដែលជាព័ត៌មានសំខាន់ៗក្នុងក្រដាស់ផ្ទាំងធំនៃការវិភាគដើម ឈើបញ្ហាដូចបង្ហាញខាងក្រោម ។
- ដឹកនាំការវិភាគដើមឈើ និង ធ្វើឱ្យមានសហសម្ព័ន្ធភាពគ្នារវាងហេតុនិងផលឱ្យកាន់តែស៊ីជម្រៅ ដោយ សួរសំណួរ ហេតុអ្វី? ហេតុអ្វី? ហេតុអ្វី?.....តើយើងគួរធ្វើដូចម្តេច......ប្រសិនបើ....?
- បន្ទាប់មកកំណត់ពណិចំណាំនូវគំនិតសំខាន់ៗ ដើម្បីលើកឡើងជាដំណោះស្រាយនៅជំហានបន្ទាប់ ។
- រក្សាក្រដាស់ផ្ទាំងធំនេះសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពបន្ទាប់ទៀត ។

# គំរូនៃការវិភាគដើមឈើបញ្ហាអំពីចំណាកស្រុក



## គំរូនៃការវិភាគបញ្ហាទូទៅ






## សកម្មភាពទី ៣ ៖ ការកំណត់ដំណោះស្រាយចំពោះបញ្ហា

ដោយផ្អែកលើការវិភាគដើមឈើបញ្ហា សិស្សអាចកំណត់ដំណោះស្រាយបញ្ហាបានច្រើន ។ សកម្មភាពនេះ ផ្តល់ឱកាសឱ្យសិស្សក្នុងការបង្កើតភាពច្នៃប្រឌិត និង ការកែប្រែថ្មីចំពោះបញ្ហា ដែលគេអាចសាកល្បងដោះស្រាយវាបាននៅក្នុងសហគមន៍របស់គេ ។ នេះជាផ្នែកមួយនៃការរៀនសូត្ររបស់សិស្ស ដែលជំរុញឱ្យសមាជិក សហគមន៍រួមចំណែក ក្នុងការដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់គេ ។



**ល្បិចបង្រៀន**

- គ្រូដាក់ក្រដាសផ្ទាំងធំនៃការវិភាគដើមឈើបញ្ហានៅលើក្ដារខៀនឬបើក្រុមនីមួយៗ មានផ្ទាំងវិភាគដើមឈើបញ្ហាផ្ទាល់ខ្លួន ហើយគេត្រូវពឹងផ្អែកលើក្រដាសផ្ទាំងធំនោះ នៅពេលដែលគេបូកសរុបយកដំណោះស្រាយផ្សេងៗ ។
- ដឹកនាំការពិភាក្សាឬឱ្យសិស្សក្នុងក្រុមនីមួយៗពិភាក្សា និង ក្រឡេកមើលហេតុនិងផលប៉ះពាល់ ហើយស្វែងរកនូវដំណោះស្រាយដែលគេអាចធ្វើបានដើម្បីដោះស្រាយបញ្ហា ។ គេអាចគិតរកដំណោះស្រាយឱ្យបានច្រើនតាមតែអាចធ្វើទៅបានដោយ មិនថាតូចឬធំ ឬ មានធនធានឡើយ ។
- ធ្វើបញ្ជីដំណោះស្រាយដែលអាចធ្វើទៅបាននៅលើក្រដាសផ្ទាំងធំ ហើយទុកវាឱ្យបានល្អសម្រាប់សកម្មភាពលើកក្រោយទៀត ។

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្សដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនីមួយៗ ដែលបានបញ្ចប់ ដោយកំណត់សម្គាល់លើបទពិសោធន៍របស់គេ និង អារម្មណ៍របស់គេលើការចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ហើយជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមៈ

1. តើដំណើរការសិក្សានៅក្នុងដំណាក់កាលនេះប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ ?
2. ក្រៅពីខ្លឹមសារមេរៀន តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី ?
3. តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនបានអភិវឌ្ឍបំណិននោះ?
4. តើបំណិនអ្វីខ្លះដែលប្អូនមិនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនមិនបានអភិវឌ្ឍបំណិននោះ?
5. តើពេលក្រោយប្អូនចង់ធ្វើយ៉ាងដូចម្ដេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនមិនទាន់អភិវឌ្ឍ ?

# ដំណាក់កាលទី ៤ : ការរៀបចំផែនការផ្សព្វផ្សាយ

## I. សេចក្តីផ្តើម

ការអភិវឌ្ឍផែនការសកម្មភាពគឺជាដំណាក់កាលមួយ ដែលផ្តល់ឱកាសឱ្យសិស្សនូវអ្វីដែលគេចង់ធ្វើនៅក្នុងសហគមន៍ដោយផ្អែកលើការវិភាគបញ្ហាដែលគេប្រមូលបានពីសហគមន៍ ។ ដំណាក់កាលនេះនឹងជំរុញឱ្យសហគមន៍យល់កាន់តែច្រើនចំពោះបញ្ហា និង ជួយរួមចំណែកដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ជីវិតរបស់គេ ។

**II. គោលបំណង :** សិស្សមានសមត្ថភាពកំណត់ដំណោះស្រាយដែលអាចអនុវត្តជាក់ស្តែង (មួយ ឬ ច្រើន) ដើម្បីដោះស្រាយបញ្ហា និង កសាងផែនការសម្រាប់អនុវត្តន៍ ។

**III. បំណិនសំខាន់ៗដែលនឹងអភិវឌ្ឍ :** បំណិនក្នុងការសម្រេចចិត្ត, បំណិនក្នុងការចាត់អទិភាពបញ្ហា បំណិនធ្វើផែនការ បំណិនការងារក្រុម ទំនុកចិត្តលើខ្លួនឯង និង ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាជាដើម ។

## IV. ល្បិចបង្រៀន :

### សកម្មភាពភាពទី ១: ការជ្រើសរើសដំណោះស្រាយសម្រាប់ការផ្សព្វផ្សាយ

នៅក្នុងដំណាក់កាលទី៣ "ការវិភាគដើមឈើបញ្ហា" សិស្សបានបង្កើតបញ្ជីដំណោះស្រាយបញ្ហារួចមកហើយ ។ ដំណោះស្រាយទាំងអស់ពុំសុទ្ធតែអាចយកប្រើប្រាស់តាមតែយើងអាចគិតបាននោះទេ ពីព្រោះវាអាស្រ័យលើធនធានដែលមាន ។ ដូចនេះត្រូវជ្រើសរើសយកដំណោះស្រាយណា ដែលអាចអនុវត្តបានទៅតាមធនធាន ។

**ល្បិចបង្រៀន**

សកម្មភាពនេះអាចធ្វើជាក្រុមតូចៗ ឬ ក្នុងថ្នាក់ទាំងមូលអាស្រ័យលើគ្រូ ។ ត្រូវប្រមូលដំណោះស្រាយដែលបានកំណត់នៅក្នុងសកម្មភាពលើកមុន ហើយសរសេរវានៅលើតារាងខាងក្រោម បន្ទាប់មកដឹកនាំក្រុមពិភាក្សាក្នុងក្រុមតូចៗឬនៅក្នុងថ្នាក់ទាំងមូលអាស្រ័យទៅលើសំនួរដែលបានណែនាំ ។

| ដំណោះស្រាយ | ធនធានចាំបាច់ | ធនធានដែលមាន | ភាពអាចធ្វើបាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១............<br>២............<br>៣............<br>៤............<br>៥............<br>៦............ | បើសិនជាយើងអនុវត្តដំណោះស្រាយនេះ តើយើងត្រូវការធនធានអ្វីខ្លះ? ដូចជា : ធនធានមនុស្ស-សម្ភារ និង ហិរញ្ញវត្ថុ ជាដើម ។ | តើយើងអាចស្វែងរកធនធានទាំងអស់នេះបានដោយងាយដែរឬទេ? | បើយើងឱ្យពិន្ទុ ៥ ដោយផ្អែកលើការវិនិច្ឆ័យ ។ (ពិន្ទុ ៥ គឺជាពិន្ទុខ្ពស់បំផុតដែលចាត់ទុកថាជាដំណោះស្រាយល្អដើម្បីយកទៅអនុវត្ត ហើយពិន្ទុ ១ ជា ពិន្ទុដែលទាបបំផុត បង្ហាញថាវាពុំមែនជាដំណោះស្រាយ ដែលអាចអនុវត្តបានឡើយ ) ។ | តើយើងចង់អនុវត្តវាយ៉ាងដូចម្តេច? តើអ្នកចង់អនុវត្តវាជាក្រុមតូចឬក្នុងថ្នាក់ទាំងមូល ដូចនេះអ្នកអាចកំណត់ថាតើដំណោះស្រាយចំនួនប៉ុន្មានដែលគួរជ្រើសរើសសម្រាប់សកម្មភាពបន្ទាប់ ។ |

បើយើងចង់រៀបចំសកម្មភាពនេះជាក្រុមតូច នោះត្រូវឱ្យក្រុមទាំងអស់ឡើងបង្ហាញត្រឡប់ ហើយពិភាក្សាអំពីដំណោះស្រាយក្នុងថ្នាក់ទាំងមូល ។ នៅចុងបញ្ចប់នៃការបង្ហាញនេះយើងជ្រើសរើសយកដំណោះស្រាយ ដែលល្អបំផុតសម្រាប់ថ្នាក់ទាំងមូល ឬ ក្រុមតូចៗ ដើម្បីអនុវត្តពេលធ្វើសកម្មភាពផ្សព្វផ្សាយក្នុងទម្រង់ជាការសម្តែងតួ ការធ្វើយុទ្ធនាការផ្សព្វផ្សាយ ការអប់រំមិត្ត ការជជែកជាសាធារណៈ ។ល។

## សកម្មភាពទី ២ ៖ ការរៀបចំផែនការសកម្មភាពសម្រាប់ផ្សព្វផ្សាយ

ការធ្វើផែនការសកម្មភាព គឺជាឯកសារមួយដែលណែនាំអំពីការអនុវត្តឱ្យមានប្រសិទ្ធិភាពនិងសក្តិសិទ្ធ ។ វាអាចជួយឆ្លើយទៅនឹងសំណួរថា ***ហេតុអ្វី? ពេលណា? កន្លែងណា? របៀបណា? និង នរណា?*** សំណួរទាំងអស់នេះនឹងជួយសិស្សឱ្យងាយស្រួលក្នុងការរៀបចំការអនុវត្តរបស់គេ ។

**ល្បិចបង្រៀន**

**ហេតុអ្វីបានជាធ្វើសកម្មភាពផ្សព្វផ្សាយ?**

គោលបំណងទូទៅនៃសកម្មភាពផ្សព្វផ្សាយ គឺដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមសមាជិកសហគមន៍លើបញ្ហាដែលសិស្សបានកំណត់ជាលទ្ធផលនៃការសិក្សាបំណិនជីវិត និង សកម្មភាពស្រាវជ្រាវតូចៗជាមួយក្រុមគោលដៅ ។ ជាលទ្ធផលនៃសកម្មភាពផ្សព្វផ្សាយ យើងសង្ឃឹមថាអ្នកភូមិនឹងផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហា និង ជួយដោះស្រាយបញ្ហាក្នុងសហគមន៍ និង ធ្វើឱ្យសហគមន៍ចេះរួបរួមសាមគ្គីគ្នា ។

**តើសហគមន៍គួរដឹងអ្វីខ្លះ?** លទ្ធផលនៃការវិភាគដើមឈើបញ្ហា យើងអាចវាយតម្លៃពីឫសនៃបញ្ហា ដែលធ្វើឱ្យមានផលអវិជ្ជមានលើសហគមន៍ និង អាចរកដំណោះស្រាយសមរម្យមួយចំពោះបញ្ហាដែលសហគមន៍គួរយល់ដឹង ។

**តើយើងអាចធ្វើសកម្មភាពនៅពេលណា?** សកម្មភាពនេះអាចធ្វើបាននៅចុងបញ្ចប់ប្រធានបទនីមួយៗ ឬ នៅពេលមានព្រឹត្តិការណ៍មួយចំនួន ដូចជានៅទិវាកុមារអន្តរជាតិ ទិវាពលកម្មអន្តរជាតិ ថ្ងៃបុណ្យសិទ្ធិនារី ថ្ងៃបុណ្យចូលឆ្នាំ ឬ ថ្ងៃសម្រាកផ្សេងទៀត ។ល។

**តើគេអាចធ្វើសកម្មភាពនេះនៅកន្លែងណា?** នៅក្នុងសាលារៀន នៅសួនសាធារណៈ នៅក្នុងវត្ត នៅក្នុងភូមិ ។ល។

**តើគេអាចធ្វើសកម្មភាពនេះយ៉ាងដូចម្តេច?** ប្រភេទនៃសកម្មភាពដែលអ្នកចង់ធ្វើ នរណាអាចជួយធ្វើផែនការ និង អាច អនុវត្តសកម្មភាពបាន ធនធានដែលត្រូវការ ។ល។

**តើនរណាជាក្រុមគោលដៅ?** ជនរងគ្រោះដែលត្រូវបណ្តុះការយល់ដឹងដល់អាជ្ញាធរមូលដ្ឋាន និង អ្នកនយោបាយ ដើម្បីឱ្យគេផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហា និង ចាត់វិធានការចំពោះបញ្ហាបុគ្គល ដែលគួរឱ្យគោរពនៅក្នុងសហគមន៍ ដើម្បីទទួលបានការជួយគាំទ្រពីពួកគាត់ ។ល។

**តើត្រូវអញ្ជើញភ្ញៀវតាមវិធីណាដើម្បីឱ្យគាត់ចូលរួមបានច្រើន?** គ្រូណែនាំឱ្យសិស្សសរសេរលិខិតអញ្ជើញ ដោយមានបោះត្រាពីនាយកសាលា ។ បន្ទាប់ឱ្យសិស្សទៅអញ្ជើញដោយផ្ទាល់ (បើមានគ្រូ ឬ លោកនាយកទៅជាមួយជាការ ប្រសើរ) ។

# គំរូសកម្មភាពផ្សព្វផ្សាយតាមសហគមន៍

## ការសម្តែងតួ

ការសម្តែងតួជាសកម្មភាពមួយ ដែលអាចធ្វើបានទាំងក្នុង និង ក្រៅថ្នាក់រៀន ដើម្បីពង្រឹងនូវអ្វីដែលសិស្សបានរៀន ដោយធ្វើឱ្យការរៀនសូត្រកាន់តែមានន័យ ហើយសប្បាយរីករាយ ។ វាពាក់ព័ន្ធជាមួយនឹងការរៀបចំការសម្តែង និង ការឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃការសម្តែងតួ ។

### ១. ការរៀបចំ

- ប្រមូលក្តីបារម្ភរួម និងផលប៉ះពាល់ដែលទាក់ទងទៅនឹងប្រធានបទ ដែលបានវិភាគនៅដំណាក់កាលទី ៣ ។
- សរសេរពីចំណាប់អារម្មណ៍លើបញ្ហា និង ឃ្លាដែលអ្នកសម្តែងត្រូវនិយាយ ។
- សម្ភារដែលចាំបាច់ក្នុងការសម្តែងដើម្បីធ្វើឱ្យកាន់តែចាប់អារម្មណ៍ រួមទាំងរូបភាព និង ស្លាកសញ្ញា... ។
- តើនរណាមានតួនាទីអ្វីក្នុងចំណោមអ្នកសម្តែងតួ និង ហ្វឹកហាត់សម្តែងឱ្យបានល្អ ។

### ២. ការសម្តែង

- ស្វាគមន៍ទស្សនិកជននិងបង្ហាញពីគោលបំណងនៃការសម្តែង ។
- សម្តែងតាមតួរអង្គជាក់ស្តែង ។
- សួរសំណួរទៅកាន់ទស្សនិកជន ឬ យោបល់របស់ទស្សនិកជន ចំពោះការសម្តែង។
- អរគុណចំពោះទស្សនិកជន ។



### ៣. ការឆ្លុះបញ្ចាំង

- តើការសម្តែងនិយាយអំពីអ្វី?
- តើអ្នកគិតថាតួអង្គ "ក" ដូចម្តេចដែរ?
- បើសិនអ្នកជាតួរអង្គ "ក" តើអ្នកគួរធ្វើអ្វី?

# យុទ្ធនាការផ្សព្វផ្សាយ

យុទ្ធនាការផ្សព្វផ្សាយគឺជាសកម្មភាពដែលមានការចូលរួមពីសហគមន៍ជាច្រើន ។ សកម្មភាពនេះត្រូវការធនធាន ការធ្វើផែនការ និង ការរៀបចំដោយប្រុងប្រយ័ត្ន ។ សកម្មភាពនេះអាចរៀបចំធ្វើបាន ១ ឬ ២ ដងក្នុងមួយឆ្នាំ ។ វានឹងទាក់ទាញការចាប់អារម្មណ៍ពី ប្រជាជនច្រើនមុខសញ្ញាក្នុងសហគមន៍ រួមទាំងប្រជាជនសាមញ្ញ អាជ្ញាធរក្នុងតំបន់ អ្នកនយោបាយ និង អ្នកជំនួញ ។ល។

## ១. ការរៀបចំ

- គោលបំណងនៃការធ្វើយុទ្ធនាការផ្សព្វផ្សាយអ្នករៀបចំត្រូវតែស្វែងយល់ ឱ្យបានច្បាស់ ។ បង្កើតគណៈកម្មការរៀបចំដែលជាអ្នកទទួលខុសត្រូវលើអ្វីៗដែលត្រូវធ្វើក្នុងការរៀបចំយុទ្ធនាការផ្សព្វផ្សាយ (តែងតាំងប្រធានដឹកនាំ ដែលអាចបញ្ជាក់ថាអ្វីៗបានត្រៀមលក្ខណៈរួចជាស្រេច មុនធ្វើយុទ្ធនាការផ្សព្វផ្សាយ ដោយចាត់តាំងមនុស្សដើម្បីទទួលខុសត្រូវក្នុងការសុំច្បាប់អនុញ្ញាតិពីអាជ្ញាធរមូលដ្ឋាន អញ្ជើញអ្នកនយោបាយ និង ថ្នាក់ដឹកនាំផ្តល់ព័ត៌មាន ដល់សហគមន៍ពីការផ្សព្វផ្សាយ ជួល ឧគ្ឃោសនស័ព្ទ ភេសជ្ជៈ...) ។
- បង្កើតគណៈកម្មការអភិវឌ្ឍខ្លឹមសារ ដែលជាក្រុមទទួលខុសត្រូវសម្រាប់ការធ្វើយុទ្ធនាការ ហើយពិភាក្សារួមគ្នាលើខ្លឹមសារ អត្ថន័យដែលយើងចង់ស្រែកជ័យឃោសទៅកាន់សហគមន៍ ថាតើយើងចង់ផ្ញើសារឱ្យនរណា តើយើងចង់ធ្វើយុទ្ធនាការផ្សព្វផ្សាយនៅកន្លែងណា តើយើងធ្វើវានៅពេលណា (បង្កើតរបៀបវារៈរួមទាំងពេល វេលា និង ទីកន្លែង) និងថាតើយើងចង់រៀបចំយុទ្ធនាការដោយរបៀបណា ។ល។
- គណៈកម្មការរៀបចំ និង គណៈកម្មការអភិវឌ្ឍខ្លឹមសារត្រូវជួបគ្នាជាមុននៅថ្ងៃធ្វើយុទ្ធនាការផ្សព្វផ្សាយ ហើយពិភាក្សាថា តើពួកគេចង់ធ្វើវាយ៉ាងដូចម្តេច ។

## ២. ការអនុវត្ត

- ធ្វើសេចក្តីប្រកាស និង សេចក្តីណែនាំចំពោះអ្នកចូលរួមអំពីការធ្វើយុទ្ធនាការណែនាំអំពីទិសដៅរយៈពេល និង ទីកន្លែង ដែលត្រូវបញ្ចប់យុទ្ធនាការ ភេសជ្ជៈផ្តល់ជូនតាមផ្លូវពេលដង្ហែ ។ល។



- ចាប់ផ្តើមយុទ្ធនាការ ដោយគ្រប់គ្នាចាប់យកតួនាទី និង ការទទួលខុសត្រូវរបស់ខ្លួនទៅតាមអ្វីដែល បានគ្រោងទុក ។
- អរគុណចំពោះអ្នកចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយ ហើយសង្ឃឹមថាពួកគេនឹងបានចូលរួមនៅពេលក្រោយទៀត ។

### ៣. ការឆ្លុះបញ្ចាំង

- គណៈកម្មការរៀបចំ និង គណៈកម្មការអភិវឌ្ឍខ្លឹមសារ ត្រូវជួបគ្នាដើម្បីឆ្លុះបញ្ចាំងថាតើដំណើការនៃការធ្វើយុទ្ធនាការប្រព្រឹត្តិទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ? តើលើកក្រោយយើងអាចធ្វើវាយ៉ាងដូចម្តេច ។ល។
- រៀបចំនិងសរសេររបាយការណ៍ពីសកម្មភាពទាំងអស់នេះទុកជាឯកសារសម្រាប់ប្រើនៅពេលក្រោយ ។
- សរសេរលិខិតថ្លែងអំណរគុណចំពោះអ្នកដែលជួយធ្វើយុទ្ធនាការនេះឱ្យបានចប់ចុងចប់ដើម និងការចូលរួមសហការនៅពេល ក្រោយទៀត ។

## ការអប់រំមិត្ត

ការអប់រំមិត្ត ជាទម្រង់មួយនៃសកម្មភាពផ្សព្វផ្សាយ ចំពោះមិត្តម្នាក់ទល់ម្នាក់ ឬ ម្នាក់ជាមួយក្រុមតូច ឬ ក្រុមតូចជាមួយនឹងក្រុមធំ ។ល។ គេអាចធ្វើសកម្មភាពនេះបានក្នុងចំណោមសិស្សផងដែរ និង ក្នុងចំណោមយុវជនដែលមិនចូលសាលារៀន ដើម្បីផ្តល់ព័ត៌មានដល់គេជានិច្ចនូវអ្វី ដែលអាចប៉ះពាល់ដល់ពួកគេ ។

### ១. ការរៀបចំ

- រៀបចំសម្ភារអប់រំដែលពាក់ព័ន្ធទៅនឹងប្រធានបទសម្រាប់សកម្មភាព ដោយមានសៀវភៅរឿង ចម្រៀង ពាក្យស្លោក ប័ណ្ណពាក្យ ក្រដាស់ផ្ទាំងធំ ។ល។
- រៀបចំផែនការសកម្មភាពសម្រាប់សកម្មភាពអប់រំមិត្ត តើអ្វីត្រូវធ្វើមុនគេ អ្វីត្រូវធ្វើបន្ទាប់ .... ។
- កំណត់មិត្តដែលត្រូវអប់រំ ហើយបន្ទាប់មកត្រូវទាក់ទងជាមួយគេឱ្យបានមុន ។

### ២.ការអនុវត្ត



- ណែនាំខ្លួនចំពោះមិត្តដែលត្រូវអប់រំ និង គោលបំណងនៃសកម្មភាព ។
- ធ្វើឱ្យមិត្តដែលត្រូវអប់រំចាប់អារម្មណ៍នឹងប្រធានបទ ដោយលើកឡើងនូវសារៈសំខាន់ និង ផលប៉ះពាល់លើពួកគេ ។
- បង្ហាញប្រធានបទ និង ពិភាក្សាឱ្យបានស៊ីជម្រៅលើប្រធានបទ តាមរយៈសំណួរ ហេតុអ្វី? អ្វីនឹង កើតឡើង ប្រសិនបើ..........? ។ល។
- ធ្វើសេចក្តីសង្ខេបនៅចុងបញ្ចប់ និង ធ្វើសេចក្តីសន្និដ្ឋាន តើព័ត៌មាននេះជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះចំពោះជីវិតគេ ។
- អរគុណចំពោះមិត្តដែលបានរៀនជាមួយយើងអំពីប្រធានបទ និងសង្ឃឹមថានឹងបានជួបគ្នាទៀតនៅពេលក្រោយ ។

## ៣. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធន៍អ្វីខ្លះ ? ។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលំអរយ៉ាងណាទៀតនៅពេលក្រោយ ?

## វេទិកាសាធារណៈ

វេទិកាសាធារណៈជាសកម្មភាពមួយ ដែលផ្តល់ឱកាសដល់មនុស្សដែលមានបទពិសោធន៍ និង ទស្សនៈខុសៗគ្នា ដើម្បីចែករំលែកគំនិត និង យោបល់លើប្រធានបទជាក់លាក់មួយ ។ អ្នករៀបចំសកម្មភាព អាចមានសំនួរណែនាំ និង ព័ត៌មានទាន់ហេតុការណ៍ ដែលគេបានចំណាយពេលក្នុងការសិក្សាលើប្រធានបទនោះ ។



## ១. ការរៀបចំ

- អភិវឌ្ឍផែនទីគំនិត ឬពិនិត្យលើការចងក្រងប្រធានបទ និងរៀបចំឱ្យបានលំអិត ។
- កំណត់ទីកន្លែងសម្រាប់ធ្វើវេទិកា និងរៀបចំលិខិតអញ្ជើញ ។
- កំណត់មុខសញ្ញាវាគ្មិន ដែលត្រូវអញ្ជើញចូលរួមក្នុងវេទិកា និង ផ្តល់ព័ត៌មានដល់គេអំពីប្រធានបទដែលនឹង ត្រូវពិភាក្សា និង ចែករំលែក ដើម្បីគេអាចត្រៀមលក្ខណៈបានល្អក្នុងការជជែកពិភាក្សា ។
- ធ្វើសេចក្តីប្រកាសជាសារធារណៈ ដើម្បីឱ្យសហគមន៍អាចចូលរួមក្នុងវេទិកានេះ ។

## ២. ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និង ភ្ញៀវកិត្តិយស ។
- ណែនាំប្រធានបទ និង គោលបំណងនៃវេទិកាពិភាក្សា ។
- បើកវេទិកាពិភាក្សាជាសាធារណៈ និង អញ្ជើញវាគ្មិនបញ្ចេញគំនិត ។
- បើកវេទិកាសំណួរ-ចម្លើយ ។
- បូកសរុប និង អរគុណចំពោះអ្នកចូលរួម ។

## ៣. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធន៍អ្វីខ្លះ? ។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលំអយ៉ាងណាទៀតនៅពេលក្រោយ ។

## ការជជែកដេញដោល

ការជជែកដេញដោលគឺជាទម្រង់នៃសកម្មភាពមួយទៀតស្រដៀងគ្នាទៅនឹងវេទិកាសាធារណៈដែរ ប៉ុន្តែវាជំរុញឱ្យមានការពិភាក្សាទៅលើប្រធានបទមួយ ដែលមានទស្សនៈពីរផ្ទុយគ្នាស្រឡះ ដែលលើកឡើងដោយក្រុមគាំទ្រផ្សេងៗ គ្នា ។ ឧទាហរណ៍មានក្រុមចំនួនពីរនឹងជជែកលើប្រធានបទ ដែលទាក់ទងនឹងការអប់រំកុមារី ហើយក្រុមនីមួយៗ ត្រូវគាំទ្រគំនិតផ្ទាល់ខ្លួនរបស់គេ ។ ក្រុមមួយអាចគាំទ្រ លើគំនិត "ស្ត្រីមិនចាំបាច់រៀនជ្រៅជ្រះទេព្រោះ....." ក្រុមមួយទៀតគាំទ្រគំនិត "ស្ត្រីត្រូវតែរៀនឱ្យបានជ្រៅជ្រះ..." ។

### ១. ការរៀបចំ

- រៀបចំក្រុមចំនួនពីរដើម្បីធ្វើការងារលើប្រធានបទជាមួយនឹងគំនិតពីរដែលខុសគ្នា ក្រុមមួយគាំទ្រគំនិតមួយ ។
- កំណត់ទីកន្លែងសម្រាប់ ជជែកដេញដោលនិងធ្វើសេចក្តីប្រកាសជាសាធារណៈដើម្បីគេអាចចូលរួមក្នុងការស្តាប់ ។
- កំណត់អ្នកដែលត្រូវអញ្ជើញចូលរួមក្នុងការជជែកដេញដោល និង ផ្តល់ព័ត៌មានដល់គេអំពីប្រធានបទដែលនឹងត្រូវជជែកដើម្បីគេអាចរៀបចំវាបានប្រសើរ ។

### ២. ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និង ភ្ញៀវកិត្តិយស ។
- ណែនាំប្រធានបទ និងគោលបំណងនៃការជជែកពិភាក្សា ។
- សួរអ្នកចូលរួមតើគំនិតមួយណាដែលគេគាំទ្រ (ដើម្បីពិនិត្យមើលការវិវត្តនៃការគិតរបស់គេ នៅចុងបញ្ចប់នៃវេទិកា) ហើយ ចាប់ផ្តើមការជជែក ។
- នៅចុងបញ្ចប់នៃការជជែក សួរអ្នកចូលរួមថា តើគេអាចផ្លាស់ប្តូរគំនិតរបស់គេទៅគាំទ្រគំនិតមួយទៀតដែរទេ ? ហើយសួរហេតុអ្វី ? ។
- បូកសរុប និង អរគុណចំពោះអ្នកចូលរួម ។

### ៣. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធន៍អ្វីខ្លះ? ។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលំអយ៉ាងណាទៀតនៅពេលក្រោយ ។

## និវាបង្ហាញ

ទិវាបង្ហាញជាសកម្មភាពមួយដែលរៀបចំឡើងដោយនាយក គ្រូ សិស្ស ដើម្បីផ្តល់ឱកាសឱ្យសិស្សបង្ហាញស្នាដៃ និង អ្វីដែលគេបានរៀនទៅដល់សហគមន៍។ ទិវាបង្ហាញនេះជាសកម្មភាពលើកទឹកចិត្តដល់សិស្សក្នុងការរៀនសូត្រ និង ជំរុញឱ្យមានការគាំទ្រ និង ចូលរួមពីសហគមន៍កាន់តែច្រើនថែមទៀត ជាពិសេសអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យពួកគេចូលរួម បំពេញការងារមួយចំនួនដែលជាតម្រូវការ និង ការចង់បានរបស់សិស្ស។ ម្យ៉ាងទៀតសកម្មភាពបង្ហាញនេះវាជាការ លើកកម្ពស់សមត្ថភាពសិស្សក្នុងការប្រើប្រាស់ ហើយ ចែករំលែកចំណេះដឹង និង បទពិសោធន៍សម្រាប់ដោះស្រាយបញ្ហា ងាយៗដែលកើតមាននៅក្នុងសហគមន៍។

### ១. ប្រភេទស្នាដៃ

- ការសរសេរពាក្យស្លោក ការសរសេរកំណាព្យ ចម្រៀង គំនូរ ករណីសិក្សា ការសម្តែងតួ

### ២. ការរៀបចំ

- កំណត់ពីគោលបំណង ខ្លឹមសារ សម្ភារ និង សកម្មភាព/វិធីសាស្ត្របង្ហាញ ។
- កំណត់មុខសញ្ញាដែលត្រូវអញ្ជើញចូលរួមក្នុងទិវាបង្ហាញ និង ផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន ដើម្បីសុំការអនុញ្ញាត និង ចូលរួមគាំទ្រ។
- កំណត់កាលបរិច្ឆេទ ទីកន្លែងសម្រាប់ធ្វើទិវាបង្ហាញ និង រៀបចំលិខិតអញ្ជើញអ្នកដែលត្រូវចូលរួម ។
- ផ្សព្វផ្សាយព័ត៌មានជាសារធារណៈ ដើម្បីឱ្យសហគមន៍អាចចូលរួមក្នុងវេទិកានេះ ។



### ៣. ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និង ភ្ញៀវកិត្តិយស ។
- ណែនាំគោលបំណង និង ខ្លឹមសារនៃទិវាបង្ហាញ ។
- បើកកម្មវិធី និង អញ្ជើញគណៈអធិបតីឡើងថ្លែងសន្ទរកថា។
- សកម្មភាពបង្ហាញរបស់ក្រុមសិស្ស។
- វេទិកាសំណួរចម្លើយ រវាងក្រុមសិស្ស និង អ្នកចូលរួម
- ចំណាប់អារម្មណ៍ និង អនុសាសន៍របស់គណៈអធិបតី
- បូកសរុប និង អរគុណចំពោះអ្នកចូលរួម ។

### ៤. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធន៍អ្វីខ្លះ? ។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលំអរយ៉ាងណាទៀតនៅពេលក្រោយ ។

**កំណត់សម្គាល់ :** ទិវាបង្ហាញនេះមានខ្លឹមសារ និង គោលបំណងដូចគ្នានឹងពិព័រណ៍ស្នាដៃសិស្សដែរដូចនេះ នាយក-គ្រូអាចយកខ្លឹមសារ និង សកម្មភាពទិវាបង្ហាញនេះទៅធ្វើនៅក្នុងពិព័រណ៍ស្នាដៃសិស្សក្នុងកម្មវិធីសាលាកុមារមេត្រីដើម្បីបង្ហាញពីស្នាដៃបំណិនជីវិតរបស់សិស្ស និង សារប្រយោជន៍នៃការរៀនបំណិនជីវិតទៅដល់អ្នកចូលរួមក្នុងគោលបំណង ធ្វើឱ្យមានការចូលរួម និង គាំទ្រកាន់តែច្រើនទៅលើសកម្មភាពរៀនសូត្របំណិនជីវិតរបស់សិស្ស ។

## សកម្មភាពទី ៣ : ការបង្ហាញផែនការ

ការបង្ហាញផែនការផ្តល់ឱកាសឱ្យសិស្សពីក្រុមផ្សេងៗគ្នាដើម្បីចែករំលែក និង ពិភាក្សាផែនការផ្ទាល់ខ្លួនរបស់គេ និង ដើម្បីទទួលអនុសាសន៍ពីគ្នាទៅវិញទៅមក ។ សកម្មភាពនេះជំរុញការគិតដោយវិភាគ និង លិ្បតល្បន់លើដោះស្រាយបញ្ហានិងជំនាញធ្វើផែនការ ។

### ល្បិចបង្រៀន

- បន្ទាប់ពីក្រុមបានបញ្ចប់ផែនការសកម្មភាពរបស់គេ (អាចជាគំរូសកម្មភាពខាងលើ) គេត្រូវបង្ហាញទៅក្រុមផ្សេងទៀតដើម្បីផ្តល់អនុសាសន៍ និង សំណូមពរ ។
- គ្រូត្រូវជំរុញលើកទឹកចិត្តឱ្យក្រុមផ្សេងទៀតសួរសំណួរ ដោយបញ្ជាក់ថាតើផែនការនោះជាក់លាក់ និង សម្រេចបានទេ ។ សំណួរគួរផ្តោតជុំវិញ :

  ○តើអនុវត្តផែនការដូចម្តេច? នរណាពាក់ព័ន្ធនៅក្នុងសកម្មភាព? តើធ្វើយ៉ាងណាដើម្បីឱ្យគេចូលរួមក្នុងសកម្មភាព?

  ○តើមានធនធានអ្វីខ្លះ ? (ធនធានសម្ភារ និង ធនធានមនុស្សដែលចាំបាច់សម្រាប់សកម្មភាព) ។

  (តើនរណាទទួលខុសត្រូវធ្វើភារកិច្ចនីមួយៗ? (លិខិតអញ្ជើញ អភិវឌ្ឍសម្ភារ រៀបចំប្រដាប់ប្រដារ...)

  (តើអ្នកត្រូវរៀបចំអ្វីខ្លះដែលអ្នកត្រូវការសម្រាប់ធ្វើសកម្មភាព ? តើមានពេលគ្រប់គ្រាន់ទេ?

  (តើអ្នកធ្វើវានៅឯណា? តើវេទិកាបានកក់ទុកហើយឬទេ?
- បន្ទាប់ពីបានទទួលអនុសាសន៍ និង សំណូមពររួច ហើយក្រុមដែលបានឡើងបង្ហាញផែនការត្រូវពិចារណា និង ពិនិត្យផែនការឡើងវិញបើសិនជាចាំបាច់ ។

## សកម្មភាពទី ៤ : ការរៀបចំសម្រាប់ការអនុវត្តផែនការ

ការរៀបចំសម្រាប់ការអនុវត្ត អនុញ្ញាតឱ្យសមាជិកក្រុមចាប់ផ្តើមធ្វើការងារលើកិច្ចការរបស់គេ និង ធ្វើឱ្យប្រាកដថាបានត្រៀមលក្ខណៈរួចរាល់ហើយសម្រាប់សកម្មភាពផ្សព្វផ្សាយដូចដែលបានគ្រោងទុក ។

**ល្បិចបង្រៀន**

- កំណត់ពេលវេលាដើម្បីធ្វើលើកិច្ចការ ។
- អភិវឌ្ឍសម្ភារដែលត្រូវការសម្រាប់ធ្វើសកម្មភាព ។
- ហ្វឹកហាត់ក្នុងការអនុវត្តផែនការសកម្មភាព ។
- ផ្តល់ព័ត៌មានដល់ប្រជាជនដែលពាក់ព័ន្ធនឹងសកម្មភាព ។
- ពេលវេលាសម្រាប់អនុវត្ត ។

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្សដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនីមួយៗ ដែលបានបញ្ចប់ ដោយកំណត់សម្គាល់លើបទពិសោធន៍របស់គេ និង អារម្មណ៍របស់គេលើការចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ ។គ្រូអាចសួរសំណួរងាយៗដូចខាងក្រោម:

- តើដំណើរការសិក្សានៅក្នុងដំណាក់កាលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ ?
- ក្រៅពីខ្លឹមសារមេរៀន តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី ?
- តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនបានអភិវឌ្ឍបំណិននោះ?
- តើបំណិនអ្វីខ្លះដែលប្អូនមិនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនមិនបានអភិវឌ្ឍបំណិននោះ?
- តើពេលក្រោយប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនមិនទាន់អភិវឌ្ឍ ?

## ដំណាក់កាលទី ៥ : ការអនុវត្តផែនការផ្សព្វផ្សាយនៅតាមសហគមន៍

### I. សេចក្តីផ្តើម

ការអនុវត្តផែនការ អនុញ្ញាតិឱ្យសិស្សមានទំនាក់ទំនងជាមួយសហគមន៍ ចូលរួមក្នុងការដោះ ស្រាយបញ្ហា ដែលអាចជះឥទ្ធិពលដល់ជីវិតរស់នៅរបស់គេ និងដើម្បីជំរុញការយល់ដឹងផងដែរអំពីសារៈសំខាន់នៃការអប់រំ ។វាក៏ផ្តល់ឱកាសឱ្យសិស្សផងដែរក្នុងការធ្វើអន្តរកម្មជាមួយសហគមន៍ ហើយធ្វើឱ្យការរៀនសូត្រកាន់តែមានភាពជាក់ស្តែង និងមានសារៈសំខាន់សម្រាប់ជីវិតរបស់គេ ។

### II. គោលបំណង

សិស្សមានសមត្ថភាពអនុវត្តតាមដំណោះស្រាយដែលគេជ្រើសរើសតាមទម្រង់សកម្មភាពផ្សព្វផ្សាយ និងចូលរួម ដើម្បីដោះស្រាយបញ្ហាដែលមាននៅតាមមូលដ្ឋាន ។

**III. បំណិនចាំបាច់ដែលនឹងអភិវឌ្ឍ :** បំណិនទំនាក់ទំនង បំណិនអន្តរបុគ្គល បំណិនក្នុងការរៀបចំ បំណិនជាក់ស្តែងក្នុងការអនុវត្តផែនការ បំណិនជជែកពិភាក្សា ទំនុកចិត្តលើខ្លួនឯង ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា ។

### IV. ល្បិចបង្រៀន

### សកម្មភាពទី ១ : ការអនុវត្តផែនការផ្សព្វផ្សាយ

វាជាការសំខាន់ណាស់ ក្នុងការណែនាំដល់អ្នកចូលរួមមុនពេលចាប់ផ្តើមសកម្មភាព ។ ការណែនាំរួមមានក្រុមអ្នកដែលត្រូវចូលរួម គោលបំណងនៃព្រឹត្តិការណ៍ដើម្បីឱ្យអ្នកចូលរួមបានដឹងអំពីប្រធានបទ ។ល។ ការធ្វើបែបនេះ អ្នកចូលរួមនឹងសហការយ៉ាងសកម្មក្នុងសកម្មភាព ហើយទទួលយកដោយពេញចិត្ត ។

ល្បិចបង្រៀន

ក. ការចាប់ផ្តើម

- អ្នករៀបចំត្រូវមកកាន់កន្លែងជួបជុំឱ្យបានមុនគេ ហើយរៀបចំអ្វីៗមុនពេលសកម្មភាព ចាប់ផ្តើម ។
- ស្វាគមន៍អ្នកចូលរួម និង ថ្លែងអំណរគុណចំពោះការចំណាយពេលដ៏មានតម្លៃរបស់ពួកគេ ។
- ណែនាំប្រជាជនទាំងអស់ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នេះ ។
- សង្ខេបពីគោលបំណងនៃសកម្មភាព និង វាយតម្លៃអ្វីដែលអ្នកចូលរួមបានដឹង ។

## ខ. ការអនុវត្តសកម្មភាព

- ចាប់ផ្ដើមការបង្ហាញ និង ធ្វើសកម្មភាពទៅតាមផែនការដោយផ្អែកលើអ្វីដែលអ្នកចូលរួមបានដឹង ហើយបន្ទឹទៅនឹងផែនការដែលបានគ្រោង ។

## គ. ការផ្ដល់ព័ត៌មានត្រឡប់

- សុំយោបល់ពីអ្នកដែលបានចូលរួមលើសកម្មភាពកន្លងមក តាមរយៈការសួរសំណួរដូចខាងក្រោម ៖
  - ○តើការបង្ហាញនិយាយអំពីអ្វី?
  - ○តើនឹងមានអ្វីកើតឡើងបើសិន.....?
  - ○តើបញ្ហានេះវានឹងជះឥទ្ធិពលដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច?
  - ○តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីដោះស្រាយវា?

# V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ជាការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្សដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនីមួយៗ ដែលបានបញ្ចប់ដោយកំណត់សម្គាល់លើបទពិសោធន៍របស់គេ និង អារម្មណ៍របស់គេលើការចូលរួមគ្រប់សកម្មភាពទាំងអស់ នៅក្នុងដំណាក់កាលនេះ ហើយជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោម៖

- តើដំណើរការសិក្សានៅក្នុងដំណាក់កាលនេះប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ ?
- ក្រៅពីខ្លឹមសារមេរៀន តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី ?
- តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនបានអភិវឌ្ឍបំណិននោះ?
- តើបំណិនអ្វីខ្លះដែលប្អូនមិនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនមិនបានអភិវឌ្ឍបំណិននោះ?
- តើពេលក្រោយប្អូនចង់ធ្វើយ៉ាងដូចម្ដេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនមិនទាន់អភិវឌ្ឍ ?

# ដំណាក់កាលទី ៦ ៖ ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយ

## I. សេចក្តីផ្តើម

ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយផ្តល់ឱកាសឱ្យសិស្សអង្គុយជុំគ្នា ពិភាក្សាលើអ្វីដែលគេបានធ្វើនៅក្នុងសហគមន៍ដើម្បីរៀនសូត្រ និង រិះរកមធ្យោបាយកែលំអសកម្មភាពឱ្យបានប្រសើរសម្រាប់លើកក្រោយ ។ វាជាបំណិនរៀនសូត្រដ៏មានសារៈសំខាន់ដែលបុគ្គលគ្រប់រូបត្រូវធ្វើការកែលំអជីវិតរបស់គេឱ្យបានប្រសើរ ។

**II. គោលបំណង:** លើកទឹកចិត្តសិស្សដើម្បីឆ្លុះបញ្ចាំង និង រៀនពីបទពិសោធន៍ក្នុងការអនុវត្តសកម្មភាពតាមមូលដ្ឋាន ។

**III. បំណិនចាំបាច់ដែលនឹងអភិវឌ្ឍ:** បំណិនវិភាគ បំណិនគិតដោយល្អិតល្អន់ ការជឿជាក់លើខ្លួនឯង ការស្គាល់ខ្លួនឯង និង ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា ។

## IV. ល្បិចបង្រៀន

### សកម្មភាពទី ១ ៖ ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយ

ការឆ្លុះបញ្ចាំង គឺជាបំណិនរៀនសូត្រដ៏មានសារៈសំខាន់មួយ ដែលជួយឱ្យបុគ្គលគ្រប់រូបត្រូវចៀសវាងកំហុសដដែលៗ ។ វាជំរុញឱ្យមានការគិត និង វិភាគដោយហ្មត់ចត់ ហើយនឹងអាចទាញយកបាននូវគំនិត និងដំណោះស្រាយល្អប្រសើរសម្រាប់ជីវិតរបស់យើង ។ សកម្មភាពនេះអាចធ្វើឡើងបន្ទាប់ពីការផ្សព្វផ្សាយភ្លាមៗ ដោយក្រុមនីមួយៗ (ប្រសិនបើរៀបចំដោយក្រុម) ឬ រៀបចំនៅក្នុងថ្នាក់ដោយគ្រូ ដើម្បីឱ្យក្រុមទាំងអស់បានចែករំលែកបទពិសោធន៍របស់គេ ។

**ល្បិចបង្រៀន**

- ការឆ្លុះបញ្ចាំងឡើងវិញលើសកម្មភាព ដែលបានអនុវត្តត្រូវផ្តោតលើសំណួរដូចខាងក្រោម ។

**១. លទ្ធផលសម្រេចបាន និង ដំណោះស្រាយ:**

ក. តើការអនុវត្តនេះសម្រេចបានតាមគោលបំណងផែនការដែរឬទេ?

ខ. តើចំណុចខ្លាំង និង ឧបសគ្គក្នុងការអនុវត្តផែនការមានអ្វីខ្លះ?

គ. តើបានដោះស្រាយបញ្ហាដែលប្រឈមក្នុងពេលអនុវត្តសកម្មភាពយ៉ាងដូចម្តេច?

ឃ. តើចំនុចដែលចាំបាច់ត្រូវកែលំអសម្រាប់ការផ្សព្វផ្សាយលើកក្រោយមានអ្វីខ្លះ?. តើគួរកែលំអដោយរបៀបណា?

**២. ការចូលរួមរបស់សហគមន៍:**

○ការតាមដានដោយយកចិត្តទុកដាក់លើការបង្ហាញ ។

○ការសួរសំណួរនៅពេលចប់ការសម្តែង។ .

**៣. ការសម្តែង និង ការងារក្រុម:**

○ទំនុកចិត្ត និង ការសម្តែងរបស់សមាជិកម្នាក់ៗ ។

○ការសហការរបស់ក្រុម ។

- ក្រុមនីមួយៗបង្ហាញលទ្ធផលការងាររបស់គេដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ខាងលើ ហើយសួរក្រុមផ្សេង ទៀត(បើមាន) នៅចុងបញ្ចប់នៃការបង្ហាញ ដើម្បីឱ្យគេផ្តល់អនុសាសន៍ និង សំណូមពរ ។
- ត្រូវកំណត់ចំណុចទាំងឡាយណាដែលត្រូវកែលំអ ក្នុងការធ្វើផែនការរបស់គេក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ពេលដែលគេរៀបចំការងារក្នុងសហគមន៍ម្តងទៀត ។

## សកម្មភាពទី ២ : ការសរសេររបាយការណ៍

ការសរសេររបាយការណ៍ជាទម្រង់មួយនៃការកសាងឯកសារដោយកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗ និងអ្វីដែលបានពិភាក្សានៅពេលឆ្លុះបញ្ចាំងក្នុងសកម្មភាពទី១។ របាយការណ៍នឹងប្រើជាឯកសារយោងនៅពេលរៀបចំសកម្មភាពផ្សព្វផ្សាយលើកក្រោយ ។

**ល្បិចបង្រៀន**

គ្រូអាចណែនាំសិស្សពីទម្រង់ និង

ខ្លឹមសារគោលក្នុងការសរសេររបាយការណ៍ដោយផ្តោតយកតាមលំនាំដូចខាងក្រោម។

**១. សេចក្តីផ្តើម :**

រៀបរាប់ការសម្រេចចិត្តក្នុងការជ្រើសរើសសកម្មភាពមកផ្សព្វផ្សាយនិងគោលបំណងដោយផ្អែកលើការយល់ដឹងពី ប្រធានបទ ការយល់ដឹងរបស់សហគមន៍ ការវិភាគដើមឈើបញ្ហា និង ដំណោះស្រាយ ។

**២. តួសេចក្តី :** រៀបរាប់ពីដំណើរការ និង គំនិតសំខាន់ៗ នៃការផ្សព្វផ្សាយ ដោយ :

○វាយតម្លៃពីការអនុវត្តផែនការផ្សព្វផ្សាយ

○វាយតម្លៃពីការចូលរួមរបស់សហគមន៍

○វាយតម្លៃសមត្ថភាពរបស់ក្រុមក្នុងការរៀបចំសកម្មភាព

**៣. សេចក្តីបញ្ចប់ :**

1. ទាញសេចក្តីសន្និដ្ឋានរួម
2. អនុសាសន៍

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្សដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនីមួយៗ ដែលបានបញ្ចប់ ដោយកំណត់សម្គាល់លើបទពិសោធន៍របស់គេ និង អារម្មណ៍របស់គេលើការចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ហើយជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ ។ គ្រូអាចសួរនូវសំណួរងាយៗ ដូចខាងក្រោម:

- តើដំណើរការសិក្សានៅក្នុងដំណាក់កាលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ ?
- ក្រៅពីខ្លឹមសារមេរៀន តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនទេ? ហេតុអ្វី ?
- តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនបានអភិវឌ្ឍបំណិននោះ?
- តើបំណិនអ្វីខ្លះដែលប្អូនមិនបានអភិវឌ្ឍ? តើប្អូនធ្វើយ៉ាងណាទើបដឹងថាប្អូនមិនបានអភិវឌ្ឍបំណិននោះ?
- តើពេលក្រោយប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនមិនទាន់អភិវឌ្ឍ ?

# ជំពូកទី ៤ : ការវាយតម្លៃការបង្រៀន និង រៀនកម្មវិធីបំណិនជីវិត

## ១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃ

**ការវាយតម្លៃមានសារៈសំខាន់ទាំងការបង្រៀន និងការរៀន** ។ មនុស្សគ្រប់រូបបារម្ភពីការវាយតម្លៃ រាប់បញ្ចូលទាំងសិស្ស គ្រូបង្រៀន ឪពុកម្តាយ អ្នកគ្រប់គ្រង និងគ្រូអធិការ ។ ដូចនេះពួកគេត្រូវតែយល់ឱ្យបានច្បាស់ពីហេតុផលនៃការវាយតម្លៃអ្វីដែលត្រូវវាយតម្លៃ លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលបានជោគជ័យ និងវិធីដែលប្រើក្នុងការវាយតម្លៃ ។ **ត្រូវចាំថាគោលបំណងនៃការបង្រៀន និង ការវាយតម្លៃ គឺដើម្បីនាំសិស្សទៅកាន់ភាពជោគជ័យ មិនមែនបរាជ័យឡើយ ។**

ទាំងសិស្ស និង គ្រូគួរតែសកម្មនៅក្នុងការវាយតម្លៃពីភាពរីកចម្រើនរបស់សិស្ស ដែលជាផ្នែកមួយនៃការអភិវឌ្ឍបំណិនក្នុងការគិតឱ្យបានល្អិតល្អន់ និងអភិវឌ្ឍបំណិននៃការវាយតម្លៃដោយខ្លួនឯង ។ គ្រូគួរតែបារម្ភផងដែរ ពីការវាយតម្លៃគុណភាពកម្មវិធីសិក្សា ។

រង្វាយតម្លៃគឺជាការប្រមូល និង វិភាគព័ត៌មានអំពីលទ្ធផលនៃការសិក្សារបស់សិស្ស ។ វាបញ្ជាក់ពីអ្វីដែលសិស្សបានចេះយល់ អាចធ្វើបាន និងអារម្មណ៍របស់ពួកគេនៅដំណាក់កាលផ្សេងៗក្នុងលំនាំនៃការរៀន ។ តាមរយៈការវាយតម្លៃអំពីការរីកចម្រើននៃការសិក្សារបស់សិស្សជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធគ្រូអាចស្វែងយល់ពីអ្វីដែលសិស្សបានរៀន និង ធ្វើការសម្រេចចិត្តបាន ត្រឹមត្រូវពីការបង្រៀនរបស់គាត់ ។ ការវាយតម្លៃផ្តោតទៅលើការយល់ និង ការលើកកម្ពស់ការសិក្សារបស់សិស្ស ។

- គ្រូត្រូវតែផ្តល់ឱកាសដល់សិស្ស ដើម្បីឱ្យពួកគេបង្ហាញពីអ្វីដែលពួកគេចេះ និង អ្វីដែលពួកគេអាចធ្វើបានទៅតាមរបៀបផ្សេងៗគ្នា។
- គ្រូចាំបាច់ត្រូវកំណត់ភស្តុតាងចាំបាច់ដែលបង្ហាញថា សិស្សអាចសម្រេចបានតាមអ្វីដែលរំពឹងទុក ។ វាមានសារៈសំខាន់ណាស់ក្នុងការជ្រើសរើសវិធីសាស្ត្រវាយតម្លៃ ដែលនឹងផ្តល់នូវភស្តុតាងនោះ ។
- គ្រូគួរតែជ្រើសរើសឧបករណ៍រង្វាយតម្លៃ ដែលអាចយកជាការបាន អាចទុកចិត្តបាន ត្រឹមត្រូវ ហើយត្រូវនឹងគោលបំណងសម្រាប់រង្វាយតម្លៃ ។ ឧទាហរណ៍ៈ ការសរសេរ ការកត់ត្រាជាប្រចាំ ដើម្បីវាយតម្លៃយុទ្ធវិធី ក្នុងការអានការវាយតម្លៃការប្រតិបត្តិជាក់លាក់របស់សិស្សការសង្កេត និងកត់ត្រាដើម្បីវាយតម្លៃបំណិនក្នុងការពិភាក្សាតាមក្រុមតូចៗ ។ល។
- នៅពេលណាសមស្រប គ្រូគួរតែប្រាប់សិស្សនូវប្រធានបទដែលត្រូវវាយតម្លៃមុនពេលរង្វាយតម្លៃ និង ចំណុចដែលត្រូវវាយតម្លៃ ។
- គ្រូគួរតែផ្តល់ព័ត៌មានត្រឡប់ទៅឱ្យសិស្សជាប្រចាំ រួមទាំងលទ្ធផលរង្វាយតម្លៃ ដើម្បីបន្តជួយជំរុញការរៀនសូត្ររបស់សិស្ស។
- ទម្រង់នៃការវាយតម្លៃគួរតែផ្លាស់ប្តូរឱ្យបានញឹកញាប់ ដើម្បីឱ្យសិស្សដែលមានរបៀបរៀន(ស្ទីលនៃការរៀន)ខុសៗគ្នាមានឱកាសទទួលបានជោគជ័យក្នុងការសិក្សារបស់គេ ។

**ជាទូទៅការវាយតម្លៃមានពីរប្រភេទៈ**

### ក. ការវាយតម្លៃតាមដំណាក់

ការវាយតម្លៃតាមដំណាក់ពាក់ព័ន្ធទៅនឹងដំណើរការរៀនសូត្រប្រចាំថ្ងៃ ហើយវាជួយគ្រូ និងសិស្សឱ្យកំណត់បានពីអ្វីដែលគេបានរៀន និងចេះ ដើម្បីធ្វើផែនការបង្រៀន និងរៀននៅពេលបន្ទាប់ទៀត។ ការវាយតម្លៃតាមដំណាក់ និងការបង្រៀន វាមានទំនាក់ទំនងនឹងគ្នា គ្មានមួយណាអាចធ្វើទៅបានតែឯងនោះទេ។ ការវាយតម្លៃបែបនេះ វាជាការពិនិត្យតាមដានលើការរីកចម្រើននៃការសិក្សាក្នុងគោលបំណងធ្វើឱ្យគ្រូ និងសិស្សដឹងពីភាពរីកចម្រើនទាក់ទងនឹងការបង្រៀន និងរៀន ដើម្បីធ្វើយ៉ាងណាផ្លាស់ប្តូរវិធីបង្រៀន និងរៀន ។ វាជាការផ្តល់ឱកាសឱ្យគ្រូកែតម្រូវល្បឿននៃការបង្រៀន និងកម្រិតនៃការរៀនរបស់សិស្ស។ រង្វាយតម្លៃតាមដំណាក់អាចជាការសង្កេតប្រចាំថ្ងៃ ការជជែកពិភាក្សាជាក្រុម ការសួរសំណួរ ការបំពេញការងារ របស់សិស្ស និងការអង្កេតរបស់គ្រូលើសកម្មភាពប្រែប្រួលរបស់សិស្សម្នាក់ៗ នៅចុងបញ្ចប់ដំណាក់កាល នីមួយៗនៃប្រធានបទ។

### ខ. ការវាយតម្លៃសរុប

រង្វាយតម្លៃសរុបធ្វើឡើងនៅចុងបញ្ចប់នៃខ្លឹមសារមេរៀនថ្មីមួយ ឬ ម៉ូឌុលមួយ។ ការវាយតម្លៃសរុបនេះវាជួយឱ្យគ្រូ និង សិស្សកំណត់បានថាតើការបង្រៀន និងរៀន របស់គេសម្រេចបានតាមវត្ថុបំណងជាក់លាក់នៃមេរៀន ឬ ក៏អត់ និង ការរីកចម្រើនរបស់សិស្សជារួម។ ម្យ៉ាងទៀតវាជួយប្រាប់ពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ រង្វាយតម្លៃសរុបត្រូវបាន គេប្រើៈ

- សម្រាប់ការទទួលខុសត្រូវក្នុងការគ្រប់គ្រងថ្នាក់រៀន ការបង្រៀន និងរៀន។
- ដើម្បីឱ្យសិស្សដឹងថាពួកគេសម្រេចបានតាមវត្ថុបំណងដែលបានកំណត់។
- ដើម្បីវាយតម្លៃការបង្រៀន។
- ដើម្បីឱ្យគ្រូបានដឹងពីចំណុចខ្លាំង និង ចំណុចខ្វះខាតសម្រាប់ពិចារណាធ្វើផែនការបង្រៀន និង កែលំការបង្រៀននៅពេលអនាគត។

### គ. តារាងប្រៀបធៀបរង្វាយតម្លៃតាមដំណាក់ និងរង្វាយតម្លៃសរុប

| | អ្វី? | ហេតុអ្វី? | ដូចម្តេច? |
|---|---|---|---|
| រង្វាយតម្លៃតាមដំណាក់ | ✓ ការវាយតម្លៃការរៀនមានលក្ខណៈបន្ថែម ផ្អែកទៅលើការឆ្លើយតប និងព័ត៌មានត្រឡប់ក្នុងកំឡុងពេលរៀន ។ | ✓ ដើម្បីវិនិច្ឆ័យពីការរៀនរបស់សិស្ស ។<br>✓ ដើម្បីដឹកនាំសិស្សឱ្យរីកចំរើន ។<br>✓ ផ្តល់ការលើកទឹកចិត្តដល់សិស្ស។<br>✓ លើកកម្ពស់ការបង្រៀន និង រៀន។<br>✓ វាយតម្លៃប្រសិទ្ធភាពខ្លឹមសារ វិធីលំនាំ និង ល្បឿននៃការបង្រៀន ។ | ✓ សង្កេតជាប្រចាំ ។<br>✓ ឯកសារ និង ប្រវត្តិរបស់សិស្សម្នាក់ៗ ។<br>✓ សង្កេតស៊ីជម្រៅ និង ជាក់លាក់ ។<br>✓ តាមដានពីសកម្មភាពសិស្ស។<br>✓ ទំនាក់ទំនងជាមួយសិស្ស ។ |
| រង្វាយតម្លៃសរុប | ✓ វាយតម្លៃពីកម្រិតប្រតិបត្តិនៅចុងបញ្ចប់នៃរយៈពេលមួយច្បាស់លាស់ ។ ឧទាហរណ៍ៈ ចុងបញ្ចប់ ឆមាស<br>✓ ផ្អែកទៅលើវត្ថុបំណង ឬ ស្តង់ដាគំរូដែលបានកំណត់។ | ✓ ដើម្បីកំណត់កម្រិតជោគជ័យក្នុងការសម្រេចវត្ថុបំណង ។<br>✓ ដើម្បីវិនិច្ឆ័យនូវអ្វីដែលសិស្សបាន រៀន<br>✓ ដើម្បីវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីសិក្សា ។ | ✓ ប្រៀបធៀបកិច្ចការដែលបានបញ្ចប់ទៅនឹងគោលដៅដែលបានគ្រោង ។ |



### ឃ. រូបភាពនៃការការវាយតម្លៃជាលក្ខណៈក្រៅផ្លូវការៈ

**ការវាយតម្លៃខ្លួនឯងៈ** ជាការឆ្លុះបញ្ចាំងខ្លួនឯងគឺជាបំណិនជីវិតមួយដ៏ចាំបាច់ និងមានសារៈសំខាន់ក្នុងការរៀនពីរបៀបនៃការរៀន ហើយការធ្វើបែបនេះគឺជួយពួកគេឱ្យមានការទទួលខុសត្រូវលើការសិក្សារបស់គេ។ ម្យ៉ាងទៀតវាជាការផ្ដល់ឱកាសដល់សិស្ស ដើម្បីពិនិត្យវាយតម្លៃកិច្ចការផ្ទាល់របស់ពួកគេ ភាពរីកចម្រើនដែលពួកគេបានធ្វើ និងអាចកំណត់បានពី ចំណុចល្អ និងចំណុចខ្វះខាតដែលពួកគេត្រូវកែលំអ ។ ស្វ័យវង្វាយតម្លៃនេះមានលក្ខណៈក្រៅផ្លូវការដោយផ្តោតលើការឆ្លុះបញ្ចាំងខ្លួនឯងលើចំណេះដឹង និងបំណិនដែលទទួលបានខ្លួនដូចជាៈ បំណិនអន្តរបុគ្គល ការទំនាក់ទំនង ការគិតល្អិតល្អន់ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ការកំណត់គោលដៅ ទំនុកចិត្តលើខ្លួនឯង ការឱ្យតម្លៃលើខ្លួនឯង ការទទួលខុសត្រូវ និង ឥរិយាបថវិជ្ជមាន។

**វាយតម្លៃដោយមិត្តភក្តិៈ** គ្រូអាចរៀបចំឱ្យសិស្សវាយតម្លៃគ្នាទៅវិញទៅមកដែលសមស្របទៅនឹងសមត្ថភាព និង វ័យរបស់សិស្ស ។ ទៅតាមសភាពជាក់ស្តែង ពេលខ្លះសិស្សអាចចូលរួមក្នុងការអភិវឌ្ឍលក្ខណវិនិច្ឆ័យដើម្បីវាយតម្លៃនេះ ។ សិស្សរៀនកំណត់ចំណុចខ្លាំងនិងចំណុចដែលត្រូវកែលំអ ព្រមទាំងផ្តល់យោបល់ទៅលើការងាររបស់មិត្តភក្តិប្រកបដោយលក្ខណៈវិជ្ជមាន និង មានប្រយោជន៍ ។

**ការវាយតម្លៃការងារក្រុមៈ** មានវិធីជាច្រើនដើម្បីជួយសិស្សឱ្យគិតអំពីរបៀបដែលពួកគេធ្វើការងារជាមួយគ្នានៅក្នុងក្រុម ។ វិធីមួយដែលប្រសើរគឺការប្រើប្រាស់ទម្រង់វង្វាយតម្លៃ ដែលអនុញ្ញាតសិស្សឱ្យសរសេរអំពី និងឆ្លុះបញ្ចាំងពីបទពិសោធរបស់ពួកគេនៅក្នុងក្រុម ។ សំណួរ បីប្រភេទដែលត្រូវសួរ : ទី ១ សំណួរអាចផ្តោតទៅលើការប្រើប្រាស់បំណិនសហការជាក់លាក់មួយចំនួន និងទី ២ សំណួរអាចជម្រុញឱ្យមានការលើកទឹកចិត្តដល់ការអនុវត្តបំណិនសហការ ហើយទី ៣ សំណួរអាចផ្តល់ឱកាសដល់សិស្សដើម្បីកំណត់គោលដៅសម្រាប់អនាគត។ ប៉ុន្តែពេលខ្លះគ្រូអាចសួរសំណួរផ្ទាល់មាត់ដើម្បីទទួលនូវចម្លើយភ្លាមៗ។

**ការវាយតម្លៃបុគ្គលម្នាក់ៗនៅក្នុងក្រុមៈ** ជាលក្ខណៈវាយតម្លៃមួយដែលតម្រូវឱ្យសមាជិកក្រុមម្នាក់ៗធ្វើ ដើម្បីឆ្លុះបញ្ចាំងអន្តរកម្ម ការចូលរួម ការផ្តល់ឱកាសឱ្យគ្នា ការជម្រុញ ការលើកទឹកចិត្តសមាជិកដទៃទៀតនៅក្នុងក្រុម ការផ្តល់គំនិត និង ព័ត៌មានដែលមានទៅឱ្យសមាជិកផ្សេងទៀតក្នុងគោលបំណងលើកកម្ពស់ កែលំអ និង អភិវឌ្ឍសមត្ថភាពសមាជិកក្រុម ។

**ការវាយតម្លៃតាមរយៈការសង្កេត និងការជួបពិភាក្សាៈ** ជាការវាយតម្លៃដែលកើតមានឡើងតាមរយៈការសង្កេតរបស់គ្រូលើបំណិនទូទៅ និង គុណភាពផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ ដែលគេបានអភិវឌ្ឍ តាំងពីពេលចាប់ផ្តើមរៀនបំណិនជីវិតរហូតដល់ចប់មេរៀនទាំងមូល ដើម្បីធ្វើការប្រៀបធៀបពីភាពខុសគ្នារវាងការវាយតម្លៃដែលសង្កេតដោយគ្រូ និង ការវាយតម្លៃខ្លួនឯងដែលធ្វើឡើងដោយសិស្សខ្លួនឯង។ ការវាយតម្លៃនេះតម្រូវឱ្យគ្រូ និងសិស្សជួបពិភាក្សាគ្នាពិនិត្យលើលទ្ធផលវាយតម្លៃរបស់គេក្នុងករណី មានភាពខុសគ្នាខ្លាំងពេកនោះ ។ ការវាយតម្លៃនេះមិនផ្តោតលើការខុសត្រូវប៉ុន្មានទេ គឺគ្រាន់តែពិភាក្សារកមូលហេតុនៃការឱ្យពិន្ទុ ខុសគ្នាប៉ុណ្ណោះ ដើម្បីធ្វើយ៉ាងណាឱ្យការវាយតម្លៃនេះមានលក្ខណៈសមស្រប។

**វាយតម្លៃនៅចុងបញ្ចប់ដំណាក់កាលនីមួយៗៈ** វាជាការតាមដានការរីកចម្រើនរបស់សិស្សជាប្រចាំពីសកម្មភាពមួយទៅសកម្មភាពមួយ ។ ការវាយតម្លៃតាមដំណាក់ធ្វើឡើងដោយគ្រូនៅពេលបង្រៀនចប់ដំណាក់កាលនីមួយៗ ដើម្បីត្រួតពិនិត្យលើការយល់ដឹងខ្លឹមសារមេរៀន បំណិនដែលបានអភិវឌ្ឍ ការប្រែប្រួលឥរិយាបថ ក្នុងបំណងធ្វើយ៉ាងណា លើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និងរៀនថ្នាក់បំណិនជីវិតក្នុងដំណាក់កាលនីមួយៗ។

## ២. ការវាយតម្លៃកម្មវិធីបំណិនជីវិត

**២.១. សេចក្តីផ្តើម:** ការវាយតម្លៃបំណិនជីវិតផ្តោតលើការរីកចម្រើនរបស់កុមារក្នុងការអភិវឌ្ឍចំណេះដឹង បំណិនទូទៅ និង គុណភាព ផ្ទាល់ខ្លួននៅក្នុងកំឡុងនៃការរៀនកម្មវិធីបំណិនជីវិតលើចំណុចសំខាន់ៗដូចខាងក្រោម:

- ចំណេះដឹងដែលទទួលបាន និង ការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និង សហគមន៍ ។
- ការប្រតិបត្តិគឺសំដៅលើការរៀបចំផែនការផ្សព្វផ្សាយ ការអនុវត្តផែនការផ្សព្វផ្សាយ ការឆ្លុះបញ្ចាំង និង វាយតម្លៃការផ្សព្វផ្សាយ ។
- បំណិនទូទៅ និងគុណភាពផ្ទាល់ខ្លួនដែលសិស្សបានអភិវឌ្ឍតាមរយៈការសិក្សាមេរៀនបំណិនជីវិតដែលមានលក្ខណៈអនុវត្តជាក់ស្តែង ហើយឆ្លើយតបទៅនឹងតម្រូវការរបស់គេ ។

**២.២. ការវាយតម្លៃជាលក្ខណៈផ្លូវការ:** ជាការវាយតម្លៃដែលតម្រូវឱ្យមានការកត់ត្រាលើការសិក្សារបស់សិស្សម្នាក់ៗ ចំពោះម៉ូឌុល ឬ មេរៀនទាំងមូល ដោយផ្តោតទៅលើការយល់ដឹងលើខ្លឹមសារមេរៀន និង ការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍ ព្រមទាំងកំណត់រកឱ្យឃើញនូវការប្រែប្រួល ឥរិយាបថ បំណិន និងគុណភាពផ្ទាល់ខ្លួន ដែលសិស្សបានអភិវឌ្ឍ និងសមត្ថភាពប្រើប្រាស់បំណិនទាំងនោះសម្រាប់ការសិក្សា និងការរស់នៅរបស់គេ ។ ការវាយតម្លៃជាលក្ខណៈផ្លូវការនេះផ្តោតលើ ចំនុច ២ ជាសំខាន់គឺ:

**ក. តេស្តចំណេះដឹង:** ជាតេស្តសរសេរបញ្ចប់ម៉ូឌុល ឬ មេរៀន ដើម្បីពិនិត្យលើកម្រិតយល់ដឹងរបស់សិស្សលើខ្លឹមសារមេរៀន (**សូមមើលគំរូតេស្តនៅទំព័រ ៦១**) ។ តេស្តសរសេរនេះ ផ្តោតលើ:

- គំនិតសំខាន់ៗ ឬ ចំណេះដឹងដែលទទួលបានលើខ្លឹមសារមេរៀន ។
- ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯង ។
- ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារនិងសហគមន៍ ។

**ខ. ការងារប្រតិបត្តិ:** ជាការបង្ហាញ ឬ អនុវត្តផ្ទាល់របស់សិស្សដើម្បីពិនិត្យមើលលើសមត្ថភាពយល់ដឹង និងបំណិនរបស់ពួកគេក្នុងការរៀបចំដឹកនាំសកម្មភាពផ្សព្វផ្សាយពីអ្វីដែលគេបានរៀនដោយផ្តោតលើ:

- ការរៀបចំផែនការផ្សព្វផ្សាយ ។
- ការអនុវត្តផែនការផ្សព្វផ្សាយ ។
- ការឆ្លុះបញ្ចាំង និង ការវាយតម្លៃលើការផ្សព្វផ្សាយ ។

**២.៣. ការវាយតម្លៃជាលក្ខណៈក្រៅផ្លូវការ:** ជាការវាយតម្លៃមានលក្ខណៈជាការសង្កេតដោយគ្រូទៅលើសកម្មភាពរៀនសូត្ររបស់សិស្សប្រចាំថ្ងៃ ឬ ការឆ្លុះបញ្ចាំងលើសកម្មភាពរៀនដោយសិស្សខ្លួនឯង ដោយផ្តោតលើចំណេះដឹង និង ការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និង សហគមន៍ ការប្រែប្រួលឥរិយាបថ បំណិន និង គុណភាពផ្ទាល់ខ្លួន ដែលសិស្សបានអភិវឌ្ឍ និង សមត្ថភាពប្រើប្រាស់បំណិនទាំងនោះសម្រាប់ការសិក្សា និង ការរស់នៅរបស់គេម្នាក់ៗ ។ ការវាយតម្លៃក្រៅផ្លូវការមិនត្រូវបានកត់ត្រាសម្រាប់វាយតម្លៃជាប់ធ្លាក់នោះទេ តែវាជួយធ្វើឱ្យការវាយតម្លៃផ្លូវការមានលក្ខណៈត្រឹមត្រូវ ។

## ៣. ការណែនាំពីការប្រើប្រាស់បណ្ណវាយតម្លៃ

៣.១. *ការវាយតម្លៃផ្លូវការ:* មាន ២ ប្រភេទគឺទី ១ តេស្តសរសេរ និង ទី ២ ការប្រតិបត្តិ ។ ចំពោះតេស្តសរសេរ សូមមើលគំរូនៅ ( **ទំព័រ ៦១**) ដោយឡែកការវាយតម្លៃការងារប្រតិបត្តិសូមមើលគំរូប័ណ្ណនៅ( **ទំព័រ ៦២**) ។

### ក. *លក្ខណៈវិនិច្ឆ័យ និង ល័ក្ខខ័ណ្ឌសម្រាប់ការវាយតម្លៃ:*

**កិច្ចការទី ១ : តេស្តសរសេរ**

| *លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ* | *ល័ក្ខខ័ណ្ឌនៃការវាយតម្លៃ* |
|---|---|
| • គំនិតសំខាន់ៗដែលមាននៅក្នុងខ្លឹមសារមេរៀន ។ | • ការងារជាបុគ្គល ។ |
| • ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯង ។ | • មិនអនុញ្ញាតឱ្យពិភាក្សា និង ចម្លងគ្នា ។ |
| • ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារ និង សហគមន៍ ។ | |

**កិច្ចការទី ២ : ការងារប្រតិបត្តិ**

| *លក្ខណៈវិនិច្ឆយ័សម្រាប់ការវាយតម្លៃ* | *ល័ក្ខខ័ណ្ឌនៃការវាយតម្លៃ* |
|---|---|
| • បំណិនអន្តរបុគ្គល | • ការស្តាប់ដោយយកចិត្តទុកដាក់ និងឆ្លើយតបដោយសមរម្យ |
| • ការទំនាក់ទំនង | • ការរាប់អានគ្នា ការចេះជួយគ្នា ឬ ភាពគ្មានទំនាស់ |
| • ការគិតល្អិតល្អន់ | • ការគិតតាមបែបបំបែកគំនិត និង បណ្តុំគំនិត |
| • ការដោះស្រាយបញ្ហា | • ការកំណត់រកវិធីផ្សេង ដើម្បីចៀសពីបញ្ហា |
| • ការសម្រេចចិត្ត | • ការជ្រើសរើសដោយផ្អែកលើព័ត៌មាន និង ភស្តុតាងគ្រប់គ្រាន់ |
| • ការកំណត់គោលដៅ | • ការរៀបចំផែនការច្បាស់លាស់ |
| • ទំនុកចិត្តលើខ្លួនឯង | • ភាពប្រាកដប្រជា និងអាចធ្វើអ្វីមួយដោយខ្លួនឯង |
| • ការឱ្យតម្លៃលើខ្លួនឯង | • ការគិតវិជ្ជមាន និងចេះលើកទឹកចិត្តខ្លួនឯង |
| • ការទទួលខុសត្រូវ | • ការទទួលស្គាល់ការពិត និងការកែលំអ |
| • ឥរិយាបថវិជ្ជមាន | • បើកចិត្ត និង គំនិតឱ្យបានទូលាយ ព្រមទាំងទទួលយកការរិះគន់ |

### ខ. របៀបប្រើប្រាស់ប័ណ្ណវាយតម្លៃផ្លូវការ:

**កិច្ចការទី ១-តេស្តសរសេរ :** ជាការធ្វើតេស្តលើចំណេះដឹងដូចមុខវិជ្ជាផ្សេងទៀត ដើម្បីយកពិន្ទុទៅដាក់ក្នុងប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ ដែលបំពេញដោយគ្រូ ( **ឧបសម្ព័ន្ធទី ១-ទម្រង់ប័ណ្ណវាយតម្លៃទី ២ ទំព័រទី ៦៩**) ។

**កិច្ចការទី ២-ការងារប្រតិបត្តិ :** តម្រូវឱ្យគ្រូវាយតម្លៃសិស្សម្នាក់ៗ និង សិស្សធ្វើស្វ័យវាយតម្លៃខ្លួនឯង ។

- នៅពេលធ្វើការវាយតម្លៃបញ្ចប់គ្រូត្រូវបំពេញប័ណ្ណវាយតម្លៃសិស្សម្នាក់ៗសម្រាប់កិច្ចការទី ២ ( **ឧបសម្ព័ន្ធ ១. ទម្រង់ប័ណ្ណវាយតម្លៃទី ២ ទំព័រ ៦៨**) ដោយប្រើខ្មៅដៃ ។
- បន្ទាប់មកគ្រូចែកប័ណ្ណវាយតម្លៃខ្លួនឯង ( **ឧបសម្ព័ន្ធ ១.ទម្រង់ប័ណ្ណវាយតម្លៃទី ១-ទំព័រ ៦៨** ) ឱ្យទៅសិស្សម្នាក់ៗធ្វើការវាយតម្លៃខ្លួនគេ រៀងៗខ្លួនមិនពិភាក្សា ឬ មើលគ្នាឡើយ ហើយ សិស្សត្រូវបំពេញដោយប្រើខ្មៅដៃ។

- គ្រូត្រូវប្រមូលប័ណ្ណដែលសិស្សវាយតម្លៃខ្លួនឯង ដើម្បីយកមកប្រៀបធៀបជាមួយប័ណ្ណរបស់គាត់ត្រង់ការងារប្រតិបត្តិ ។ ក្នុងករណីដែលសិស្ស និង គ្រូមានការវាយតម្លៃខុសគ្នា គេត្រូវពិភាក្សាអំពីលទ្ធផលនៃការវាយតម្លៃនោះ ។ ក្នុងកំឡុងពិភាក្សានេះ សិស្សម្នាក់ៗបង្ហាញគ្រូនូវលទ្ធផល ដែលគេបានវាយតម្លៃដោយខ្លួនឯង ដើម្បីពិភាក្សាជាមួយគ្រូ លុះត្រាទទួលបាននូវការព្រមព្រៀងមួយពីការដាក់ពិន្ទុ និង ធ្វើការកែតម្រូវលើប័ណ្ណវាយតម្លៃការសិក្សារបស់កុមារនោះ ដោយប្រើប៊ិច ។ គ្រូអាចលើកជាឧទាហរណ៍តាមរយៈការសង្កេតរបស់ខ្លួនទៅលើសិស្សនេះ ឬ ឱ្យសិស្សផ្ដល់ហេតុផលចំពោះការដាក់ពិន្ទុរបស់គេ ដើម្បីជួយឱ្យសិស្សទទួលស្គាល់ការពិតពីសមិទ្ធិផលរបស់គេ ជៀសវាងវាយតម្លៃខ្លួនទាប ឬ ហួសពីការពិត ។ ការពិភាក្សាជាមួយកុមារម្នាក់ៗ គឺមានរយៈពេលពី ១០ ទៅ ១៥នាទី ។
- បន្ទាប់ពីពិភាក្សាជាមួយកុមាររួច គេត្រូវកែលំអនៅលើប័ណ្ណវាយបម្លៃរបស់គេរៀងៗខ្លួន ហើយគ្រូត្រូវស្រង់លទ្ធផលសរុបរបស់សិស្សដាក់ក្នុងតារាងវាយតម្លៃសង្ខេបរួម (**ឧបសម្ព័ន្ធ ១-ទម្រង់ប័ណ្ណវាយតម្លៃទី ៣ ទំព័រ ៧០**) រួចផ្ដល់ឱ្យមកក្រុមការងារថ្នាក់កម្រង ។
- បន្ទាប់មកគ្រូគួរបំពេញប័ណ្ណវាយតម្លៃសង្ខេបរបស់សិស្សម្នាក់ៗ ។ គ្រូដាក់ពិន្ទុសម្រាប់លក្ខណៈវិនិច្ឆ័យនីមួយៗ ដែលបានវាយតម្លៃនៅក្នុងកិច្ចការវង្វាយតម្លៃបញ្ចប់សម្រាប់ម៉ូឌុល ។
- នៅចុងបញ្ចប់ឆ្នាំសិក្សា គ្រូ និង សិស្សអាចពិនិត្យកម្មវិធីទាំងមូលឡើងវិញ ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់នៅក្នុងកម្មវិធីបំណិនជីវិតទាំងមូលតែម្ដង ។
- គ្រូគួររក្សាប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ និង ប័ណ្ណវាយតម្លៃរួមនៅក្នុងសឺមីស្នាដៃរបស់សិស្ស ។

### គ. គំរូបង្កើតតេស្តសរសេរវាយតម្លៃសម្រាប់កិច្ចការទី ១ និង គំរូប័ណ្ណវាយតម្លៃកិច្ចការទី ២

**គំរូតេស្តសរសេរ : មេរៀនៈ អំពើហិង្សាក្នុងគ្រួសារ**

**កិច្ចការទី ១ៈ តេស្តលើចំណេះដឹងដែលទទួលបាន និង ការប្រើប្រាស់**

**១. ចំណេះដឹងដែលទទួលបានៈ (១០ ពិន្ទុ)**

ក. តើមូលហេតុអ្វីដែលបណ្ដាលឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ? (**៣ ពិន្ទុ**)

..........................................................................................................................

ខ. តើការកើតមានអំពើហិង្សាក្នុងគ្រួសារបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះ? (**៣ ពិន្ទុ**)

..........................................................................................................................

គ. តើប្អូនគួរធ្វើយ៉ាងដូចម្ដេច ដើម្បីការពារកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ? (**៤ ពិន្ទុ**)

..........................................................................................................................

**២. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯងៈ (១០ ពិន្ទុ)**

ឃ. តើប្អូនត្រូវធ្វើដូចម្ដេច ដើម្បីការពារខ្លួនអ្នកឱ្យចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

..........................................................................................................................

**៣. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារ និង សហគមន៍ៈ (១០ ពិន្ទុ)**

ង. តើប្អូនត្រូវធ្វើដូចម្ដេច ដើម្បីការពារគ្រួសារ ឬ សហគមន៍របស់អ្នកឱ្យចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

## <u>គំរូបំណ្ណវាយតម្លៃការងារប្រតិបត្តិ</u>

**កិច្ចការទី ២: ការងារប្រតិបត្តិ**

ចូរអានប្រយោគនីមួយៗក្នុងតារាងខាងក្រោម រួចគូសសញ្ញា ( ✓ ) ក្នុងប្រអប់មួយដែលស្របនឹងបំណិនដែលសិស្សបានអភិវឌ្ឍ ។

| ល.រ | បំណិនដែលបានអភិវឌ្ឍ | យល់ស្របខ្លះៗ | យល់ស្រប | យល់ស្របខ្លាំង |
|---|---|---|---|---|
| | | (៤ ពិន្ទុ) | (៧ ពិន្ទុ) | (១០ ពិន្ទុ) |
| ០ | **ការបង្ហាញ:** ខ្ញុំមានទំនុកចិត្តក្នុងការឡើងបង្ហាញ និង បកស្រាយពន្យល់បានច្បាស់លាស់ ។ | ✓ | | |
| ១ | **បំណិនអន្តរបុគ្គល:** នៅក្នុងថ្នាក់ខ្ញុំបានចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយមិត្តភក្តិជាញឹកញាប់ ។ | | | |
| ២ | **ការទំនាក់ទំនង:** ខ្ញុំចូលចិត្តមិត្តរួមថ្នាក់របស់ខ្ញុំ,យើងតែងជួយគ្នាហើយមិនដែលមានទំនាស់នឹងគ្នាទេ ។ | | | |
| ៣ | **ការគិតល្អិតល្អន់:** ខ្ញុំតែងពិចារណារកហេតុផល, មានអំណះអំណាង និង ភស្តុតាងច្បាស់លាស់ ។ | | | |
| ៤ | **ការដោះស្រាយបញ្ហា:** ខ្ញុំអាចកំណត់បានដំណោះស្រាយច្រើនចំពោះបញ្ហាមួយ ហើយរើសយកដំណោះស្រាយដែលខ្ញុំ អាចដោះស្រាយបាន ។ | | | |
| ៥ | **ការសម្រេចចិត្ត:** ខ្ញុំបានប្រមូលព័ត៌មាន និងភស្តុតាងជាច្រើនមុននឹងធ្វើការសម្រេចចិត្ត ។ | | | |
| ៦ | **ការកំណត់គោលដៅ:** ខ្ញុំតែងរៀបចំផែនការបានច្បាស់លាស់ ដើម្បីអនុវត្តការងារឱ្យបានជោគជ័យ ។ | | | |
| ៧ | **ទំនុកចិត្តលើខ្លួនឯង:** ខ្ញុំមានភាពប្រាកដប្រជាមិនស្ទាក់ស្ទើរ និង អាចធ្វើអ្វីមួយដោយខ្លួនឯងបាន ។ | | | |
| ៨ | **ការឱ្យតម្លៃលើខ្លួនឯង:** ខ្ញុំគិតវិជ្ជមានពីខ្លួនឯង និងសាទរចំពោះជោគជ័យដែលខ្លួនធ្វើ ។ | | | |
| ៩ | **ការទទួលខុសត្រូវ:** ខ្ញុំទទួលស្គាល់ការពិត និង កែលំអចំណុចខ្វះខាតរបស់ខ្ញុំ ។ | | | |
| ១០ | **ឥរិយាបថវិជ្ជមាន:** ខ្ញុំមានចិត្ត និង គំនិតទូលំទូលាយ ឱ្យតម្លៃអ្នកដទៃ និង ទទួលការរិះគន់ដោយរីករាយ ។ | | | |

**៣.២. ការវាយតម្លៃក្រៅផ្លូវការ:** ក្រៅពីការសង្កេតសកម្មភាពប្រចាំថ្ងៃរបស់សិស្ស គ្រូអាចប្រើប័ណ្ណវាយតម្លៃ សម្រាប់ការវាយតម្លៃក្រៅផ្លូវការនៅចុងបញ្ចប់នៃដំណាក់កាលនីមួយៗនៃមេរៀន ជាលក្ខណៈបុគ្គល និងក្រុម ដោយប្រើប័ណ្ណវាយតម្លៃគំរូដូចជា: *១. ការវាយតម្លៃពីឥរិយាបថរបស់សមាជិកនៅក្នុងក្រុម ២. ការវាយតម្លៃការងារក្រុម ពីចំណុចចូលចិត្ត និងចំណុចកែលំអ ៣. ការគិតអំពីក្រុមរបស់ខ្ញុំ ៤. តារាងត្រួតពិនិត្យក្រុម* (**ឧបសម្ព័ន្ធទី ២ ទំព័រ ៧១-៧៣**) ទៅតាមស្ថានភាពជាក់ស្តែង និង តម្រូវការក្នុងការទទួលព័ត៌មានពីការរីកចម្រើនលើគ្រប់ផ្នែកទាំងអស់របស់សិស្ស។

**ក. លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ:**

- ពិនិត្យមើលពីឥរិយាបថរបស់គេចំពោះសមាជិកគេម្នាក់ៗនៅក្នុងក្រុម។
- ពិនិត្យមើលពីចំណុចចិត្ត និង ចំណុចត្រូវកែលំអសម្រាប់ការងារក្រុម ។
- ពិនិត្យមើលពីកម្រិតនៃការចូលរួមរបស់គេ ឬ ការចូលរួមរបស់សមាជិកដទៃទៀតចំពោះការងារក្រុម និង ហេតុការណ៍ផ្សេងៗដែលកើតមាននៅក្នុងក្រុម។

**ខ. របៀបប្រើប្រាស់ប័ណ្ណវាយតម្លៃក្រៅផ្លូវការ:**

- គ្រូត្រូវជ្រើសរើសយកទម្រង់ប័ណ្ណណាមួយក្នុងចំណោមទម្រង់ប័ណ្ណវាយតម្លៃក្រៅផ្លូវការទាំង ៤ (**ឧបសម្ព័ន្ធទី ២ ទំព័រ ៧០-៧២** ) ចែកទៅឱ្យសិស្សម្នាក់ៗបំពេញ រៀងៗខ្លួនដោយមិនឱ្យពិភាក្សាគ្នា ឬ មើលគ្នាឡើយ ចំពោះប័ណ្ណ ១-៣។ ដោយឡែកសម្រាប់ប័ណ្ណទី ៤ សិស្សពិភាក្សាជាក្រុមធ្វើការវាយតម្លៃការងារក្រុមរបស់គេរួមគ្នា។
- គ្រូត្រូវប្រមូលប័ណ្ណទាំងនោះ យកមកអានស្វែងយល់ និង ស្រង់ចំណុចសំខាន់ៗសម្រាប់រៀបចំកែលំអ និង ជួយសិស្សក្នុងការអភិវឌ្ឍការងារក្រុមឱ្យកាន់តែប្រសើរ ។

## V. សកម្មភាពអនុវត្តន៍

### ១. ការតម្រង់ទិសកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដល់សហគមន៍




ជាការពិតណាស់ ការអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ជារឿងថ្មីសម្រាប់សង្គមកម្ពុជា ជាពិសេសសម្រាប់មន្ត្រីអប់រំនៅតាមមូលដ្ឋាននិងសហគមន៍ ។ដូចនេះហើយ ការតម្រង់ទិសពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋានទៅដល់សហគមន៍ជារឿងសំខាន់ណាស់ ដើម្បីឱ្យមានការចូលរួម និងគាំទ្រពីសហគមន៍ ។ ការធ្វើបែបនេះវាជួយជំរុញឱ្យសហគមន៍យល់ពីសកម្មភាព ដែលសិស្សធ្វើនៅពេលពួកគេចុះស្រាវជ្រាវព័ត៌មាន និងធ្វើការផ្សព្វផ្សាយពីអ្វីដែលគេបានរៀនដល់សហគមន៍ ។ ការតម្រង់ទិសនេះគួរតែធ្វើឡើងមុនពេលកម្មវិធីបំណិនជីវិត តាមមូលដ្ឋានចាប់ផ្តើម ហើយការតម្រង់ ទិសនេះគួរតែរៀបចំធ្វើដោយនាយកសាលាសហការជាមួយអាធរមូលដ្ឋាន ។

### ២. ការពិនិត្យឡើងវិញលើកម្មវិធីសិក្សានៅថ្នាក់កម្រង




ក្រោយពីទទួលបានការបណ្តុះបណ្តាលការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន បន្ទាប់មកនាយកសាលា ប្រធានក្រុមបច្ចេកទេស និង គ្រូបំណិនជីវិតទាំងអស់ត្រូវជួបប្រជុំគ្នា ដើម្បីពិនិត្យមើលឡើងវិញលើគោលនយោបាយអប់រំបំណិនជីវិត ការអភិវឌ្ឍកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន លំនាំនៃការបង្រៀន និង រៀនបំណិនជីវិត និងកិច្ចតែងការដែលបានរៀបចំបង្ហាញនៅឯសិក្ខាសាលាថ្នាក់កម្រង ។ ការប្រជុំនេះត្រូវពិនិត្យស្វែងយល់ឡើងវិញលើខ្លឹមសារ វិធីសាស្រ្តបច្ចេកទេសដែលមាននៅក្នុងកិច្ចតែងការបង្រៀន ធ្វើការកែសម្រួលដើម្បីឱ្យមានលក្ខណៈងាយស្រួលក្នុងការយកទៅអនុវត្ត ព្រមទាំងកំណត់ពីធនធានសម្ភារ ដែលចាំបាច់ត្រូវប្រើសម្រាប់ការចាប់ផ្តើមការបង្រៀនបំណិនជីវិត ។ ម្យ៉ាងទៀតការជួបប្រជុំនេះក្នុងន័យឱ្យគ្រូបំណិនទាំងអស់ផ្លាស់ប្តូរយោបល់គ្នាធ្វើយ៉ាងណាឱ្យគ្រូយល់កាន់តែច្បាស់ និងមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការបង្រៀន និងការវាយតម្លៃមេរៀនបំណិនជីវិត ។

## ៣. ការធ្វើផែនការបង្រៀនបំណិនជីវិតប្រចាំឆ្នាំ

ដើម្បីឱ្យការអនុវត្តកម្មវិធីបំណិនជីវិតកាន់តែមានលក្ខណៈងាយស្រួល និងមានប្រសិទ្ធភាពនោះ នាយកសាលា និងប្រធានក្រុមបច្ចេកទេសត្រូវដឹកនាំការប្រជុំធ្វើផែនការលំអិតសម្រាប់កម្មវិធីបំណិនជីវិតប្រចាំឆ្នាំ ដោយពិភាក្សាកំណត់អាទិភាពចំនួនប្រធានបទ ឬមេរៀនបំណិនជីវិតសម្រាប់អនុវត្តការបង្រៀន ក្នុងរយៈពេលពេញមួយឆ្នាំសិក្សា។ ម្យ៉ាងទៀតប្រធានបទ និង វិធីសាស្ត្របង្រៀនត្រូវឆ្លើយតបទៅនឹងតម្រូវការ និងការចង់បាន របស់សិស្សដែលមានបីផ្នែកសំខាន់គឺប្រធានបទដែលពាក់ព័ន្ធ ផ្នែកសង្គម វប្បធម៌ប្រពៃណី និង ការប្រតិបត្តិងាយៗ ឬ បុរេវិជ្ជាជីវៈ។ ការបង្រៀន បំណិនជីវិតគឺដំណើរការនៅរៀងរាល់ថ្ងៃព្រហស្បតិ៍ រយៈពេល ២ ម៉ោង ហើយការបង្រៀននេះអនុវត្តតាមលំនាំគំរូ ៦ ដំណាក់កាលនៃការបង្រៀន និង រៀន។

## ៤. ការរៀបចំកិច្ចតែងការបង្រៀនមេរៀនបំណិនជីវិត

ជាផែនការបន្តក្រោយពេលបង្រៀនចប់ប្រធានបទ ឬ មេរៀនបំណិនជីវិតមួយ នាយកសាលា ប្រធានក្រុមបច្ចេកទេស និង គ្រូថ្នាក់ទី ៥ និងទី ៦ ត្រូវជួបប្រជុំគ្នា ដើម្បីធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀនបំណិនជីវិតដែលបានអនុវត្តចប់មួយប្រធានបទ ដោយពិភាក្សាផ្លាស់ប្តូរយោបល់ និង បទពិសោធន៍ កំណត់ពីចំណុចល្អ ចំនុចត្រូវកែលំអ ការប្រឈម និងដំណោះស្រាយ ដើម្បីកែលំអការបង្រៀនមេរៀនបន្ទាប់ឱ្យកាន់តែល្អប្រសើរ និង មានប្រសិទ្ធភាព ។ បន្ទាប់ប្រធានក្រុមបច្ចេកទេស និងគ្រូពិភាក្សារៀបចំធ្វើកិច្ចតែងការបង្រៀនបំណិនជីវិតថ្មីមួយទៀតក្នុងចំណោមប្រធានបទ ឬមេរៀនដែលបានកំណត់ទុកជាអាទិភាពសម្រាប់មួយឆ្នាំសិក្សានោះ ផ្តោតសំខាន់លើខ្លឹមសារ វិធីសាស្ត្រ បច្ចេកទេស និងធនធានសម្ភារដែលត្រូវការសម្រាប់ ប្រើប្រាស់ក្នុងការបង្រៀនបំណិនជីវិត និងប្រើប្រាស់នូវបទពិសោធ និង ដំណោះស្រាយដែលបានលើកឡើងពេលធ្វើការឆ្លុះបញ្ចាំង។

## ៥. ការគាំទ្រពីសាលារៀន និង សហគមន៍



ដើម្បីអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននេះឱ្យទទួលបានជោគជ័យ វាទាមទារឱ្យមានការចូលរួមគាំទ្រពីសាលារៀន និងសហគមន៏ដែលការគាំទ្រនេះជាកត្តាដ៏សំខាន់ក្នុងការកសាងទំនាក់ទំនងរវាងសាលា និង សហគមន៏រវាងសហគមន៏ និងសិស្សដើម្បីឱ្យពួកគេយល់ពីតម្លៃ និងសកម្មភាពរៀនសូត្ររបស់សិស្ស ។ ដូចនេះ ដើម្បីឱ្យឆ្លើយតបនឹងតម្រូវការនេះ នាយកសាលា គ្រូ និង អាជ្ញាធរមូលដ្ឋានធ្វើយ៉ាងណាសហការគ្នាកំណត់

គោលដៅមនុស្សនៅតាមសហគមន៍ សម្រាប់សិស្សចុះសម្ភាសន៍នៅក្នុងដំណាក់កាលទី ២ ដោយជម្រាបប្រាប់ពួកគេឱ្យយល់ច្បាស់ពីគោលបំណង និងសារៈប្រយោជន៍នៃការរៀននៅដំណាក់កាលនេះ និងជួយគាំទ្រដល់សកម្មភាពរៀបចំផែនការផ្សព្វផ្សាយរបស់សិស្សនៅដំណាក់កាលទី ៥ ដូចជាការរៀបចំទីកន្លែង ផ្តល់សម្ភារ និងការអញ្ជើញសហគមន៍ឱ្យចូលរួម ។ លើសពីនេះទៀត ការរៀបចំទិវាបង្ហាញជូនដល់សហគមន៍ពីអ្វីដែលសិស្សបានរៀន និង ធ្វើអាចជួយឱ្យសហគមន៍មើលឃើញកាន់តែច្បាស់ពីសារៈសំខាន់នៃការសិក្សា និង ចូលរួមកាន់តែច្រើនឡើងៗ ។

### ៦. ការពិនិត្យតាមដាន និង វាយតម្លៃ

នៅពេលដែលមានការអនុវត្តកម្មវិធីបំណិនជីវិតនៅតាមសាលា ក្រុមការងារថ្នាក់ស្រុក ជាពិសេសនាយកសាលានឹងធ្វើផែនការចុះតាម ដានពិនិត្យការបង្រៀនបំណិនជីវិតរបស់គ្រូ ។ ការចុះតាមដាននេះមានគោលបំណងផ្តល់ការគាំទ្រដល់ក្នុងការអនុវត្ត កម្មវិធីបំណិនជីវិតរបស់គេ និងរកឱ្យឃើញនូវតម្រូវការរបស់គ្រូក្នុងការអនុវត្តកម្មវិធីបំណិនឱ្យមានប្រសិទ្ធភាព ដើម្បីលើកជារបៀបវារៈក្នុងការប្រជុំបច្ចេកទេសនៅថ្ងៃព្រហស្បតិ៍ ។ ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ក្នុងការធ្វើផែនការតាមដានពិនិត្យមានដូចខាងក្រោម :

- ការរៀបចំកាលវិភាគសំរាប់ចុះតាមដានពិនិត្យ-ពេលណា ថ្នាក់ណា សាលាណា អ្នកណា ឧបករណ៍....
- ការប្រជុំក្រុមប្រឹក្សាបច្ចេកទេស និង ផែនការសកម្មភាព ក្នុងការលើកកម្ពស់គុណភាពបង្រៀន និង រៀននៅតាមសាលា ។
- ធ្វើរបាយការណ៍ជូនប្រធានការិយាល័យអប់រំស្រុក និង ប្រធានមន្ទីរអប់រំខេត្ត ។
- ការសង្កេតថ្នាក់ក្រុមការងារត្រូវជួបជាមួយនាយកសាលា ដើម្បីពិភាក្សាពីការអនុវត្តកម្មវិធីបំណិនជីវិតសំណូមពររបស់គាត់ ហើយពេលសង្កេតថ្នាក់ អ្នកសង្កេតថ្នាក់ត្រូវកត់ត្រា និង បញ្ជាក់ភស្តុតាងឱ្យច្បាស់សម្រាប់ផ្តល់ព័ត៌មានត្រឡប់ដល់គ្រូដែលភស្តុតាងនេះនឹងជួយឱ្យគ្រូ មើលឃើញនូវសមត្ថភាពរបស់គាត់ និង ចំណុចដែលគាត់ត្រូវកែលំអ ។
- អ្នកសង្កេតថ្នាក់មានតួនាទីធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងសម្រាប់គ្រូ មិនប្រាប់គ្រូឱ្យធ្វើតាមការយល់ឃើញរបស់ខ្លួនឡើយ តែអាចផ្តល់យោបល់ដល់គ្រូ ដើម្បីចែករំលែកបទពិសោធ និង ចំណេះដឹងតែប៉ុណ្ណោះ ។
- គ្រូមានសិទ្ធិចូលរួមជជែក និង លើកហេតុផលឆ្លើយតបនឹងអ្នកផ្តល់ព័ត៌មានត្រឡប់
- បូកសរុបការចុះសង្កេតលើបទពិសោធល្អៗ ចំណុចដែលត្រូវកែលំអ និង ផ្តល់អនុសាសន៍ដល់គ្រូ ។ ទន្ទឹមនឹងនេះដែរ គេអាចផ្តល់របាយការណ៍នេះទៅនាយកសាលា ដែលគេបានចុះសង្កេតដើម្បីបង្ហាញទស្សនៈពីខាងក្រៅក្នុងការអនុវត្តកម្មវិធីបំណិនជីវិតនៅក្នុងសាលារបស់គាត់ ។

## ៧. ការប្រជុំក្រុមបច្ចេកទេស និង ការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបង្រៀន



ផ្អែកលើលទ្ធផលនៃការសង្កេតថ្នាក់ ក្រុមប្រឹក្សាបច្ចេកទេស ត្រូវរៀបចំផែនការសម្រាប់ប្រជុំបច្ចេកទេសជាមួយគ្រូនៅតាមកំរងលើចំណុច ដែលគេបានរកឃើញថាតើត្រូវរៀបចំ និងបង្ហាញពេលប្រជុំក្រុមបច្ចេកទេសដូចម្តេច ការប្រជុំក្រុមបច្ចេកទេស ជាវេទិកាមួយដែលផ្តល់ឱកាសដល់គ្រូក្នុងការឆ្លុះបញ្ចាំងលើការបង្រៀនរបស់គេ ពិភាក្សា និង ចែករំលែកបទពិសោធ ការលំបាក និងរៀនពីគ្នាទៅវិញទៅមក ។ លើសពីនេះទៅទៀត ការប្រជុំក្រុមបច្ចេកទេសមានតួនាទីជួយគ្រូ ដើម្បីឱ្យគាត់មានលទ្ធភាពអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់គាត់ និងបង្រៀនមេរៀនបំណិនជីវិតប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្ហាញជាថ្នាក់និទស្សន៍ ឬការបំប៉នសកម្មភាពណាមួយនៅក្នុងដំណាក់កាលទាំង ៦ នៃការរៀន ។ ការប្រជុំក្រុមបច្ចេកទេស និង ការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបបង្រៀន គួរផ្តោតលើចំណុចមួយចំនួន ដូច ខាងក្រោម :

- ✓ ឆ្លុះបញ្ចាំងនូវការអនុវត្តកម្មវិធីបំនិនជីវិតតាមសាលារៀនកន្លងមក (ចំណុចល្អ ចំណុចកែលំអ និង អនុសាសន៍..) ។
- ✓ ពិភាក្សាស្វែងរកដំណោះស្រាយបញ្ហាខាងលើដែលទាក់ទងទៅនឹងការបង្រៀន និងការរៀន ។
- ✓ ការរៀបចំកិច្ចតែងការ និងកសាងប្រើប្រាស់សម្ភារសម្រាប់ការបង្រៀន និង រៀន ។
- ✓ ការប្រើគោលវិធីសិស្សមជ្ឈមណ្ឌលបង្រៀនតាមលំនាំកម្មវិធីបំណិនជីវិតចំពោះប្រធានបទផ្សេងទៀតដែលក្រសួងតម្រូវឱ្យបង្រៀន ។

## ៨. ការឆ្លុះបញ្ចាំង និងរៀបចំសម្រាប់ឆ្នាំសិក្សាថ្មី

នៅពេលវិស្សមកាលក្រុមការងារស្រុក ដែលទទួលខុសត្រូវតាមកម្រងនីមួយៗ រៀបចំសិក្ខាសាលារយៈពេល ៥ ថ្ងៃ ជាមួយនាយកសាលា ប្រធានក្រុមបច្ចេកទេស និង គ្រូដែលមានបទពិសោធចំនួន ២៥ នាក់ ដើម្បីឆ្លុះបញ្ចាំងលើការអនុវត្តកម្មវិធីបំណិនជីវិតកន្លងមក និងរៀបចំផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់ ។ ក្រុមការងារថ្នាក់ស្រុកដែលទទួលខុសត្រូវតាមកំរង និងប្រធានក្រុមបច្ចេកទេសត្រូវរៀបចំឱ្យបានត្រឹមត្រូវ ដើម្បីសម្របសម្រួលសិក្ខាសាលានេះឱ្យមានប្រសិទ្ធភាព និងរកឱ្យឃើញនូវចំណុចដែលត្រូវកែលំអ ព្រមទាំងរៀបចំផែនការសំរាប់បំប៉នគ្រូនៅពេលវិស្សមកាលសម្រាប់ការបង្រៀនបំណិនជីវិតនៅឆ្នាំសិក្សាថ្មី ។

## V. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធទី ១ :ទម្រង់បណ្ណវាយតម្លៃផ្លូវការ

<u>ទម្រង់បណ្ណវាយតម្លៃទី ១ :</u>

**បណ្ណវាយតម្លៃខ្លួនឯង ( សម្រាប់សិស្សប្រើ )**

ឈ្មោះសិស្ស ............................... សាលា ................................. កម្រង .............................. ស្រុក ...................................

**១. សមត្ថភាពមិនទាន់សម្រេចបាន** **២. សមត្ថភាពកំពុងទទួលបាន** **៣. សមត្ថភាពទទួលបានពេញលេញ**

ការងារប្រតិបត្តិ: ស្តីពីការផ្សព្វផ្សាយដល់សហគមន៍

ចូរអានប្រយោគនីមួយៗក្នុងតារាងខាងក្រោម រួចគូសសញ្ញា ( ✓ ) ក្នុងប្រអប់ចម្លើយណាមួយដែលស្របនឹងបំណិនដែលសិស្សបានអភិវឌ្ឍ ។

| ល.រ | បំណិនដែលបានអភិវឌ្ឍ | យល់ស្របខ្លះៗ | យល់ស្រប | យល់ស្របខ្លាំង |
|---|---|---|---|---|
| | | (៤ ពិន្ទុ) | (៧ ពិន្ទុ) | (១០ ពិន្ទុ) |
| 0 | **ការបង្ហាញ:** ខ្ញុំមានទំនុកចិត្តក្នុងការឡើងបង្ហាញ និង បកស្រាយពន្យល់បានច្បាស់លាស់ ។ | ✓ | | |
| ១ | **បំណិនអន្តរបុគ្គល:** នៅក្នុងថ្នាក់ខ្ញុំបានចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយមិត្តភក្តិជាញឹកញាប់ ។ | | | |
| ២ | **ការទំនាក់ទំនង:** ខ្ញុំចូលចិត្តមិត្តរួមថ្នាក់របស់ខ្ញុំ, យើងតែងជួយគ្នា ហើយមិនដែល មានទំនាស់នឹងគ្នាទេ ។ | | | |
| ៣ | **ការគិតល្អិតល្អន់:** ខ្ញុំតែងពិចារណារកហេតុផល, មានអំណះអំណាង និង ភស្តុតាងច្បាស់លាស់ ។ | | | |
| ៤ | **ការដោះស្រាយបញ្ហា:** ខ្ញុំកំណត់បានដំណោះស្រាយច្រើនចំពោះបញ្ហាមួយ ហើយរើសយកដំណោះស្រាយដែលខ្ញុំ អាចដោះស្រាយបាន ។ | | | |
| ៥ | **ការសម្រេចចិត្ត:** ខ្ញុំបានប្រមូលព័ត៌មាន និងភស្តុតាងជាច្រើនមុននឹងធ្វើការសម្រេចចិត្ត ។ | | | |
| ៦ | **ការកំណត់គោលដៅ:** ខ្ញុំតែងរៀបចំផែនការ និងវត្ថុបានច្បាស់លាស់ដើម្បីអនុវត្តការងារឱ្យបានជោគ ជ័យ ។ | | | |
| ៧ | **ទំនុកចិត្តលើខ្លួនឯង:** ខ្ញុំមានភាពប្រាកដប្រជាមិនស្ទាក់ស្ទើរ និង អាចធ្វើអ្វីមួយដោយខ្លួនឯងបាន ។ | | | |
| ៨ | **ការឱ្យតម្លៃលើខ្លួនឯង:** ខ្ញុំគិតវិជ្ជមានពីខ្លួនឯង និងសាទរចំពោះជោគជ័យដែលខ្លួនធ្វើបាន ។ | | | |
| ៩ | **ការទទួលខុសត្រូវ:** ខ្ញុំទទួលស្គាល់ការពិត និង កែលំអចំណុចខ្វះខាតរបស់ខ្ញុំ ។ | | | |
| ១០ | **ឥរិយាបថវិជ្ជមាន:** ខ្ញុំមានចិត្ត និង គំនិតទូលំទូលាយ ឱ្យតម្លៃអ្នកដទៃ និង ទទួលការរិះគន់ដោយរីករាយ ។ | | | |
| មធ្យមភាគ | | ១ ☐ | ២ ☐ | ៣ ☐ |

## <u>ទម្រង់ប័ណ្ណវាយតម្លៃទី ២:</u>

### ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ (សម្រាប់គ្រូប្រើ )

ឈ្មោះសិស្ស .................................. សាលា ................................. កម្រង ...................................... ស្រុក ..........................

**១. សមត្ថភាពមិនទាន់សម្រេចបាន** **២. សមត្ថភាពកំពុងទទួលបាន** **៣. សមត្ថភាពទទួលបានពេញលេញ**

| **កិច្ចការទី ១:** តេស្តលើចំណេះដឹងដែលទទួលបាន និងការប្រើប្រាស់ | | **ពិន្ទុ** | | |
|---|---|---|---|---|
| | | ១-៤ | ៥-៧ | ៨-១០ |
| ១ | ចំណេះដឹងដែលទទួលបាន | | | |
| ២ | ការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង | | | |
| ៣ | ការប្រើប្រាស់ចំណេះដឹងសម្រាប់គ្រួសារ និង សហគមន៍ | | | |
| មធ្យមភាគ | | ១ ☐ | ២ ☐ | ៣ ☐ |

**កិច្ចការទី ២:** ការងារប្រតិបត្តិស្តីពីការផ្សព្វផ្សាយដល់សហគមន៍

ចូរអានប្រយោគនីមួយៗក្នុងតារាងខាងក្រោម រួចគូសសញ្ញា ( ✓ ) ក្នុងប្រអប់ចម្លើយណាមួយដែលស្របនឹងបំណិនដែលសិស្សបានអភិវឌ្ឍ ។

| **ល.រ** | **បំណិនដែលបានអភិវឌ្ឍ** | **យល់ស្របខ្លះៗ** | **យល់ស្រប** | **យល់ស្របខ្លាំង** |
|---|---|---|---|---|
| | | (៤ ពិន្ទុ) | (៧ ពិន្ទុ) | (១០ ពិន្ទុ) |
| 0 | **ការបង្ហាញ:** ខ្ញុំមានទំនុកចិត្តក្នុងការឡើងបង្ហាញ និង បកស្រាយពន្យល់បានច្បាស់លាស់ ។ | ✓ | | |
| ១ | **បំណិនអន្តរបុគ្គល:** នៅក្នុងថ្នាក់ខ្ញុំបានចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយមិត្តភក្តិជាញឹកញាប់ ។ | | | |
| ២ | **ការទំនាក់ទំនង:** ខ្ញុំចូលចិត្តមិត្តរួមថ្នាក់របស់ខ្ញុំ, យើងតែងជួយគ្នា ហើយមិនដែល មានទំនាស់នឹងគ្នាទេ ។ | | | |
| ៣ | **ការគិតល្អិតល្អន់:** ខ្ញុំតែងពិចារណារកហេតុផល អំណះអំណាង និង ភស្តុតាងច្បាស់ លាស់ ។ | | | |
| ៤ | **ការដោះស្រាយបញ្ហា:** ខ្ញុំកំណត់បានដំណោះស្រាយច្រើនចំពោះបញ្ហាមួយ ហើយរើសយកដំណោះស្រាយដែលខ្ញុំ អាចដោះស្រាយបាន ។ | | | |
| ៥ | **ការសម្រេចចិត្ត:** ខ្ញុំបានប្រមូលព័ត៌មាន និងភស្តុតាងជាច្រើនមុននឹងធ្វើការសម្រេចចិត្ត ។ | | | |
| ៦ | **ការកំណត់គោលដៅ:** ខ្ញុំតែងរៀបចំផែនការបានច្បាស់លាស់ ដើម្បីអនុវត្តការងារឱ្យបានជោគជ័យ ។ | | | |
| ៧ | **ទំនុកចិត្តលើខ្លួនឯង:** ខ្ញុំមានភាពប្រាកដប្រជាមិនស្ទាក់ស្ទើរ និង អាចធ្វើអ្វីមួយដោយខ្លួនឯងបាន ។ | | | |
| ៨ | **ការឱ្យតម្លៃលើខ្លួនឯង:** ខ្ញុំគិតវិជ្ជមានពីខ្លួនឯង និងសាទរចំពោះជោគជ័យដែលខ្លួនធ្វើបាន ។ | | | |
| ៩ | **ការទទួលខុសត្រូវ:** ខ្ញុំទទួលស្គាល់ការពិត និង កែលំអចំណុចខ្វះខាតរបស់ខ្ញុំ ។ | | | |
| ១០ | **ឥរិយាបថវិជ្ជមាន:** ខ្ញុំមានចិត្ត និងគំនិតទូលំទូលាយ ឱ្យតម្លៃអ្នកដទៃ និងទទួលការរិះគន់ដោយរីករាយ ។ | | | |
| មធ្យមភាគ | | ១ ☐ | ២ ☐ | ៣ ☐ |
| **សរុបមធ្យមភាគ** | | **១ ☐** | **២ ☐** | **៣ ☐** |

## ទម្រង់បណ្ណវាយតម្លៃទី ៣ :

**តារាងបូកសរុបវាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់ ( សម្រាប់គ្រូប្រើ )**

ថ្នាក់ទី ........................................ សាលា ................................ កម្រង ..................................... ស្រុក .....................................

**១. សមត្ថភាពមិនទាន់សម្រេចបាន** **២. សមត្ថភាពកំពុងទទួលបាន** **៣. សមត្ថភាពទទួលបានពេញលេញ**

| ល.រ | ឈ្មោះសិស្ស | កិច្ចការទី ១ | | | កិច្ចការទី ២ | | | មធ្យមភាគ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ចំណេះដឹង | | | ការងារប្រតិបត្តិ | | | ☹ | 😐 | ☺ |
| | | ១ | ២ | ៣ | ១ | ២ | ៣ | ១ | ២ | ៣ |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |
| ៥ | | | | | | | | | | |
| ៦ | | | | | | | | | | |
| ៧ | | | | | | | | | | |
| ៨ | | | | | | | | | | |
| ៩ | | | | | | | | | | |
| ១០ | | | | | | | | | | |
| ១១ | | | | | | | | | | |
| ១២ | | | | | | | | | | |
| ១៣ | | | | | | | | | | |
| ១៤ | | | | | | | | | | |
| ១៥ | | | | | | | | | | |
| ១៦ | | | | | | | | | | |
| ១៧ | | | | | | | | | | |
| ១៨ | | | | | | | | | | |
| ១៩ | | | | | | | | | | |
| ២០ | | | | | | | | | | |
| ២១ | | | | | | | | | | |
| ២២ | | | | | | | | | | |
| ២៣ | | | | | | | | | | |
| ២៤ | | | | | | | | | | |
| ២៥ | | | | | | | | | | |

ថ្ងៃទី...........ខែ...................ឆ្នាំ.....................

.

គ្រូបង្រៀន

## ឧបសម្ព័ន្ធទី ២ : ទម្រង់ប័ណ្ណវាយតម្លៃក្រៅផ្លូវការ

<u>ទម្រង់ប័ណ្ណវាយតម្លៃទី ១ :</u>

### ការវាយតម្លៃពីអារម្មណ៍របស់សមាជិកនៅក្នុងក្រុម

សិស្សគួររង្វង់រូបមុខមនុស្ស ដែលតំណាងឱ្យអារម្មណ៍របស់គេពីសមាជិកនៅក្នុងក្រុមដែលគេធ្វើការជាមួយ ។

| | | |
|---|---|---|
| ខ្ញុំលើកទឹកចិត្តសមាជិកដទៃទៀតនៅក្នុងក្រុម ។ |  |  |
| ខ្ញុំផ្តល់គំនិត និង ព័ត៌មានទៅឱ្យសមាជិកផ្សេងទៀត ។ |  |  |
| សមាជិកផ្សេងទៀតនៅក្នុងក្រុមរបស់ខ្ញុំបានលើកទឹកចិត្តខ្ញុំ ។ |  |  |
| សមាជិកផ្សេងទៀតបានផ្តល់ គំនិត និង ព័ត៌មានដល់ខ្ញុំ ។ |  |  |

<u>ទម្រង់ប័ណ្ណវាយតម្លៃទី ២ :</u>

### ការវាយតម្លៃការងារក្រុមពីចំណុចចូលចិត្ត និង ចំណុចកែលំអ

| អ្វីដែលយើងចូលចិត្ត | អ្វីដែលយើងចង់កែលំអ |
|---|---|
| | |

**គំនិតសម្រាប់ពេលក្រោយ នៅពេលដែលយើងធ្វើការក្នុងក្រុមសហការ**

**ទម្រង់ប័ណ្ណវាយតម្លៃទី ៣ :**

**ការគិតអំពីក្រុមរបស់ខ្ញុំ**

1. តើអ្នកបានធ្វើអ្វីខ្លះ នៅក្នុងក្រុម ដើម្បីធ្វើឱ្យក្រុមរបស់អ្នកមានដំណើរការល្អ?

a. ______________________________________________

b. ______________________________________________

2. តើអ្នកបានមើលឃើញអ្វីកើតឡើង ដែលបណ្តាលឱ្យមានបញ្ហានៅក្នុងក្រុមរបស់អ្នក?

______________________________________________

______________________________________________

3. តើក្រុមរបស់អ្នកអាចធ្វើអ្វីលើកក្រោយ ដើម្បីឱ្យការធ្វើការរបស់អ្នកបានល្អជាមួយគ្នា?

______________________________________________

______________________________________________

<u>ទម្រង់បំណ្ណវាយតម្លៃទី ៤ :</u>

## តារាងពិនិត្យតាមដានក្រុម

**ចូរគូសរង្វង់ត្រង់ចម្លើយណាមួយដែលអ្នកពេញចិត្ត ។សូមបញ្ជាក់ថាអ្នកមិនអាចគូសយកចម្លើយលើសពីមួយបានឡើយ ។**

***ឧទាហរណ៍:***

*០. យើងបានផ្តល់ឱកាសឱ្យសមាជិកក្រុមបញ្ចេញយោបល់បានគ្រប់ៗ ។*

**(ជានិច្ចជាកាល)** ម្តងម្កាល មិនដែលសោះ

*១- យើងបានត្រួតពិនិត្យដើម្បីប្រាកដថាយើងបានយល់ពីការណែនាំ ។*

ជានិច្ចជាកាល ម្តងម្កាល មិនដែលសោះ

*២- យើងបានចែករំលែកសម្ភាររបស់យើង និង ប្តូរវេនគ្នាដើម្បីប្រើប្រាស់សម្ភារទាំងនោះ ។*

ជានិច្ចជាកាល ម្តងម្កាល មិនដែលសោះ

*៣-យើងបានជួយគ្នាទៅវិញទៅមក ។*

ជានិច្ចជាកាល ម្តងម្កាល មិនដែលសោះ

*៤- យើងបានលើកសរសើរគ្នាទៅវិញទៅមក ។*

ជានិច្ចជាកាល ម្តងម្កាល មិនដែលសោះ

*៥- យើងបានស្តាប់ដោយគ្មានការរំខាន ។*

ជានិច្ចជាកាល ម្តងម្កាល មិនដែលសោះ

*៦- យើងអាចធ្វើបានប្រសើរលើ ( បំណិនសហប្រតិបត្តិការ)____________________________________ដោយ*

________________________________________________________________________

## ឧបសម្ព័ន្ធទី ៣ : គំរូបំណែងអង្កេតថ្នាក់

## <u>បំណែងអង្កេតថ្នាក់បំណិនជីវិត</u>

| | | |
|---|---|---|
| ឈ្មោះសាលា:...................................... | កំរង:................................................ | ស្រុក:................................................ |
| ឈ្មោះគ្រូ:......................................... | ថ្នាក់:................................................ | មុខវិជ្ជា:............................................... |
| កាលបរិច្ឆេទ:...................................... | សរុបចំនួនសិស្ស:..................................... | ចំនួនសិស្សវត្តមាន:................................. |

៥_ ល្អណាស់　　៤_ល្អ　　៣_បង្គួរ　　២_មធ្យម　　១_ចំណុចកែលំអ

| | កត្តាចង្អុលបង្ហាញ | សេចក្តីអធិប្បាយ | ពិន្ទុ | ភស្តុតាង |
|---|---|---|---|---|
| I-លក្ខណៈសម្បត្តិរបស់គ្រូ ~ អត្តចរិតៈ | ១<br>ការរៀបចំកិច្ចតែងការបង្រៀន | ✓ គ្រូបានរៀបចំផែនការបង្រៀន និង សម្ភារសម្រាប់សិស្ស<br>✓ សម្ភារដែលគ្រូបានរៀបចំ ឬជ្រើសរើសឡើង បង្ហាញថាគ្រូបានធ្វើវាដោយគិតយ៉ាងខ្លាំង ដើម្បីជួយដល់សិស្សស្វែងយល់ និងសម្រេចឱ្យបាននូវវត្ថុបំណងមេរៀនរបស់គាត់ ។<br>✓ គ្រូបានបង្ហាញពីការចូលរួមដោះស្រាយបញ្ហាពេលបង្រៀន តាមវិធីយ៉ាងល្អ<br>✓ គ្រូមានការរៀបចំយ៉ាងប្រសើរពេលបង្រៀន | ១<br>២<br>៣<br>៤<br>៥ | |
| | ២<br>ការយល់ពីមេរៀន | ✓ គ្រូអាចពន្យល់វត្ថុបំណងមេរៀនតាមវិធីផ្សេងៗ<br>✓ គ្រូអាចពន្យល់ពាក្យពិបាកនិងខ្លឹមសារបានល្អដោយមានឧទាហរណ៍ច្បាស់លាស់<br>✓ គ្រូបានធ្វើការស្រាវជ្រាវ និងធ្វើផែនការ ដែលបង្ហាញពីការដកស្រង់ខុសគ្នា ពីឧទាហរណ៍ងាយៗដែលមាននៅក្នុងខ្លឹមសារបង្រៀន ។<br>✓ គ្រូបានជ្រើសរើសឧទាហរណ៍និងបកស្រាយយ៉ាងល្អដែលអាចជួយសិស្សឱ្យស្វែងយល់អំពីគំនិតសំខាន់ៗ និងគំនិតបន្ថែមផ្សេងៗ | ១<br>២<br>៣<br>៤<br>៥ | |
| | ៣<br>អាកប្បកិរិយា និងឥរិយាបថរបស់គ្រូ | ✓ ញញឹម និងរាក់ទាក់ចំពោះសិស្ស<br>✓ លើកទឹកចិត្តសិស្សជានិច្ច<br>✓ ដើរជុំវិញថ្នាក់រៀន (ដោយមិនឈរនៅទ្រឹងនឹងកន្លែងពេញមួយម៉ោង)<br>✓ យកចិត្តទុកដាក់ចំពោះសិស្សម្នាក់ៗជាបុគ្គល | ១<br>២<br>៣<br>៤<br>៥ | |
| | ៤<br>ទំនាក់ទំនងជាមួយសិស្ស | ✓ យល់ពីតម្រូវការរបស់សិស្សម្នាក់ៗ<br>✓ គ្រូឱ្យតម្លៃសិស្សគ្រប់ៗគ្នាក្នុងថ្នាក់រៀន និងលើកទឹកចិត្តឱ្យចូលរួមក្នុងការសិក្សាមេរៀន<br>✓ ប្រតិកម្មយ៉ាងរហ័សចំពោះសិស្សដែលសំដែងកិរិយាមិនសមរម្យ<br>✓ ផ្តល់ព័ត៌មានត្រឡប់ចំពោះសិស្សជាប្រក្រតី | ១<br>២<br>៣<br>៤<br>៥ | |

**II-បំណិនក្នុងការបង្រៀន - មធ្យមភាគៈ**

| | | | |
|---|---|---|---|
| **១**<br>**បំណិនក្នុងការបង្ហាញ** | ✓ ប្រើប្រាស់ក្ដារខៀនដោយមានសណ្ដាប់ធ្នាប់<br>✓ សរសេរអក្សរបានច្បាស់លើក្ដារខៀនដែលសិស្សទាំងអស់អាចមើលឃើញ<br>✓ បង្ហាញរូបភាពដែលសិស្សទាំងអស់អាចមើលឃើញ<br>✓ បង្ហាញឧទាហរណ៍ និងបកស្រាយខ្លឹមសារយ៉ាងច្បាស់លាស់ | ១<br>២<br>៣<br>៤<br>៥ | |
| **២**<br>**បច្ចេកទេសក្នុង**<br>**ការសួរសំនួរ** | ✓ គ្រូប្រើប្រាស់ទំរង់សំណួរច្រើនបែប( សំណួរបើក,សំណួរបិទ,សំណួរចង់ចាំ សំណួរត្រិះរិះ.)<br>✓ គ្រូប្រើសំណួរភ្ជាប់ទៅនឹងតថភាពជាក់ស្ដែង<br>✓ គ្រូផ្ដល់ឱកាសឱ្យសិស្សសួរសំណួរ និងបញ្ជូនសំណួរនោះទៅសិស្សដទៃដើម្បីឆ្លើយ<br>✓ គ្រូបកស្រាយចម្លើយដោយវិជ្ជមាន | ១<br>២<br>៣<br>៤<br>៥ | |
| **៣**<br>**ការប្រើប្រាស់សម្ភារ**<br>**ឧបទេស** | ✓ គ្រូបង្ហាញសម្ភារឧបទេស និងធានាថាសិស្សទាំងអស់អាចមើលឃើញបាន<br>✓ គ្រូគូររូបភាព /គំនូសតាង ដើម្បីពន្យល់សិស្ស<br>✓ គ្រូឱ្យសិស្សប្រើប្រាស់សម្ភារសិក្សា និងឧបករណ៍ផ្សេងៗដែលមាននៅពេលរៀន<br>✓ គ្រូអាចធ្វើឱ្យសិស្សចូលរួមបង្កើតសម្ភារក្នុងពេលរៀន | ១<br>២<br>៣<br>៤<br>៥ | |
| **៤**<br>**ការជំរុញ និង**<br>**លើកទឹកចិត្តសិស្ស** | ✓ គ្រូប្រមូលអារម្មណ៍ និងការផ្ដោតយកចិត្តទុកដាក់របស់សិស្ស<br>✓ គ្រូជំរុញសិស្សឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពផ្សេងៗ<br>✓ គ្រូអាចលើកទឹកចិត្តសិស្សឱ្យបន្តពិនិត្យ និងព្យាយាមធ្វើការងាររបស់គេជានិច្ច<br>✓ គ្រូបង្ហាញការយល់ដឹងពីវិធីរបស់សិស្ស និងប្រើប្រាស់វិធីសាស្ត្រជាក់លាក់ដើម្បីលើកទឹកចិត្តពួកគេ | ១<br>២<br>៣<br>៤<br>៥ | |
| **៥**<br>**ការផ្ដល់ព័ត៌មាន**<br>**ត្រឡប់ដល់សិស្ស** | ✓ គ្រូទទួលយកសំណួរ និងការចង់ដឹងរបស់សិស្ស ហើយផ្ដល់ព័ត៌មានត្រឡប់ដល់គេវិញ ដោយទឹកចិត្តរីករាយ<br>✓ ការផ្ដល់ព័ត៌មានត្រឡប់ជាប្រចាំ និងមិនឱ្យសិស្សរង់ចាំ<br>✓ ការផ្ដល់ព័ត៌មានត្រឡប់ក្នុងន័យបែបស្ថាបនា ប៉ុន្តែពុំមែនជាការរិះគន់<br>✓ ការផ្ដល់ព័ត៌មានត្រឡប់ដោយជំរុញឱ្យសិស្សមានគំនិតបន្ថែម | ១<br>២<br>៣<br>៤<br>៥ | |
| **៦**<br>**ការសង្ខេបខ្លឹមសារ**<br>**មេរៀន** | ✓ គ្រូបានទុកពេលសម្រាប់សង្ខេបបញ្ចប់មេរៀនដោយសមរម្យ<br>✓ គ្រូអាចធ្វើឱ្យសិស្សទាំងអស់ចាប់អារម្មណ៍មុនពេលសង្ខេប បញ្ចប់មេរៀន<br>✓ គ្រូសង្ខេបខ្លឹមសារដោយខ្លួនឯង ឬដោយឱ្យសិស្សសង្ខេបជំនួស ដែលផ្សារភ្ជាប់ ទៅនឹងវត្ថុបំណងមេរៀន<br>✓ គ្រូផ្ដល់ពេលឱ្យសិស្សសួរសំណួរផ្សេងៗមុនពេលបញ្ចប់មេរៀន | ១<br>២<br>៣<br>៤<br>៥ | |

| | | | | |
|---|---|---|---|---|
| III-ការគ្រប់គ្រងថ្នាក់ - មធ្យមភាគ: | **១**<br>**ការផ្តល់ការណែនាំ** | ✓ គ្រូទាញចំណាប់អារម្មណ៍សិស្សមុននឹងផ្តល់សេចក្តីណែនាំ<br>✓ គ្រូផ្តល់សេចក្តីណែនាំងាយៗនិងច្បាស់លាស់ ព្រមទាំងមានឧទាហរណ៍បញ្ជាក់ផង<br>✓ គ្រូពិនិត្យលើសេចក្តីណែនាំ ដោយសួរសិស្សអោយប្រាប់ពីអ្វីដែលគេត្រូវធ្វើ/អ្វីដែលជាការអភិវឌ្ឍសមត្ថភាព<br>✓ គ្រូកំណត់ពេលវេលាជាក់លាក់តាមសកម្មភាពនីមួយៗ | ១<br>២<br>៣<br>៤<br>៥ | |
| | **២**<br>**ការរៀបចំសកម្មភាពបង្រៀន** | ✓ សកម្មភាពសិក្សាសមស្របទៅនឹងកម្រិតរបស់សិស្ស និងវត្ថុបំណងមេរៀន<br>✓ គ្រូបង្កើតសកម្មភាពសិក្សាប្លែកៗពីគ្នា ( ការធ្វើការជាក្រុម, ក្រុមតូចៗ, ជាដៃគូ, និងជាបុគ្គល) ដោយមានប្រសិទ្ធភាព និងដំណើរការល្អ<br>✓ គ្រូសង្កេតការរីកចម្រើនក្នុងពេលធ្វើសកម្មភាព<br>✓ ផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់សិស្សធ្វើសកម្មភាពនីមួយៗ | ១<br>២<br>៣<br>៤<br>៥ | |
| | **៣**<br>**ការត្រួតពិនិត្យសកម្មភាពរៀនសូត្រ និងការសម្របសម្រួល** | ✓ គ្រូពិនិត្យដំណើរការសកម្មភាពជាក្រុម និងជាបុគ្គលដោយ ហ្មត់ចត់ ហើយបើសិនជាចាំបាច់គ្រូត្រូវណែនាំបន្ថែម<br>✓ គ្រូលើកទឹកចិត្តសិស្សឱ្យកែកំហុសខ្លួនឯង និងការកែកំហុសពីមិត្តភក្តិ<br>✓ វិធីសាស្ត្រដែលគ្រូប្រើសម្រាប់កែកំហុសសិស្សប្លែកៗពីគ្នាតាមការយល់ដឹងរបស់ គ្រូ ចំពោះបុគ្គលិកលក្ខណៈរបស់សិស្សម្នាក់ៗ<br>✓ គ្រូប្រើបច្ចេកទេសជំរុញនិងលើកទឹកចិត្តដោយវិជ្ជមានពេលកែកំហុសសិស្ស | ១<br>២<br>៣<br>៤<br>៥ | |
| | **៤**<br>**អន្តរកម្មក្នុងថ្នាក់រៀន រវាងគ្រូ-សិស្ស សិស្ស-សិស្ស** | ✓ គ្រូជំរុញឱ្យសិស្សសួរសំណួរ និងបញ្ចេញទស្សនៈដោយចំហរ<br>✓ សិស្សបង្ហាញពីចំណាប់អារម្មណ៍ស្តាប់សិស្សដទៃទៀតពេលដែលគេពិភាក្សាគ្នា ហើយរងចាំធ្វើការពិភាក្សា នៅពេលដល់វេនរបស់គេ<br>✓ បង្ករលក្ខណៈឱ្យសិស្សខ្លាំងជួយសិស្សខ្សោយ<br>✓ សិស្សម្នាក់ៗមានអន្តរកម្មជាមួយសិស្សដទៃទៀតយ៉ាងហោចណាស់ ៣ នាក់ | ១<br>២<br>៣<br>៤<br>៥ | |
| | **៥**<br>**ការគ្រប់គ្រងពេលវេលា** | ✓ គ្រូចេះបត់បែនទៅតាមសកម្មភាពផ្សេងៗដោយពេលខ្លះមិនចាំបាច់ផ្តោតតាមពេល វេលាដែលកំណត់នៅក្នុងកិច្ចតែងការបង្រៀន<br>✓ គ្រូបែងចែកពេលវេលាបានសមស្របទៅតាមសកម្មភាពនីមួយៗ<br>✓ គ្រូរំលឹកសិស្សពីពេលវេលាដែលមានសម្រាប់ធ្វើកិច្ចការ<br>✓ ការផ្លាស់ប្តូរពីសកម្មភាពមួយទៅសកម្មភាពមួយទៀតប្រព្រឹត្តទៅយ៉ាងរលូន ដោយផ្អែកការណែនាំ និងពេលវេលាកំណត់ | ១<br>២<br>៣<br>៤<br>៥ | |
| | **៦**<br>**បរិយាកាសថ្នាក់រៀន** | ✓ គ្រូរៀបចំកន្លែងអង្គុយបានសមស្របទៅនឹងអន្តរកម្មរបស់សិស្សព្រមទាំងសមរម្យសម្រាប់សកម្មភាពសិក្សាដែលបានបង្កើតឡើង<br>✓ សម្ភារឧបទ្ទេស បានត្រៀមនិងរៀបចំឡើងទៅតាមលក្ខណៈដែលគ្រូ និងសិស្សងាយស្រួលក្នុងការយកមកប្រើប្រាស់នៅក្នុងថ្នាក់រៀន<br>✓ ទីកន្លែងសិក្សាមានអនាម័យល្អ មានសណ្តាប់ធ្នាប់ និងសមរម្យសម្រាប់ការសិក្សា<br>✓ គ្រូលើកទឹកចិត្តសិស្សឱ្យនិយាយក្នុងសំឡេងសមល្មមដែលសិស្សទូទៅអាចស្តាប់បាន ពេលដែលឆ្លើយ ឬ សួរសំណួរ ឬផ្តល់យោបល់ នៅក្នុងថ្នាក់ | ១<br>២<br>៣<br>៤<br>៥ | |

# ការផ្តល់ព័ត៌មានត្រឡប់

## យោបល់រួមលើលទ្ធផលបង្រៀន

## ចំណុចល្អរបស់គ្រូ (ចំនួនបីចំណុច)

## ចំណុចដែលគួរកែលំអរបស់គ្រូ (ចំនួនពីរចំណុច)

## ចំណុចដែលត្រូវកែលំអសម្រាប់ការបង្រៀនលើកក្រោយ

| | | | |
|---|---|---|---|
| អ្នកចុះសង្កេត: | | គ្រូបង្រៀន: | |
| ហត្ថលេខា: | | ហត្ថលេខា: | |
| មធ្យមភាគសរុប: | | | |